ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Feb-2015, 09:32
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២៣៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ័ង

លោក ម៉ាធូវ ម៉ាកាធី
*(Mr. Matthew McCARTHY)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Vincent De Wilde D'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ម៉ាទីន ហ្សាកកាំង *(Ms. Martine JACQUIN)*

លោក លោក ម៉ាហេស រ៉ៃ *(Mr. Mahesh RAI)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធារី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក សួន វិសាល | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក សយ សែន (2-TCCP-271) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សយ សែន** (2-TCCP-271)


សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........ទំព័រ ៥
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្ដើមពី........ទំព័រ ២៥
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ទំព័រ ២៩
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........ទំព័រ ៥៦

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ យើងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សយ សែន។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោក អាកទួរ វែកកែន មេធាវីអន្តរជាតិការពារក្តីឱ្យលោក ខៀវ សំផន អវត្តមាន ដោយសារមូលហេតុសុខភាព។ កត់សម្គាល់ផងដែរ អំពីវត្តមានលោក ម៉ាហេស រ៉េ *(Mr Mahesh RAI)* ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដែលត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារួចហើយ។ ប៉ុន្តែមិនទាន់បានទទួលស្គាល់នៅចំពោះមុខ អ.ជ.ស.ដ ក្នុងរយៈពេលកន្លងមកនៅឡើយ។ ដោយឡែក លោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺលោក សយ សែន។ លោកមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការ។ ហើយនៅថ្ងៃនេះដែរ មិនមានសាក្សីបម្រុងនោះទេ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំលះបង់សិទ្ធិរបស់លោក នួន ជា។

អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយមូលហេតុ

មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការបានល្អនៅថ្ងៃអនាគត ឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ដោយមេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះ ថាការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់ក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាង ក្នុងបង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលនៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យថែទាំសុខភាពរបស់ជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ នួន ជា មានអាការៈឈឺចង្កេះ និងវិលមុខ នៅពេលអង្គុយ ហើយបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៧:០៧]

ដោយផ្អែកលើមូលដ្ឋាន -- មូលហេតុនេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមអញ្ជើញលោក ពេជ អង្គ ព្រោះតាមក្រឡាបញ្ជីសវនាការរាយការណ៍មិញថា មានវត្តមាននូវមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីថ្មីដែលមិនទាន់បានសុំឲ្យអង្គជំនុំជម្រះទទួលស្គាល់ពីពេលកន្លងមក។

សូមអញ្ជើញលោក ពេជ អង្គ!

[០៩:០៨:១៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រមអង្គសវនាការ និង សាធារណជន។ បាទ ជាបឋម ខ្ញុំសូមជម្រាបថា សម្រាប់ខ្លួនខ្ញុំផ្ទាល់ ខ្ញុំនឹងមានអវត្តមានពី -- ក្នុងការចូលរួមផ្ទាល់ក្នុងសវនាការនេះ ពីថ្ងៃស្អែកទៅ រហូតទៅដល់មុនចូលឆ្នាំខ្មែរ។ ក៏ប៉ុន្តែនៅពេលដែលអវត្តមានរបស់ខ្ញុំ គឺលោក វ៉ែន ពៅ ដែលជាមេធាវីមុខនាំបម្រុង និងជំនួសខ្ញុំនៅក្នុងសវនាការនេះ។

ទី២ ពាក់ព័ន្ធនឹងមេធាវីបរទេសថ្មី គឺខាងក្រោយខ្ញុំ ខាងស្តាំដៃនេះ គឺមានវត្តមានរបស់លោក ម៉ាហេស រ៉េ។ លោកគឺជាមេធាវីជនជាតិសាំងហ្គាពួរ ដែលត្រូវបានទទួលស្គាល់ដោយ ចូលទៅក្នុងគណៈមេធាវីរបស់សាំងហ្គាពួរ នៅខែកុម្ភៈ ឆ្នាំ២០១១ រហូតមកដល់បច្ចុប្បន្ននេះ។ ហើយលោកបានទទួលដោយ ឲ្យចូលរួមជាសមាជិកគណៈមេធាវីកម្ពុជានៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣ និងបានធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣។ លោក ម៉ាហេស រ៉េ តំណាងដើមបណ្តឹងរដ្ឋប្បវេណីពីររូប ជាមួយមេធាវីជាតិរបស់លោក គឺលោក សំ សុគង់។ ដូច្នេះ សូមលោកប្រធាន លោក លោកស្រីចៅក្រម ទទួលស្គាល់លោកដើម្បីឲ្យមានសិទ្ធិជាមេធាវីពេញសិទ្ធិនៅចំពោះមុខសាលាក្តីនេះ។ សូមលោកប្រធានអនុញ្ញាត។ សូមអរគុណលោកប្រធាន។

[០៩:០៩:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ម៉ាអេស រ៉េ *(Mr Mahesh RAI)* ពេលនេះអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកជាមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តីតាមរយៈការទទួលស្គាល់នេះ លោកមេធាវីទទួលបានសិទ្ធ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតដែរ។

អង្គុយចុះ! ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិការជូនដល់ក្រុមសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

បាទសូមផ្អាកបន្តិចសិន បាទសូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។ ខ្ញុំបាទមានសំណើតូចមួយទាក់ទងទៅនឹងសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាលេខ E327/4 ដែលនៅក្នុងនោះតំណាងសហ

ព្រះរាជអាជ្ញាបានធ្វើការចម្លងជូននូវឯកសារនេះទៅលោកស្រី ទូច វរល័ក្ស និងលោក ខលវីន សោនដឺស៍ ហើយដែលបានដាក់ថាមេធាវីការពារជនជាប់ចោទ បានន័យថានៅក្នុងកូឡោនមួយនៅក្នុងទម្រង់របស់គាត់ហ្នឹងគឺមានដាក់ថា "មេធាវីការពារជនជាប់ចោទ"។ ខ្ញុំបាទបានយល់អំពីសេចក្ដីរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងឯកសារ E321/2 ដែលនិយាយអំពីសេចក្ដីសម្រេចស្ដីពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន។ ខ្ញុំបាទយល់ឃើញថាតាមការណែនាំរបស់អង្គជំនុំជម្រះកន្លងមកបានបញ្ជាក់ថាមេធាវីទាំងពីររូបជាមេធាវីប្រចាំការនេះ គឺមិនចូលទាក់ទងនឹងនីតិវិធីរបស់តុលាការនេះឡើយទេ រហូតណាទាល់តែមានការបញ្ជាពីតុលាការថាឲ្យចូលនៅក្នុងនីតិវិធីនេះ។ ដូច្នេះការកំណត់ថា មេធាវីប្រចាំការទាំងពីរនេះជាមេធាវីការពារជនជាប់ចោទនៅក្នុងឯកសារនេះ វាអាចបង្ហាញឲ្យឃើញថាមេធាវីប្រចាំការទាំងពីរនេះកំពុងតែការពារលោក ខៀវ សំផន នៅក្នុងនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះដែរ។ ដូច្នេះវាអាចឲ្យមានការយល់ច្រឡំ។ ដូច្នេះខ្ញុំបាទសូមស្នើមិនឲ្យមានការប្រើប្រាស់បែបនេះ ឬមួយក៏សហព្រះរាជអាជ្ញាអាចធ្វើការពន្យល់ណាមួយដែលអាចទទួលយកបានក្នុងការដាក់មេធាវីទាំងពីរនាក់នេះថាជាមេធាវីជនជាប់ចោទនៅក្នុងទីនេះ។ បាទ សូមអរគុណ។

[០៩:១៣:០២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្ដីលោក ខៀវ សំផន គឺពិតណាស់យើងៗត្រូវដាក់ថាមេធាវីប្រចាំការនៅលើគម្របនៃសំណើដែលយើងដាក់នៅក្នុងសំណុំឯកសារថ្មីៗនេះ ក៏ប៉ុន្តែអង្គជំនុំជម្រះជាអ្នកបញ្ជាក់ថាមេធាវីទាំងអស់នេះ ទោះបីជាមិនទាន់កំពុងតែអនុវត្តមុខងាររបស់ខ្លួនក៏ដោយក៏ពួកគាត់មានសិទ្ធិទទួលបានព័ត៌មានទាំងអស់ហើយនិងចូលមើលឯកសារបានទាំងអស់ អ៊ីចឹងហើយបានជាឈ្មោះរបស់គាត់មានលេចឡើងនៅលើទំព័រដំបូងនៃសំណើរបស់យើងនេះ។ នេះជាការបញ្ជាក់ពីខាងសហព្រះរាជអាជ្ញាលោកប្រធាន។

[០៩:១៤:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៥:១៣]

**ប្រធានអង្គជំនុំ៖**

បាទ ហើយរឿងតូចតាចទេ ប៉ុន្តែក៏គប្បីជៀសវាងកុំឲ្យមានការខុសឆ្គងដែរ ហើយអង្គជំនុំជម្រះសូមជម្រាបជូនទៅខាងសហព្រះរាជអាជ្ញា ហើយក៏ដូចជាភាគីដទៃទៀតដែរ ហើយប្រសិនបើមានឯកសារត្រូវសរសេរបែបនេះក៏ត្រូវដាក់ឲ្យច្បាស់លាស់ចំណាងជើងថា រវាងមេធាវីការពារជនជាប់ចោទ ហើយនិងក្រុមមេធាវីប្រចាំការ។ បាទ ទំនងជាមិនជាបញ្ហាអីធំដុំទេ អាចដោះស្រាយបញ្ហាបានណ៎ះ!

បាទ សូមប្រគល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោក សយ សែន ខ្ញុំនឹងសួរលោករហូតដល់ប្រហែលជាម៉ោង ដប់មួយនៅព្រឹកនេះ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកចំណុចមួយដែលលោកបានឆ្លើយកាលពីម្សិលមិញ ហើយយើងក៏បានពិភាក្សាគ្នាអំពីការសួរចម្លើយលោកនៅឆ្នាំ១៩៧៤ ក្រោយពីលោកទៅដល់មន្ទីរសន្តិសុខក្រាំងតាចាន់។ លោកបានឆ្លើយថា គេសួរចម្លើយលោកពាក់ព័ន្ធទៅនឹងទំនាក់ទំនងមួយនៅអង្គតាសោម។ ខ្ញុំចង់អានសម្រង់ឯកសារស្ដាប់ចម្លើយរបស់លោកគឺលេខ E3/5214, ជាភាសាខ្មែរ 00223058, ជាភាសាបារាំង 00702889, ជាភាសាអង់គ្លេស 00225503។ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “អ្នកសួរចម្លើយមានបីនាក់ ហើយមេទ័ពម្នាក់ទៀតជាអ្នកយាម។ ពេលសួរចម្លើយនោះ គេសួរខ្ញុំថាមានទាក់ទងជាមួយ ព្រំ សាន់ ដែរឬអត់? ខ្ញុំឆ្លើយថា ខ្ញុំមិនដែលស្គាល់ទេ”។ បន្ទាប់មកគេថា អ្ហែងឆ្លើយឲ្យត្រង់មក។ ខ្ញុំក៏នៅតែឆ្លើយថាអត់ស្គាល់ដដែលហ្នឹង។ រួចហើយអ្នកសួរចម្លើយឲ្យទ័ព ដែលជាអ្នកយាមយកខ្ញុំមកដាក់ខ្នោះវិញ។” ដូច្នេះលោកបានឆ្លើយឈ្មោះ ព្រំ សាន់។ ខ្ញុំចង់សួរលោកថា តើព្រំ សាន់ ហ្នឹង ជាអ្នកណាដែលគេសួរចម្លើយពីឈ្មោះហ្នឹង?

**លោក សយ សែន៖**

**ឆ៖** បាទ គេសួរខ្ញុំថា អ្ហែងដែលស្គាល់ព្រំសាន់អត់? ថាខ្ញុំអត់ស្គាល់ទេ។ ព្រោះ ព្រំ សាន់ ហ្នឹង

គឺគេចោទគាត់ថាគាត់ជាមេក្បត់ជាតិ ប៉ុន្តែខ្ញុំឮសួរតែគេថាមេក្បត់ជាតិ។ ខ្ញុំអត់បានដឹងទេបាទ។

**ស៖** តើលោកអាចដឹងតាមរយៈអ្នកទោសផ្សេងទៀត ឬក៏អ្នកយាមថា ព្រំ សាន់ ហ្នឹងជាអ្នកវាយនៅក្នុងសង្គ្រាម ៥ឆ្នាំ ខាងខ្មែរក្រហម ឬក៏ខាងលន់ នល់?

[០៩:១៨:៤២]

**ឆ៖** បាទ គាត់មិនដឹងខាងណាៗ ក៏ខ្ញុំអត់ស្គាល់ដែរ ប៉ុន្តែគេពីសម័យហ្នឹង គេចោទ ព្រំ សាន់ ថា ព្រំ សាន់ ក្បត់ជាតិ។ ខ្ញុំអត់បានដឹងដែរ ឮសួរតែគេថា ក្បត់ជាតិតែប៉ុណ្ណឹងបាទ។

**ស៖** នៅទំព័របន្ទាប់មកទៀត នៅឯកសារដដែល។ លោកបានឆ្លើយថា៖ “ក្នុងអំឡុងពេលដែលខ្ញុំជាប់នៅក្នុងឃុំឃាំងនោះ អ្នកទោសដទៃទៀត ខ្ញុំដឹងថាត្រូវគេសួរចម្លើយទាក់ទងហ្នឹងរឿង ព្រំ សាន់ ប៉ុណ្ណោះ”។ សុំបញ្ចប់ការដកស្រង់។ តើលោកធ្លាប់ពិភាក្សាជាមួយនឹងអ្នកទោសផ្សេងទៀតដើម្បីចង់ដឹងថា តើគេសួរចម្លើយពួកគេពីរឿងអីដែរនៅពេលដែលគេសួរចម្លើយអ្នកទោសផ្សេងទៀតនោះ? លោកមានបានធ្លាប់សួរអ្នកទោសអ៊ីចឹងទេ?

**ឆ៖** អត់បានដឹងដែរ ប៉ុន្តែថាគាត់ជាប់ជាមួយខ្ញុំ គ្រាន់តែជាប់ខ្នោះជើងជាប់ជាមួយគ្នាជិតគ្នាចេះតែយប់ឡើងលួចសួរគ្នាថា៖ “បងឯងមកមានរឿងអីដែរ?” ថា “ហ៊ឺ! ខ្ញុំគេចោទពីបញ្ហាបងប្អូនខ្ញុំធ្វើស័ក្តិ៣ ឬស័ក្តិ៤ អីអ៊ីចឹងទៅ”។ បាទ ដឹងតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ សម្រាប់ជាប្រតិចារិក ឥឡូវនេះ ខ្ញុំសូមបញ្ជាក់ថាឈ្មោះ ព្រំ សាន់ មាននៅក្នុងឯកសារត្រាំកក់ និងជាពិសេសឈ្មោះនេះត្រូវបានចុះជាច្រើនលើកច្រើនសានៅក្នុងរបាយការណ៍ដែលធ្វើឡើងដោយមន្ទីរក្រាំងតាចាន់ទៅថ្នាក់លើ។ ខ្ញុំសូមលើកឡើងនូវឯកសារបី ក្នុងចំណោមឯកសារផ្សេងទៀត ជាដំបូងគឺឯកសារ E3/4095 នៅទំព័រជាភាសាខ្មែរ ERN 00271090 រហូតទៅដល់ 91, ជាភាសាបារាំង 00721206 ,ជាភាសាអង់គ្លេស 00747237។ ឈ្មោះ ព្រំ សាន់ ក៏មាននៅក្នុងរបាយ-ការណ៍ចម្លើយរបស់អ្នកទោស ស៊ុំ សៀង និង ស៊ុំ សេង គឺឯកសារ E3/4101, ERN ជាភាសាខ្មែរ 00271039, ជាភាសាបារាំង 00854221, ជាភាសាអង់គ្លេស 00322129។ ឯកសារទី៣ និងជាឯកសារចុងក្រោយគឺឯកសារ D157.7, ជាភាសាខ្មែរគឺ ERN 00270883 ទៅដល់ 84 និងទំព័រ 00270886 និងទំព័រ 00270891, ជាភាសាបារាំង 00878221, 00872824 និង 00872829 និង ERN ជាភាសាអង់គ្លេស 00866446 ទៅដល់ 47, 00866450 និង 00866456។

[០៩:២៣:២៥]

លោក សយ សែន ឥឡូវនេះ ខ្ញុំចង់និយាយអំពីអ្នកទោសដែលជាប់រយៈពេលនៅក្រាំងតាចាន់។ ម្សិលមិញនេះ លោកនិយាយអំពីឈ្មោះ តាចិន, តានន ហើយលោកនិយាយថា ពួកគាត់ធ្វើការងារមួយចំនួនជាមួយលោក ដូចជានាំអ្នកទោសដែលគេសួរចម្លើយទៅគុកវិញ ឬក៏ជីករណ្ដៅសម្រាប់ដាក់អ្នកស្លាប់។ ឥឡូវនេះ ខ្ញុំចង់ដកស្រង់នូវសម្រង់មួយនៃឯកសាររបស់លោកគឺ E3/5214, ជាភាសាខ្មែរ 00223064, ជាភាសាបារាំង 00702895, ជាភាសាអង់គ្លេស 00225508។ លោកនិយាយអំពីអ្នកដែលជីករណ្ដៅ។ ខ្ញុំសូមដកស្រង់៖ "ក្រៅពីខ្ញុំមាន តានន និង តាចិន។ តានន ស្លាប់ដោយសារគេវាយសម្លាប់ក្នុងមន្ទីរក្រាំងតាចាន់នោះ ទោសកំហុសរបស់គាត់ជាអ្នកហាណូយ"។ បន្ទាប់មកទៀត "តានន គឺគាត់ត្រូវមានទោសស្រាល និងគេប្រើឱ្យធ្វើការដូចខ្ញុំ។ គាត់គេឱ្យធ្វើចុងភៅសម្រាប់ធ្វើអាហារឱ្យអ្នកទោស។ ថ្ងៃមួយនៅកន្លែងចុងភៅ គាត់កំពុងតែនិយាយជាមួយខ្ញុំថា អញបែបងាប់មុនអ្អែងហើយ។ ពេលដែលកំពុងនិយាយជាមួយខ្ញុំនោះ ស្រាប់តែឈ្មោះ ចេង ជាទ័ពនៅក្រាំងតាចាន់នេះមកហៅគាត់។ ដល់ពេលគាត់បាត់យូរ ខ្ញុំបានដើរទៅមើលកន្លែងកន្លែងគេវាយសម្លាប់អ្នកទោស ខ្ញុំឃើញសពរបស់គាត់ត្រូវគេវាយសម្លាប់ដាក់នៅក្រោមដើមឈើទាលដែលមានចម្ងាយប្រហែល៧០ម៉ែត្រពីគុក"។ សូមបញ្ចប់ការដកស្រង់ចម្លើយ។ ខ្ញុំចង់ដឹងអំពីចម្លើយរបស់លោកនេះ ហេតុអីក៏ថា តានន ហ្នឹងជាអ្នកទោសដោយសារតែគាត់ហ្នឹងជាអ្នកហាណូយនោះ គាត់មានទោសកំហុសដោយសារតែគាត់ជាអ្នកហាណូយ។ ហេតុអីបានជាលោកនិយាយអ៊ីចឹង?

**ឆ៖** បាទបើខ្ញុំនិយាយអ៊ីចឹង បើគាត់មកពីហាណូយៗ គាត់ក៏យកប្រពន្ធនៅឃុំសំរោង ប្រពន្ធគាត់ខ្មែរយើងសុទ្ធសាធ គាត់គេអញ្ជើញគាត់មកក្រាំងតាចាន់ គាត់ក៏មកក្រាំងតាចាន់។ គាត់មកគេក៏ឃុំឃាំងនៅហ្នឹង និងគាត់នៅជាប់ជាមួយខ្ញុំ គាត់ប្រាប់ បានប្រាប់ខ្ញុំថាអ៊ីចឹង បាទ។

[០៩:២៦:១៨]

**ស៖** ក្រៅពី តាចិន និង តានន តើមានអ្នកទោសផ្សេងទៀត ដូចជាលោកដែលមានឋានៈពិសេសខុសពីគេ ដូចថាអាចដើរហើរនៅក្នុងបរិវេណមន្ទីរសន្តិសុខក្រាំងតាចាន់បាន។ តើមានទេ?

**ឆ៖** បាទអត់មានទេ មានតែខ្ញុំបានជម្រាបពីម្សិលមកវិញថា មានតែបីបួនប្រាំនាក់ គេលែងឱ្យធ្វើការតែប៉ុណ្ណឹង មានតែប៉ុណ្ណឹងទេ ក្រៅពីហ្នឹងទៀត អត់មានទេ។

**ស៖** លោកអាចប្រាប់ឈ្មោះអ្នកដែលគេអនុញ្ញាតឱ្យដើរហើរនៅក្នុងគុកហ្នឹងដូចលោកបានទេ? អ្នកណាខ្លះ?

**ធ៖** អាចប្រាប់បាន។ មានកូនចៅ យាយញ៉ៅ គាត់មួយក្រុមគ្រួសារគាត់ហ្នឹងមានកូនគាត់ អាខុម, អាខាយ, អាហាប់, យាយញ៉ៅ, ខ្ញុំ, តាចិន, តានន, អ៊ីហ៊ន។ បាទមានតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ខ្ញុំនឹងព្យាយាមបំភ្លឺឈ្មោះជាភាសាដែល -- ឈ្មោះដែលខ្ញុំឮជាភាសាបារាំង នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមានលេខ D22/1370។ ឯកសារនេះមិនត្រូវបាន បកប្រែទាំងស្រុងជាភាសាអង់គ្លេសទេ ប៉ុន្តែមានតែជាបារាំងនិងខ្មែរ។ គឺឯកសារជាភាសាខ្មែរគឺ 0052 7705។ ជាភាសាបារាំង 01057607។ ខ្ញុំសូមដកស្រង់៖ “អាន់ បានប្រើខ្ញុំនិងឈ្មោះ ខា (កូនយាយញ៉ៅ) ឲ្យជីករណ្ដៅកប់ខ្មោច ដែលខ្មែរក្រហមសម្លាប់នៅក្រាំងតាចាន់។ ក្នុងមួយថ្ងៃ យ៉ាងហោចណាស់ក៏ពីរ ទៅបីនាក់ស្លាប់ដោយសារវាយស្នូរចម្លើយនៅក្នុងគុក។ ថ្ងៃខ្លះ ខ្មែរក្រហមសម្លាប់អ្នកទោស គឺមានទៅ ដល់៥០ ទៅ១០០នាក់ក៏មាន”។ សូមបញ្ចប់ការដកស្រង់។ លោកបានឆ្លើយ មានឈ្មោះពីរក្នុងនេះគឺ យាយញ៉ៅ។ នៅក្នុងឯកសារនេះ តើឈ្មោះ យាយញ៉ៅ ហ្នឹងជាអ្នកណាគេដែរ?

**ធ៖** បាទ យាយញ៉ៅ គាត់ជាអ្នកចុងភៅ គាត់អ្នកខាងដាំបាយឲ្យអ្នកខាងអ្នកទោស។

**ស៖** ចុះលោកស្គាល់ឈ្មោះពេញគាត់ទេ ទាំងត្រកូល ហើយនិងឈ្មោះគាត់ហ្នឹង ឈ្មោះឥឡូវ ហ្នឹង?

[០៩:២៩:២៣]

**ធ៖** បាទខ្ញុំអត់ស្គាល់ទេ ស្គាល់តែឈ្មោះគាត់នៅហ្នឹង នេះគេហៅថាពេញ បាទត្រកូលគាត់ខ្ញុំ អត់ដែលស្គាល់ផង។

**ស៖** ចុះ ខា – ឈ្មោះ ខា នេះ លោកថាជាកូនរបស់ យាយញ៉ៅ នោះ ត្រូវជីករណ្ដៅ ដើម្បីកប់ មនុស្សស្លាប់ជាមួយលោកនោះ លោកស្គាល់ឈ្មោះពេញគាត់ទេ ខា ហ្នឹង?

**ធ៖** បាទអត់ស្គាល់ទេ ស្គាល់តែ អាខា (កូនយាយញ៉ៅ) ដោយសារវាតូច អាហ្នឹងវានៅតូច ហើយវា -- ខ្ញុំវាងធំជាងវាបន្តិច។ ដល់ពេលដែលស្លាប់តាមផ្ទះអ៊ីចឹង តាមគុកអ៊ីចឹង តាចិនគាត់ឈឺ។ ដល់ពេលឈឺ ខ្ញុំហៅ អាខា ជួយ។ ថា “អាខា អ្ហែងជួយអញ!”។ អាខា វាទៅចេះតែកាន់ដៃពីក្រោយ ខ្ញុំ អូស ចាប់ជើងអូស ដោះខ្នោះអូស បានអាខា មួយវាជួយទាញដៃទាញអីទៅពីរនាក់ជាមួយវាហ្នឹង។ ប៉ុន វាក្មេង វាតូចជាងខ្ញុំទៅទៀត។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណ។ ឥឡូវនេះខ្ញុំសូមបង្ហាញឯកសារមួយជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី គឺឯកសារ

E3/4145។ ហើយលោកប្រធាន ខ្ញុំសុំការអនុញ្ញាតដើម្បីបញ្ចាំងឯកសារនេះនៅលើអេក្រង់ និងផ្តល់ឯកសារជាក្រដាសជូនសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[០៩:៣១:១៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ឥឡូវនេះយើងមើលទៅទំព័រទី១។ ជាភាសាខ្មែរ ERN 00068730, ជាភាសាបារាំង 00761093, ជាភាសាអង់គ្លេស 00762837។ នេះគឺជាតារាងមួយដែលមានឈ្មោះថា បញ្ជីឈ្មោះអ្នកទោសដែលត្រូវបានឃុំជាច្រើនខែច្រើនឆ្នាំ ហើយសូមការសម្រេចពីបក្ស។ តើលោកអាចប្រាប់បានទេថាលោកស្គាល់ឈ្មោះអ្នកទោសដែលជាប់ឃុំរនៅក្រាំងតាចាន់? ជាដំបូងខ្ញុំចង់ដឹងថា លោកស្គាល់ឈ្មោះមនុស្សទី១ គឺ អ៊ាត ចិន អាយុ៥១ឆ្នាំ ឃុំញ៉ែងញ៉ង។ គេដាក់ថា "គេចាប់ច្រឡំ"។ លោកបញ្ជាក់បានទេឈ្មោះហ្នឹង លោកស្គាល់ទេ អ៊ាត ចិន ហ្នឹង?

**លោក សយ សែន៖**

**ឆ៖** បាទស្គាល់។ មិនដឹងគាត់ជាមានទោសអីក៏ខ្ញុំអត់បានដឹងដែរ ប៉ុនក្រុមគាត់ហ្នឹងមកប្រាំមួយនាក់។ ប្រាំមួយនាក់ហ្នឹងគឺស្លាប់ទាំងអស់ វ៉ៃសួរចម្លើយស្លាប់ទាំងអស់។ នៅសល់តែ តាចិន មួយគាត់រស់នៅ សព្វថ្ងៃជាមួយខ្ញុំហ្នឹង។ ដល់មកចុងបញ្ចប់គាត់ទើបនឹងស្លាប់ពីថ្ងៃមុន។ ពីបញ្ហាដែលគម្រោងអក្សរនេះគឺ ខ្ញុំមិនអាចអានដាច់ទេ ព្រោះខ្ញុំអត់បានរៀនបានសូត្រទេ ពីសម័យនោះ។ ខ្ញុំដឹងថាជាប់គុកធំឡើងជាប់គុករហូតមកដល់សម័យនេះ ខ្ញុំអាចយល់បានខ្លះបន្តិចៗបាទ។

**ស៖** បាទ មិនអីទេ។ ឥឡូវនេះ ខ្ញុំនឹងអានបន្តទៀត។ អ៊ាត ចិន ហ្នឹងលោកថា ក្នុងចំណោមក្រុមប្រាំមួយនាក់ តើជាមនុស្សតែមួយដែលលោកហៅថា តាចិន ហ្នឹងអី? ដែលលោកជីករណ្តៅសម្រាប់កប់សាកសពជាមួយគាត់ហ្នឹង។ តើមនុស្សតែមួយមែនទេ អ៊ាត ចិន ហើយនិង តាចិន ហ្នឹង?

[០៩:៣៣:២៣]

**ឆ៖** បាទ មនុស្សតែមួយទេ។ នៅកន្លែងនោះគេហៅថាឪៗ ឪចិនៗ អ៊ីចឹងទៅ។ គូជាមួយយាយញ៉ ចុងភៅហ្នឹងព្រោះគាត់នៅជាប់នឹងឃុំរ គេចេះតែផ្គូថា "ឪចិន ហើយម៉ែញ៉ បើមិនកើតទេផ្សំផ្គុំគ្នានៅហ្នឹងឲ្យហើយ" អាហ្នឹងពាក្យនិយាយលេងទេបាទ។

**សៈ** ឈ្មោះទី២ នៅក្នុងបញ្ជីនេះគឺ ឈ្មោះ ហ៊ុន សេង អាយុ ៤៦ឆ្នាំមកពីភូមិស្រែគ្រូ ឃុំជាងទង ស្រុកត្រាំកក់។ ហើយបន្ទាប់មកទៀត មានស្ត្រីម្នាក់ឈ្មោះ មាស សារ៉ាត់ អាយុ ២៦ឆ្នាំ មកពីភូមិស្រែគ្រូ ឃុំជាងទងដូចគ្នា គេបានបញ្ជាក់ថា "នារីទាំងពីរនេះ ជាប្រពន្ធរបស់ឈ្មោះ គុន និងបឿន។ យើងកម្ទេចប្តី ពីព្រោះថា បំបះបំបោរគេឯងហ្នឹង ឲ្យទម្លាក់ប្រធានភូមិ"។ លោកស្គាល់ឈ្មោះទាំងពីរហ្នឹង ទេ គឺហ៊ុន សេង និង មាស សារ៉ាត់?

**ឆៈ** បាទ ស្គាល់។ ហ៊ុន សេង ហ្នឹងគាត់ជាប្តីយាយញ៉ូ។ ហើយបឿន នោះជាកូនប្រសាយាយញ៉ូ។ យាយញ៉ូ ហ្នឹងគាត់ម៉ែ អ៊ីរ៉ាត់ ហើយ អ៊ីរ៉ាត់ ជាកូនយាយញ៉ូដែរ។ ស្គាល់មួយគ្រួសារចៅកែតហ្នឹង ខ្ញុំស្គាល់ទាំងអស់។

**សៈ** លោកបានឆ្លើយថា អ៊ាត ចិន គឺថាត្រូវរៀបការ។ អ៊ីចឹងតើគាត់ហ្នឹងត្រូវរៀបការជាមួយនរណា? លោកនិយាយអំមិញថា អ៊ាត ចិន ហើយនិងយាយញ៉ូ ហ្នឹងថាទៅរៀបការយ៉ាងម៉េច? ហើយត្រូវរៀបការជាមួយអ្នកណា? ខ្ញុំដូចជាមិនសូវយល់។

**ឆៈ** បាទ ពាក្យហ្នឹងអត់ទេ។ ពាក្យហ្នឹងគេផ្តផ្គងគាត់លេងទេ។ កងទ័ពហ្នឹងចេះតែផ្ត កងទ័ពដែលការពារនៅក្រាំងតាចាន់ គេថា៖ "អ្នេ ឪចិន ហើយម៉ែញ៉ូ ថាមិនកើតទេរៀបចំផ្សំផ្គុំគ្នាហ្នឹងឲ្យហើយទៅមិនបាច់ទៅណាមកណា នៅហ្នឹងឲ្យហើយមួយគ្រួសារហ្នឹងតែម្តងទៅ"។ គ្រាន់តែគេនិយាយលេងទេ ការពិតគឺអត់ទេ។

[០៩:៣៦:០៦]

**សៈ** បាទ ឥឡូវនេះ ខ្ញុំចូលទៅទំព័រផ្សេងទៀត គឺចុះមកក្រោមរៀងឆ្ងាយបន្តិចដែរ គឺជាភាសាខ្មែរ គឺ 00068736, ជាភាសាបារាំង 00761100, ជាភាសាអង់គ្លេស 00762844។ នេះគឺជាតារាងដដែល ដែលមានចំណងជើងថា "បញ្ជីឈ្មោះអ្នកទោសដែលឃុំនៅមន្ទីរម-១០៥ តាំងពីយូរណាស់មកហើយ ហើយដាក់ឲ្យបក្សសម្រេច"។ ក្នុងនេះគឺមានឈ្មោះ យុត សែន។ ខ្ញុំគិតថា អ្នកបកប្រែមានឯកសារជា -- នៅចំពោះមុខហើយ។ ឈ្មោះនេះគឺ យុត សែន មកពីភូមិត្រពាំងលាន ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ មុខងារកសិករ។ មានចំណារពាក់ព័ន្ធនឹងឈ្មោះ យុត សែន នេះ ដែលដាក់ថា នៅឆ្នាំ៧៤ មនុស្សនេះជាយុវជនឲ្យនៅសមរភូមិមុខ តែរត់មកផ្ទះវិញ។ លោកស្គាល់ឈ្មោះ យុត សែន នេះទេ?

**ឆៈ** បាទ ស្គាល់។ យុត សែន – ខ្ញុំបាទផ្ទាល់តែម្តង។ អត់ទេ គេឲ្យខ្ញុំទៅនៅកន្លែងកងឈ្លប។

នៅកន្លែងកងឈ្លបហ្នឹង នៅ -- ខ្ញុំអត់នៅ ខ្ញុំរត់មកផ្ទះ ដល់រត់មកផ្ទះហ្នឹង អាហ្នឹងបានគេបញ្ជូនមកអង្គការនៅ រត់មកផ្ទះយូរហើយ មិនមែនទើបនឹងមកថ្ងៃហ្នឹង គេមកចាប់ថ្ងៃហ្នឹងអត់ទេ។ មកផ្ទះប្រកបអាជីវកម្មអី កាប់អូស កាប់អីលក់ បររទេះដឹកអូសដឹកអីលក់ យកមកលក់បាន កាលជំនាន់ហ្នឹងគេនៅចាយលុយៗ ដឹកមកលក់ឱ្យចិនភៀសខ្លួនចេញពីតាកែវ ពីអង្គតាសោម គាត់ទៅនៅតាមៗជនបទហ្នឹង គាត់ធ្វើគុយទាវធ្វើអីលក់ ខ្ញុំទៅកាប់អូសលក់ឱ្យគាត់ហ្នឹង។ ខ្ញុំហ្នឹងតែម្តង គឺ ឃុត សែន។ បាទ ខ្ញុំដាក់ឈ្មោះ ឃុត សែន ហ្នឹង ដោយសារខ្ញុំមិនដាក់ សយ សែន ហ្នឹង កុំឱ្យគេថា ខ្ញុំហ្នឹងកូនតា សុខ សយ។ ដាក់ ឃុត សែន ម្តង។ បន្តិំឈ្មោះហ្នឹង យាយៗគាត់អ្នកដាក់ឱ្យបាទ។

[០៩:៣៨:៣៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំបញ្ជាក់បន្តិចនៅក្នុងឯកសារ F3/4 -- /4145 ឈ្មោះដែលគេសរសេរនុ៎ងមិនមែន យុត សែន ទេ គឺឃុត សែន ក៏ប៉ុន្តែដោយសារការសេរមានលក្ខណៈស្រដៀងគ្នាអាចការបកប្រែទៅជា យុត សែន។ តាមការពិតគឺ ឃុត សែន។ សូមអរគុណលោកប្រធាន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណចំពោះការឆ្លើយបញ្ជាក់ ដូច្នេះប្រហែលជាកុំហុសនៃការបកប្រែជាភាសាបារាំងហើយ ដែលយើងមើលឃើញបែបនេះនោះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ហើយមានឈ្មោះ ពីរផ្សេងទៀត ដែលខ្ញុំចង់អានជូនលោក គឺឈ្មោះ ហ៊ុន ញ៉ វ និងឈ្មោះ មាស វ៉ាត់ ដែលមាននៅក្នុងបញ្ជីនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សហការីពីខាងដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំពីឈ្មោះ សូមមេត្តានិយាយឈ្មោះនេះឡើងវិញម្តងទៀត ដើម្បីឱ្យខ្ញុំអាចស្តាប់ឈ្មោះ នេះបាន។

**លោក ពេជ អង្គ៖**

បាទ ឯកសារដែលសហព្រះរាជអាជ្ញាបានលើកនោះ គឺលោកសហព្រះរាជអាជ្ញាបានអានតាមការបកប្រែជាភាសាបារាំង គឺ យុត សែន។ តែឯកសារដើមដែលជាភាសាខ្មែរ សរសេរ ឃុត សែន។ ដោយសារថា អក្សរ "ឃ" និង "យ" មានលក្ខណៈស្រដៀងខ្លាំងមែនទែន ហើយអាចការបកប្រែ គាត់យល់ថាជាអក្សរ "យ"។ ដូច្នេះគាត់សរសេរ យុត សែន។ បើពិនិត្យមើលឲ្យច្បាស់លាស់មែនទែន យើងពង្រីកអក្សរហ្នឹង គឺអក្សរ "ឃ" – ឃុត សែន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តបាទ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានសូមការអនុញ្ញាតខាងភាសាអង់គ្លេសថាសាក្សីនិយាយភាសាខ្មែរញាប់ពេក។ អ៊ីចឹង បកពីខ្មែរទៅអង់គ្លេស អាចបាត់ច្រើន។ លោកប្រធាន សូមបន្តល្បឿនបន្តិច។

[០៩:៤១:១២]

**ប្រធានអង្គជំនុំ៖**

លោក សយ សែន សូមដល់ពេលលោកឆ្លើយ សូមលោកឆ្លើយឲ្យបានយឺត ជាងអ្វីដែលលោកបាននិយាយនេះ ព្រោះកាលដែលលោកនិយាយ ទាំងអស់គ្នាដែលយើងនិយាយនេះ សុទ្ធតែមានការបកប្រែទៅជាភាសាផ្សេងៗទៀត មាន ព្រោះយើងប្រើប្រាស់នៅក្នុង អ.វ.ត.ក នេះ បីភាសា។ ដូច្នេះដើម្បីឲ្យពាក្យពេចន៍ និងសម្ដីសំដៅរបស់លោកដែលបាននិយាយឡើងហ្នឹង គឺត្រឹមត្រូវ មានការបកប្រែច្បាស់លាស់ ហើយនិងមានការកត់ត្រាត្រឹមត្រូវ។ សូមលោកនិយាយឲ្យយឺតៗ។ លោក យល់ទេ លោក សយ សែន?

**លោក សយ សែន៖**

បាទ យល់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្ត។ លោកតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយឌ័ ដេស្មាឯល៖**

**ស៖** ដូច្នេះ យើងពិនិត្យមើលបញ្ជីអ្នកទោសនៅម-២១ ដែលជាប់រាប់ឆ្នាំមកហើយនេះ។ ក្រៅពីឈ្មោះរបស់លោកនោះ មានឈ្មោះ ហ៊ុន ញ៉ និងមានឈ្មោះ មាស វ៉ាត់។ តើឈ្មោះ ហ៊ុន ញ៉ និងមាស វ៉ាត់ នេះ គឺជាឈ្មោះដដែល ដែលមាននៅក្នុងឯកសារទី១អម្បាញ់មិញនេះ ដែលថាលោកហៅថា យាយ ញ៉ ហើយនិង មាស សាវ៉ាត់។ អ៊ីចឹងអ្នកទាំងពីរហ្នឹងជាមនុស្សដដែលទេ ឬក៏ជាអ្នកផ្សេង?

**លោក សយ សែន៖**

**ឆ៖** បាទ ជាមនុស្សដដែល ពីរនាក់ហ្នឹង – ម៉ែនិងកូន។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងឯកសារនេះ នៅក្នុងចំណងជើងនោះ គេដាក់ថា "បញ្ជីអ្នកទោសម-១០៥"។ តើនៅសម័យនោះ លោកធ្លាប់ឮឈ្មោះ ម-១០៥ ហ្នឹងទេ? ហើយពាក្យថា "ម-១០៥" នេះ មានន័យថាម៉េចដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ ដឹងថាគេហៅថា ស្រុក១០៥។ អត់ដឹងថា ម-១០៥ អត់ដែលដឹងគេនិយាយផង។ ដឹងតែស្រុក១០៥។

[០៩:៤៣:៣៥]

**ស៖** បាទ ម្សិលមិញ លោកបាននិយាយពីប្រជាជន១៧មេសា ហើយនិងប្រជាជនរបស់លន់ នល់ –ពួកលន់នល់– ដែលត្រូវគេចាត់ទុកថាជាអ្នកទោស ឬក៏ជាឈ្លើយសឹក។ តើលោកអាចជម្រាបបានទេ ថាអ្នកណាគេអ្នកប្រើពាក្យថា "អ្នកទោស ឬក៏ឈ្លើយសឹក" នៅមន្ទីរសន្តិសុខក្រាំងតាចាន់នោះ?

**ឆ៖** បាទ ឆ្លើយបាន។ កងទ័ព ហើយនិងប្រធានគុកនៅហ្នឹង គាត់ឆ្លើយអ៊ីចឹង។ សុទ្ធតែពួកឈ្លើយសឹក គាត់ហៅ "ពួកឈ្លើយសឹក" អ៊ីចឹង។

**ស៖** លោកអាចបញ្ជាក់បានទេ ថាតើពាក្យហ្នឹង ឈ្លើយសឹកហ្នឹង សំដៅទៅលើពួកប្រជាជនថ្មី ឬក៏សំដៅលើតែអតីតយោធា ទាហានលន់ នល់ ទេ?

**ឆ៖** បាទ បើនិយាយឲ្យខ្លីមក វាថាសរុបមកឲ្យតែអ្នកទោស គេហៅ "ឈ្លើយសឹក"ទាំងអស់។

**ស៖** បាទសូមអរគុណ។ នៅចំពោះមុខតុលាការនេះ មានឈ្មោះអ្នកផ្សេងទៀត ដូចជាសក្ខីកម្មរបស់លោក មាស សុខា នោះ។ គាត់បាននិយាយនៅទីនេះថ្ងៃទី២១-២២ ខែមករា អំពីក្រុមមនុស្សម្នាក់ក្រុមមនុស្សដែលមានពី ១០០ ទៅ ១៣០នាក់ ដែលនាំមកពីឃុំពីរមកមន្ទីរក្រាំងតាចាន់ រួចគាត់និយាយកាលនោះដូចជាស្រែរនោង ហើយនិងញ៉ែងញ៉ង។ ខ្ញុំសូមដកស្រង់អ្វីដែលគាត់បាននិយាយឡើងគឺឯកសារ

E1/249.1 ថ្ងៃទី២១ មករា ឆ្នាំ២០១៥ ប្រហែលជាម៉ោងដប់ពីរថ្ងៃត្រង់។ ខ្ញុំសូមដកស្រង់គាត់ "មានៗ ប្រហែលជា១៣០នាក់ ហើយ១៣០នាក់នេះត្រូវបាននាំទៅមន្ទីរសន្តិសុខក្រាំងតាចាន់" ហើយបើឆ្ងាយជាងហ្នឹងបន្តិចទៀត គាត់និយាយថា "អ្នកទាំងអស់នោះមិនត្រូវបានគេសួរចម្លើយនោះទេ"។ ថ្ងៃបន្ទាប់មកទៀតលោក មាស សុខា ដដែលបាននិយាយថានៅប្រតិចារិក គឺ E1/250.1 ប្រហែលជាម៉ោង ១០:៥១នាទី "ថ្ងៃនោះប្រហែលជាអ្នកទោសជាង១០០នាក់ត្រូវបានសម្លាប់ ហើយខ្ញុំមិនដឹងតួលេខជាក់លាក់ទេ"។ នៅម៉ោង ១០:៥៦:១៦, "ខ្ញុំឃើញក្រោយមកទៀតហ្នឹងអ្នកទោសត្រូវបានសម្លាប់ហើយខ្ញុំបានកប់សាកសពទៀតផង"។ តើលោកចាំក្រុមអ្នកដែលថាមានចំនួនប្រហែលជា១០០ ទៅ ១៣០នាក់ អ្នកទោសនេះដែលមិនត្រូវបានគេចោទសំណួរសួរចម្លើយទេ ក៏ប៉ុន្តែត្រូវបានគេសម្លាប់នៅក្រាំងតាចាន់តែម្តង អ្នកទោស ១០០ ទៅ១៣០នាក់។ លោកដឹងទេ?

[០៩:៤៦:៤៨]

**ឆ៖** បាទដឹង។ ប៉ុន្តែខ្ញុំក៏មិនបានរាប់ដែរ ប៉ុន្តែស្មានទៅទេអាហ្នឹងនោះ វាស្មើនឹងខ្ទង់១០០ជាងអារឿងរាប់មិនបានរាប់ទេអាហ្នឹងវាឆ្នាំ៧៧ ហ្នឹងដឹងបាទ។

**សៈ** អ្នកទោសហ្នឹងទាំង១០០នាក់ អ្នកទោសជាង១០០នាក់ហ្នឹងមកដល់មន្ទីរក្រាំងតាចាន់តែម្តងទេ ឬក៏មកជាច្រើនដំណាក់?

**ឆ៖** មិនអាចរាប់បានទេ វាចូលច្រើនដំណាក់ដូចខ្ញុំប្រសាសន៍ពីម្សិលមិញមកអ៊ីចឹងថា ចូលតាមថ្នាក់ វាភាគច្រើនវាមកពីខាងព្រះសីហនុ និងញ៉ែងញ៉ង ពិតប្រាកដដូចវានិយាយត្រឹមត្រូវហើយ អាខា។

**សៈ** បាទឥឡូវនេះខ្ញុំសូមចូលទៅនិយាយអំពីអ្វីដែលលោកបានលើកឡើងកាលពីម្សិលមិញ។ អង្កាល់នោះលោកបាននិយាយថានៅឆ្នាំ១៩៧៧ មានមនុស្សចូលមកជាច្រើន ហើយត្រូវបានគេសម្លាប់នៅមន្ទីរក្រាំងតាចាន់នៅពេលដែលវៀតណាមវាយបានប្រហារលើប្រទេសកម្ពុជា? នៅពេលមានការវាយប្រហារពីសំណាក់ប្រទេសវៀតណាមនេះ តើមានខ្មែរក្រោម ឬក៏វៀតណាមចូលមកមន្ទីរសន្តិសុខក្រាំងតាចាន់ច្រើនទេ?

[០៩:៤៨:២៧]

**ឆ៖** បាទជំនាន់ហ្នឹងខ្ញុំអត់បានដឹងពីសាសន៍ណាៗក៏មិនបានដឹងដែរ ប៉ុន្តែបើតាមពិនិត្យនិងតាមដានមើលបែបមានច្រើនៗតែជនជាតិចាមទេ ច្រើនតែជនជាតិចាម បើថាក្រៅពីហ្នឹងខ្ញុំមិនសូវដែលឃើញទេ បើចាមអាហ្នឹងអាចស្គាល់ដោយសារគាត់ថាខ្ញុំអត់ហូបសាច់ជ្រូកទេពីមុន ហើយគាត់បាន

E1/257.1

ប្រាប់អ៊ីចឹងបានដឹងថាគាត់ជាជនជាតិចាមបាទ។

**សៈ** បាទខ្ញុំនិយាយពីខ្មែរក្រោមទេបាទ គឺថាខ្មែរដែលមកពីកម្ពុជាក្រោម តើលោកមានបានសម្គាល់អ្នកទោសមួយចំនួនដែលថាមើលទៅឃើញថាគាត់មាននិយាយប៉ៃឡាំទៅ ដឹងថាគាត់ជាខ្មែរក្រោមមកពីប្រទេសវៀតណាម លោកមានកត់សម្គាល់ឃើញអ៊ីចឹងទេ ចំណាំមើលកាលហ្នឹង?

**ឆៈ** បាទ អត់ទេ ខ្ញុំអត់ដែលសម្គាល់មើលទេ អត់ដែលនឹកឃើញទៅសម្គាល់អ៊ីចឹងទេ។

[០៩:៤៩:៤៤]

**សៈ** បាទ ឥឡូវនេះខ្ញុំសូមដកស្រង់នៃចម្លើយមួយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយដើម្បីរំឭកលោកអំពីអ្វីដែលលោកបានលើកឡើងគឺឯកសារ E319.1.24 ខ្ញុំមិនផ្តល់លេខ ERN ទេ។ នេះជាចម្លើយរបស់លោក។ អ៊ីចឹង ខ្ញុំកត់លេខចម្លើយលេខ៨២ ទៅដល់ចម្លើយ៩១។ ខ្ញុំសុំអានអ្វីដែលលោកបានឆ្លើយចំពោះមុខសហចៅក្រមស៊ើបអង្កេត សុំដកស្រង់ចម្លើយ៨២៖ "ខ្មែរកម្ពុជាក្រោមបានមកដល់ឆ្នាំ១៩៧៥"។ ហើយចម្លើយ៨៣៖ "គេមកបន្តិចម្តងៗរហូតដល់ឆ្នាំ១៩៧៨។ ខ្មែរកម្ពុជាក្រោមមិនត្រូវបានឃុំខ្លួនយូរនោះទេ ប៉ុន្តែប្រហែលជាបួនដប់ថ្ងៃ -- បីបួនថ្ងៃ ត្រូវបានគេសម្លាប់ហើយទៅយកម្តងបីបួននាក់"។ "សៈ តើនៅឆ្នាំណាដែលគេបញ្ជូនខ្មែរក្រោមមកក្រាំងតាចាន់ច្រើនជាងគេ?" ចម្លើយ៨៤បន្តមកទៀត៖ "នៅឆ្នាំ១៩៧៧ គឺឆ្នាំដែលវៀតណាមវាយប្រហារចូលមកលើប្រទេសខ្មែរ គឺនៅពេលនោះហើយដែលគេបញ្ជូនខ្មែរក្រោមមកគុកក្រាំងតាចាន់ច្រើន។ នៅពេលនោះ គេហៅខ្មែរក្រោមថា ជនជាតិយួន"។ ចម្លើយ៨៥៖ "គឺខ្មែរក្រហមដែលនិយាយថា ខ្មែរក្រោមហ្នឹងជាយួន ហើយនៅឆ្នាំ១៩៧៧ វៀតណាមព្យាយាមវាយចូលប្រទេសកម្ពុជា ប៉ុន្តែខ្មែរក្រហមបានវាយបកទៅវិញ" "សៈ ក្រោយឆ្នាំ១៩៧៥ តើលោកធ្លាប់ឮអ្នកយាម ឬក៏អ្នកគុកនិយាយអំពីខ្មែរក្រោមដែរឬទេ? ចម្លើយ៨៦៖ បាទ ខ្ញុំឮ ប៉ុន្តែពួកគេហៅខ្មែរក្រោមទាំងនេះថា យួន ព្រោះពួកខ្មែរក្រោមនេះគេរស់នៅវៀត-ណាម ហើយចេះភាសាវៀតណាម។ សៈ តើពួកគេនិយាយអំពីគោលនយោបាយសម្លាប់ខ្មែរកម្ពុជាក្រោមដែរឬទេ? ចម្លើយ៨៧៖ អត់ទេ គឺឲ្យតែខ្មែរក្រហមទៅដល់គឺសម្លាប់តែម្តង"។ ចម្លើយ៨៩៖ "ពីព្រោះខ្មែរក្រហមនិយាយថា ពួកគេជាយួន ហើយនិយាយខ្មែររដឹនៗ"។ ចម្លើយ៩០៖ "បាទ ខ្ញុំឮពេលនោះ ពួកគេជាប់គុកជាមួយខ្ញុំ គេនិយាយខ្មែរមិនច្បាស់នោះទេ។ ហើយជាប់គុកបានតែមួយ ឬពីរយប់តែប៉ុណ្ណោះ។ ខ្ញុំឃើញដោយផ្ទាល់នូវការសម្លាប់ខ្មែរក្រោមម្តង ឬពីរដងប៉ុណ្ណោះ ប៉ុន្តែគេសម្លាប់ខ្មែរក្រោមរាល់ថ្ងៃ"។ បាទ សុំបញ្ចប់ការដកស្រង់។

តើលោកមានចាំថា លោកបាននិយាយដូច្នេះទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នេះមិនមែនជាការជំទាស់ទេ ក៏ប៉ុន្តែស្នើសុំឲ្យធ្វើការបញ្ជាក់ ខ្ញុំពេញចិត្តតែចំពោះការបកប្រែពីសំណាក់អ្នកបកប្រែ ប៉ុន្តែ បើយើងអានឯកសារនេះទៅមានការប្រើប្រាស់ពាក្យពេចន៍ផ្សេងគ្នា។ ប៉ុន្តែនៅក្នុងការបកប្រែនៅចម្លើយរបស់គាត់នេះ ខ្ញុំឃើញថាមានការប្រើពាក្យច្រើនសម្រាប់ប្រជាជនវៀតណាម ថាតើយើងដកស្រង់ពាក្យពេចន៍របស់គាត់ត្រង់ៗតែម្តង ឬក៏ចៀសវាងមិនដកស្រង់ដោយប្រើប្រាស់ពាក្យពេចន៍ត្រង់ៗនោះទេ?

[០៩:៥៣:៤៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន ទាក់ទងនឹងឯកសារមួយនេះ ជាក់លាក់នេះ គឺវាច្បាស់ណាស់ទៅហើយ អ្នកបកប្រែត្រូវតែបកប្រែប្រដេញ អ៊ីចឹងគឺថាជារឿងធម្មតាទេ ដែលថាមានខុសគ្នាបន្តិចបន្តួចរវាងឯកសារជាលាយលក្ខណ៍អក្សរ ហើយនិងការបកប្រែផ្ទាល់មាត់ ហើយខ្ញុំអាននេះ ខ្ញុំអាននូវចម្លើយរបស់គាត់ជាលាយលក្ខណ៍អក្សរ។ អ៊ីចឹង ខ្ញុំមិនអាចនិយាយឲ្យលើសពីហ្នឹងទេ លោកប្រធាន។

បើអ៊ីចឹង ខ្ញុំអានទៅឃើញថាលោកបាននិយាយ --

**លោក វ៉ិចទ័រ កូប៉េ៖**

សុំអធ្យាស្រ័យ ខ្ញុំមានការបកប្រែជាភាសាអង់គ្លេសផ្សេងគ្នា។ បើយើងប្រើពាក្យថា "ប្រជាជនវៀតណាម" ខ្ញុំបកមកជាភាសាអង់គ្លេស ខ្ញុំស្តាប់ឮសូរខុសគ្នា។ ដូច្នេះខ្ញុំចង់ថាតើយើងគេច ឬក៏ថាយើងចៀសវាងមិនប្រើពាក្យនេះត្រង់ៗ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ យ៉ាងម៉េចទៅ ឯកសារ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមិនបានផ្ទៀងផ្ទាត់ថាតើពាក្យដែលគេប្រើជាភាសាអង់គ្លេសនោះទេ ព្រោះខ្ញុំប្រើតែជាភាសាបារាំង លោកប្រធាន សំណៅជាភាសាបារាំង។

បាទ កាលដែលខ្ញុំផ្ទៀងផ្ទាត់ឃើញថា ជាភាសាអង់គ្លេសនេះគេប្រើពាក្យ "យួន" ដែលនៅក្នុងភាសាបារាំងនោះ សំណៅជាភាសាបារាំងគេប្រើពាក្យថា "វៀតណាម"។ ខ្ញុំមិនគិតថា គ្រាន់តែប្រើពាក្យយួន និងវៀតណាមនេះដូចជាមិនមានផលប៉ះពាល់អីលើការចោទសំណួររបស់ខ្ញុំទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បន្តទៀត បញ្ហានេះ ពាក្យនេះ តែអាចមានន័យតែមួយទេណេះ។ កាលណាអាស្រ័យទៅលើអ្នកប្រើប្រាស់ទេ ព្រោះដូចខ្មែរនិងកម្ពុជាអ៊ីចឹង មិនខុសគ្នាទេ។

[០៩:៥៦:០៦]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើវគ្គដែលខ្ញុំបានអានអម្បាញ់មិញនេះ ចម្លើយរបស់លោកដែលលោកផ្ដល់ទៅសហចៅក្រមស៊ើបអង្កេតនេះ ធ្វើឱ្យលោកចងចាំឡើងវិញទេ ទាក់ទងនឹងអ្វីដែលលោកបាននិយាយទាក់ទងទៅនឹងខ្មែរក្រោម ឬក៏វៀតណាម ឬក៏យួននេះ។

**លោក សយ សែន៖**

**ឆ៖** បាទ ខ្ញុំដែលសម្ភាសជាមួយអ្នកកាសែតខ្លះដែរពីបញ្ហាហ្នឹង ប៉ុន្តែខ្ញុំអត់ដឹងថា ខ្មែរកម្ពុជាក្រោមទេ ដឹងតែយួន នៅនោះគេដឹងតែយួន បើនិយាយប៉ែឡាំគេដឹងតែយួនហើយហ្នឹងឆ្នាំ៧៧។

**ស៖** តើអ្នកដែលៗនិយាយមិនសូវច្បាស់ ឬក៏និយាយមិនសូវល្អហ្នឹង គេថា ពួកគេហ្នឹងជា យួន ហើយពួកគេហ្នឹងត្រូវបានសួរចម្លើយហើយបានយកទៅសម្លាប់ ឬក៏យកទៅសម្លាប់ទាំងមិនទាន់បានសួរចម្លើយផង?

**ឆ៖** បាទ ឆ្នាំ៧៧ហ្នឹង ខ្ញុំបានប្រាប់ដូចជាដដែលៗ ថាវា ជួនកាលមកច្រើនណាស់អត់បានសួរចម្លើយទេក្នុងប្រទង់ប្រទាញគ្នា កើតសង្គ្រាមនៅតាមព្រំដែន អត់បានប្រទង់ប្រទាញ អត់បានសួរអត់បានអីទេ មកដល់គឺ គាត់មកដល់ ជួនកាលបើច្រើនពេកបញ្ចូលគុកខ្លះ គាត់យកទៅខ្លះ បណ្ដើរៗអ៊ីចឹង។

[០៩:៥៨:០៤]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមចូលទៅប្រធានបទមួយទៀតទាក់ទងទៅនឹងការទំនាក់ទំនងរវាងមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយនិងស្រុក១០៥។ បាទ ខ្ញុំសូមដកស្រង់ចម្លើយរបស់លោកមួយគឺឯកសារ E3/5214, ERN ជាភាសាខ្មែរគឺ 00223068, ជាភាសាបារាំងគឺ 00702899, ជាភាសាអង់គ្លេសគឺ 00225511។ លោកបាននិយាយដូចតទៅនេះ៖ "ខ្ញុំគ្រាន់តែដឹងថា នៅពេលដែល

នីរសាររបស់មន្ទីរក្រាំងតាចាន់បានយកសំបុត្រពីស្រុកមកឲ្យប្រធានមន្ទីរក្រាំងតាចាន់នេះ មានអក្សរក្រហមនៅលើខ្នងសំបុត្រ។ កាលណាយកមកដល់ពេលល្ងាច ស្អែកឡើងសម្លាប់អ្នកទោសគឺមានធ្វើហើយ។ រឿងនេះ ទ័ពឈ្មោះ ស៊ឹម គាត់ធ្លាប់និយាយអំពីរឿងនេះប្រាប់ខ្ញុំដែរ។ ក្រោយពីបានឃើញសំបុត្រនេះហើយគាត់តែងតែរអ៊ូប្រាប់ខ្ញុំថា ស្អែកឡើងនឹងមានការងារធ្វើទៀតហើយ។ នីរសាររបស់មន្ទីរក្រាំងតាចាន់ដែលមានឈ្មោះ សាក់ សារិន ហើយនិងឈ្មោះ អឿន"។

បាទ តើនៅក្រាំងតាចាន់ហ្នឹង អ្នកណាជាអ្នកយក -- នាំសារមក រវាងមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយនិងស្រុក១០៥ នៅមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥? អ្នកណាជាអ្នកនាំសារ?

**ឆ៖** បាទនីរសារគាត់ឈ្មោះ -- កាលពីមុនខ្ញុំមិនស្គាល់នាមត្រកូលរបស់គាត់ទេ ស្គាល់តែ រិន។ រិន ហ្នឹង ហើយ អឿន តែពីរនាក់ហ្នឹងទេ បាទ។ គាត់អ្នករត់សារ គេហៅនីរសារៗ។

**សៈ** អ្នកណាជា -- ធ្វើនីរសារក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩?

**ឆ៖** បាទអ្នកហ្នឹង ស៊ាន់ ។ បាទខ្ញុំអត់ស្គាល់នាមត្រកូលទេគាត់ ស្គាល់តែ ស៊ាន់។

**សៈ** តើលោកមានធ្លាប់ឃើញ នីរសារស្រុកមកមន្ទីរសន្តិសុខក្រាំងតាចាន់ទេ ឬក៏រាល់ដងនីរសារមន្ទីរសន្តិសុខក្រាំងតាចាន់ ទៅស្រុក?

**ឆ៖** អត់ដែល ឃើញតែគណៈស្រុក ជំនាន់នុងគេហៅគណៈស្រុក ដែលឃើញតែគាត់ ហើយនីរសារគាត់មួយមកជាមួយគណៈស្រុកហ្នឹង គាត់មានហុងដា គេហៅហុងដាមួយ ដៃច្រងាង។ ពីដើមមានអាហ្នឹងជិះមួយៗ និរសារគាត់ហ្នឹង មកញឹកញាប់ដែរ គាត់មកញឹកញាប់។

[១០:០១:៤៧]

**សៈ** តើលោកធ្លាប់ឃើញគណៈស្រុក គាត់យកសំបុត្រមកមន្ទីរសន្តិសុខក្រាំងតាចាន់ទេ? គណៈស្រុក ឬក៏ចៅហ្វាយស្រុក?

**ឆ៖** បាទអត់ដែលឃើញគណៈស្រុកគាត់យកសំបុត្រមកខ្លួនឯង មានតែនិរសារ។ គណៈស្រុកគាត់មក មាននិរសារបើកម៉ូតូពីមុខ បាទគាត់ជិះពីក្រោយគាត់ – និរសារៗនៅពីមុខ បាទ។

**សៈ** ហើយនិរសារពេលដែលមកមន្ទីរហ្នឹង គាត់មកយកសំបុត្រមក?

**ឆ៖** និរសារគាត់យកសំបុត្រមកដាក់នៅមន្ទីរក្រាំងតាចាន់ ហ្នឹង ដាក់ឲ្យលោកប្រធាន។ នៅ -- គាត់មកដល់ គាត់អង្គុយនៅកន្លែងប្រធាន ប្រធាន នៅកន្លែងប្រធានហើយនៅជាប់កន្លែងចង្ក្រានបាយអ្នកទោស ជិតកន្លែងចង្ក្រានបាយអ្នកទោស – កន្លែងប្រធាន។

**ស៖** បាទឥឡូវខ្ញុំសូមដក់ស្រង់កំណត់ហេតុស្តាប់ចម្លើយរបស់លោកមួយគឺឯកសារ E319.1 .24 ហើយចម្លើយ៩៩ លោកបានឆ្លើយថា៖ “ បាទ ខ្ញុំឃើញលិខិតចេញពីអង្គការលើ ថ្នាក់លើដោយដាក់ឈ្មោះអ្នកដែលត្រូវកម្ទេច ហើយខ្ញុំឃើញលិខិតនេះសឹងតែរាល់ថ្ងៃ ដែលសរសេរប៊ិកពណ៌ក្រហម។ ហើយចម្លើយលេខ១០០៖ “ខ្ញុំឃើញលិខិតនេះ ដោយនិរសារកាន់នឹងដៃ ហើយ ឌុច ក៏ជាអ្នកវាយរបាយការណ៍។ ចម្លើយ១០១៖ “ ឌុច វាយរបាយការណ៍អំពីឈ្មោះអ្នកដែលត្រូវបានកម្ទេចហើយ”។ “លោកបាននិយាយពីនិរសារ តើលោកចង់សំដៅទៅលើឈ្មោះ ស៊ាន់ មែនទេ? ចម្លើយលេខ១០២៖ “បាទ”។ នៅក្នុងសម្រង់នេះលោកបាននិយាយថា ទាក់ទងទៅនឹងរបាយការណ៍ដែលវាយអង្គលីលេខដោយ ឌុច គាត់ធ្វើរបាយការណ៍ទៅលើអ្នកដែលត្រូវបានកម្ទេចហើយ។ ដោយយើងដឹងហើយថា លោកមិនចេះអានអក្សរទេ តើលោកមានបានដឹងថា ឌុច ធ្វើរបាយការណ៍លើអ្នកដែលគេសួរចម្លើយ ហើយដែលគេមិនទាន់យកទៅសម្លាប់ទេ? លោកមានដឹងថា ឌុច ធ្វើរបាយការណ៍ទៅលើអ្នកដែលគេសួរ ទើបតែសួរចម្លើយទេ?

**ឆ៖** បាទកន្លែងហ្នឹងខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំអត់ប៊ានសួរគាត់ទេ។

**ស៖** នៅពេលដែល ស៊ាន់ យកសំបុត្រ ពីស្រុកមកមន្ទីរសន្តិសុខក្រាំងតាចាន់ តើគាត់យកមកឲ្យអ្នកណា? យកមកឲ្យផ្ទាច់មុខ តើមានបុគ្គលណាម្នាក់ដែលថាគាត់ឲ្យតែពេលយកសំបុត្រមកពីស្រុក គាត់យកទៅឲ្យតែបុគ្គលម្នាក់នោះទេ?

[១០:០៥:២៤]

**ឆ៖** តាមដែលខ្ញុំសម្គាល់មើល គាត់បីនាក់ហ្នឹង គាត់មកជួបអ្នកណា គាត់ឲ្យអ្នកហ្នឹង មកជួបប្រធានឲ្យប្រធាន ជួបអនុប្រធានឲ្យអនុប្រធាន ជួបសមាជិកឲ្យសមាជិក អត់កំណត់។

**ស៖** ហើយបន្ទាប់មកទៀត បុគ្គលិកមន្ទីរហ្នឹង ក្រោយពីពេលទទួលសំបុត្រហើយនិងតើមានការចេញបញ្ជាឲ្យធ្វើអីទេ?

**ឆ៖** ឃើញសព្វមួយដងកាលណាផែនការប្រញាប់ បានគាត់ទទួលសំបុត្រហើយគាត់ចាត់ចែងកម្លាំងកងទ័ពគាត់។ ហើយបើដូចថាយូរទៅមានមួយៗ គាត់ ទំនងថាសំបុត្រមកថ្ងៃហ្នឹងអ៊ីចឹង គាត់ចាត់ចែងស្អែកបានចាត់ចែង បាទ។

**ស៖** ពេលលោកនិយាយថា ក្រោយមកទៅធ្វើបន្តទៀត លោកចង់សំដៅថាយ៉ាងម៉េច? ថា យោធាហ្នឹង ទ័ពទាំងអស់ហ្នឹងគេត្រូវធ្វើយ៉ាងម៉េច?

**ឆ៖** កាលណា គេត្រូវដាក់ការខ្នងសំបុត្រ វាមានប៊ិកក្រហម ខ្ញុំអត់ចេះអក្សរ ប៉ុនខ្ញុំចូលបោសសំរាមកន្លែង ឌុច ចុចអង្គុលីលេខ ខ្ញុំមកអឺតមើលៗ ឃើញការខ្នង ដាក់ប៊ិកក្រហម គេដាក់ "កម្ទេច"។ កាលណាគេដាក់កម្ទេចអ៊ីចឹង ឧទាហរណ៍ថា ផែនការគាត់ប្រញ៊ីកខ្លាំងបានអាចកម្ទេចថ្ងៃហ្នឹង បើអត់ទេស្អែកឡើងបានអាចចាប់ផ្តើមវិធានការកម្ទេច ធ្វើមិនឲ្យអ្នកទោសក្នុងហ្នឹងបានដឹងទេបាទ មិនឲ្យអ្នកទោស និងអ្នកលែងចេញក្រៅហ្នឹងក៏មិនដឹងសភាពការណ៍យ៉ាងម៉េចៗ អត់ឲ្យដឹងទេ គាត់ធ្វើធម្មតាដូចអត់ដឹង។

**ស៖** បាទ ខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងការធ្វើទារុណកម្មទៅលើអ្នកទោសពេលសួរចម្លើយក្រោយខែមេសា ឆ្នាំ១៩៧៥ មិនមែនការសួរចម្លើយដែលលោកបានទទួលរងនោះទេ ក៏ប៉ុន្តែការសួរចម្លើយដែលអ្នកទោសផ្សេងទៀតទទួលរង។ បើតាមអ្វីដែលលោកបានសង្កេតឃើញ ឬក៏បានដឹងឮនៅនឹងកន្លែងផ្ទាល់ តើការសួរចម្លើយទាំងអស់នោះ មានគោលបំណងយ៉ាងដូចម្តេចដែរ?

**ឆ៖** កាលណាសួរចម្លើយ សួរដដែលៗ ដូចដែលខ្ញុំបានប្រាប់អ៊ីចឹង។ អត់មានសួរបញ្ហាអីខុសពីរឿងទាក់ទង គិញ សេ.អ៊ី.អា របស់លន់នល់ គិញ សេ.អ៊ី.អា របស់ដៃជើងរបស់ ព្រំ សាន។ មានតែប៉ុណ្ណឹងមិនដែលខុសពីហ្នឹងទេ សួរ។

[១០:០៨:៣០]

**ស៖** តើលោកមានធ្លាប់ឮសំណួរដែលគេសួរនៅពេលដែលគេសួរចម្លើយហ្នឹងដែរឬទេ?

**ឆ៖** បាទ កាលខ្ញុំទៅបោសសំរាមជិតហ្នឹងទៅ ឮសួរ គេឲ្យទៅធ្វើការបោសសំរាមជិតៗ កន្លែងហ្នឹង ទៅបានតែខ្ញុំទេ ទៅបោសសំរាមកន្លែងហ្នឹង គេឲ្យទៅតែម្នាក់។ អ៊ីចឹងឮសួរស្រែកសួរចម្លើយក្នុងកន្លែងការិយាល័យរបស់គាត់។

**ស៖** ខ្ញុំឮថាលោកបាននិយាយអំមិញនេះផងដែរ គឺថាពីមុនមានសំណួរមួយចំនួនគេសួរលើឋានៈរបស់អតីតយោធានៃរបបចាស់ហ្នឹង។ តើខ្ញុំស្តាប់នេះយល់ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ យល់ត្រឹមត្រូវហើយសំណួរ។

**ស៖** ពេលសួរចម្លើយបើតាមលោកសង្កេតឃើញនោះ តើគេធ្វើទារុណកម្មញឹកញាប់ដែរឬទេ? ឬក៏កម្រនឹងធ្វើ?

**ឆ៖** នេះ បើតាមខ្ញុំមើលទៅ មើលតែអ្នកណារាងចាស់វ័យ ដែលថាទាក់ទងមានខ្សែបណ្តាញនៅខាង លន់ នល់ ខាងទាហាន លន់ នល់ ខាងអីអ៊ីចឹងទៅ ខាង១៧អីអ៊ីចឹង អាហ្នឹងដូចទារុណកម្មគ្រប់

មនុស្សអ៊ីចឹងទាំងអស់។ បើថាខាងមូលដ្ឋាន១០មានតែពីរ ឬបីទេ ទារុណកម្ម។

**ស៖** ម្សិលមិញលោកបាននិយាយអំពីការធ្វើទារុណកម្មមួយចំនួនថា វ៉ៃនឹងដំបង ហើយនិងការប្រើថង់ផ្លាសស្ទិក។ ទាក់ទងទៅនឹងការវាយដំ តើការវាយដំនេះ គេវ៉ៃនឹងឧបករណ៍អីមួយ ឬក៏វ៉ៃនឹងដៃទេ វ៉ៃអ្នកទោសហ្នឹង?

**ឆ៖** បាទ វ៉ៃដំបងឫស្សី។ ឫស្សីប្រហែលជាប្រវែងប្រាំពីរតឹក ឬក៏ប្រាំមួយតឹក។ ឫស្សីប្រហែលប៉ុនៗករដៃបាទ។ គេកាត់ឫស្សីនៅកន្លែងហ្នឹង មានបីកង់ បួនកង់នៅពីក្រោយសួរចម្លើយនៅហ្នឹង។

**ស៖** តើលោកមានធ្លាប់ឃើញ ឬធ្លាប់ឮថា អ្នកទោសនោះត្រូវបានគេដកក្រចកនៅពេលគេសួរចម្លើយដែរឬទេ?

**ឆ៖** អត់បានឃើញទេ។ ដឹងតែដង្កាប់មួល បើថាស្ត្រីអ៊ីចឹង ខាងនារីហ្នឹង យកដង្កាប់ទៅមួលដោះ មួលអីគាត់ហ្នឹងបាទ។

[១០:១១:៥០]

**ស៖** តើការអនុវត្ត ការធ្វើទារុណកម្មនោះ នៅបន្តទៅរហូតពីឆ្នាំ -- ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមកដល់ទេ គឺថាធ្វើទារុណកម្មហ្នឹងរហូតដោយមិនមានអាក់ខានអីទេ បន្តជាប់រហូត?

**ឆ៖** មកដល់ឆ្នាំ៧៩នេះ វារង្វើលៗ ដោយសារវាដកកម្លាំងរត់ទៅក្នុងព្រៃ ហើយនៅកន្លែងហ្នឹងនៅតែពួកខ្ញុំប៉ុន្មាននាក់ទេ នៅសល់តែប៉ុន្មាននាក់ហ្នឹងគេឲ្យនៅមើលអ្នកទោសទាំងអស់ វាក្នុងគុកប្រាំមួយប្រាំពីរនាក់ៗទេ ប្រសិនណាវាតិចៗ វាមិនបានរាប់ទាំងអស់ទេ។ ប៉ុន្តែវាជាប់នៅតិច ប៉ុន្តែដល់វៀតណាមចូលមកដល់ក៏បាញ់ សោបណ្តាច់ ខ្ញុំក៏រត់ចូលតាមសហករណ៍ ទៅចូលតាមភូមិគេទៅ ចេះតែទៅតាមនឹងគេឯងទៅ រត់ពេលហ្នឹង។ ខ្ញុំលែងបានទទួលដឹងឮពី៧៩ហ្នឹង វៀតណាមបុកមក ខ្ញុំក៏បានរត់ចេញពីហ្នឹងមករហូតទាំងអស់គ្នាមក។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតម៉ោងដប់ និងសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់សម្រាក សម្រាប់សាក្សី អ្នកជំនាញ ដល់សាក្សី និងបុគ្គលិកអង្គការ ធី.ភី.អូ ក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលា ឲ្យបានមុនម៉ោងដប់ និង សាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ -- ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំគិតថាខ្ញុំអាចនឹងបញ្ចប់ក្នុងរយៈពេល១៥ ឬ ២០នាទី គឺមុនពេលសម្រាប់យើងនិយាយពីការសួរចម្លើយនៅក្រាំងតាចាន់។ តើលោកមានបានកត់សម្គាល់ឃើញថាអ្នកណាម្នាក់មកនៅក្នុងមន្ទីរហ្នឹងកត់ត្រាទេនៅពេលសួរចម្លើយហ្នឹង មានអ្នកកត់ត្រាទេ?

**លោក សយ សែន៖**

**ឆ៖** បាទ អត់ឃើញទេ ឃើញតែពួកគាត់នៅកន្លែងហ្នឹងតែ ពីរបីនាក់ហ្នឹងដដែល។

**ស៖** កាលពីម្សិលមិញលោកនិយាយថាបន្ទាប់ពីសួរចម្លើយអ្នកទោសហើយ អ្នកទោសខ្លះនោះគេអត់ឲ្យហូបទេ ហើយលោកបានរាប់ផងដែរ មានអ្នកខ្លះអត់អាចហូបដល់១៨ថ្ងៃឯណោះ។ តើ ស៊ឹម ឬក៏អ្នកយាមផ្សេងទៀតនៅក្រាំងតាចាន់ហ្នឹងមានប្រាប់លោកទេថា ហេតុអ្វីបានជាគេបង្អត់អាហារអ្នក

ទោសក្រោយពីគេសួរចម្លើយហើយ?

**ឆ៖** បាទគេអត់មានប្រាប់ទេ គ្រាន់តែគេមិនឲ្យលើកបាយចូលទៅហ្នឹង គេថា "មិនបាច់លើកទៅហ្នឹងទេ អ្ហែងលើកទៅខាងកើតទៅ" គេថាតែប៉ុណ្ណឹង។

**ស៖** ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរបស់មន្ទីរសន្តិសុខក្រាំងតាចាន់វិញ តើលោកអាចជម្រាបបានទេថាក្រោយ ១៧ មេសា ឆ្នាំ៧៥ អ្នកណាខ្លះដែលស្ថិតនៅក្នុងគណៈកម្មការដែលគ្រប់គ្រងមន្ទីរសន្តិសុខនោះ?

**ឆ៖** បាទ ខ្ញុំស្គាល់តែពីរនាក់ហ្នឹង ផ្លាស់ខ្ញុំទៅនៅ ឃើញគាត់ផ្លាស់ប្ដូរតែពីរវគ្គហ្នឹង ពីរដង។

**ស៖** សូមទោស ក្នុងការបកប្រែខ្ញុំអត់បានស្ដាប់ឮអ្វីដែលលោកបាននិយាយទេ លោកអាចនិយាយឈ្មោះម្ដងទៀតបានទេ។ នរណាខ្លះដែលជាអ្នកដឹកនាំមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹង គឺដូចជាប្រធាន អនុប្រធាននិងសមាជិក សូមលោករៀបរាប់ឈ្មោះអ្នកទាំងអស់នេះ?

**ឆ៖** បាទ ប្រធានគាត់ តាអាន់, អនុប្រធាន តាពេញ, សមាជិក តាចេង។

**ស៖** ចុះ ឌុចធំ គាត់មិនស្ថិតនៅក្នុងចំណោមថ្នាក់ដឹកនាំហ្នឹងទេ?

**ឆ៖** បាទ ឌុចធំ ខ្ញុំអត់បានក្ដាប់គាត់ជុំដែរ ដឹងតែគាត់ជំនួយការ គាត់ធ្វើជាជំនួយការក្នុងហ្នឹង ប៉ុន្តែការងារអ្វីៗឃើញគាត់ពិភាក្សាគ្នាគាត់ហ្នឹង ឃើញតាចេង ហើយនិងតាពេញហ្នឹង ឧស្សាហ៍ពិភាក្សាជាមួយ បងឌុច ហ្នឹងបាទ។

[១០:៣៨:១៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បានការបញ្ជាក់ពីអ្វីដែលលោកបានឆ្លើយពីម្សិលមិញ។ លោកថាទាហាន ឬក៏អ្នកយាមមួយហ្នឹងបានរំលោភស្ត្រីពីរនាក់នៅកងចល័ត ហើយបានដាក់បញ្ចូលគ្រាប់*សេវេនធីណៃ* ហ្នឹងនៅក្នុងប្រដាប់ភេទ។ លោកអាចប្រាប់ឈ្មោះទាហានដែលធ្វើបែបនេះបានទេ?

**ឆ៖** បាទ ប្រាប់បានស្គាល់គាត់។ បងឌុច –ឌុចតូចហ្នឹង– ឌុចតូច ហើយនិង សាំង។ ពីរនាក់ហ្នឹងបាទ។

**ស៖** តើអ្នកទាំងហ្នឹងមានត្រូវបាន តាអាន់ ឬក៏ថ្នាក់ដឹកនាំមន្ទីរក្រាំងតាចាន់ហ្នឹងដាក់ទណ្ឌកម្មទេនៅពេលដែលគាត់រំលោភបែបនេះនោះ?

**ឆ៖** អត់ឃើញគាត់ដាក់ទណ្ឌកម្មអី ឃើញតែធម្មតា។ ចុះបើបទបញ្ជាចេញពីមេគាត់ទៅដែរដូចគ្នា។

**ស៖** កាលពីម្សិលមិញលោកបាននិយាយពីការសម្លាប់ស្ត្រីពីរនាក់ កូនស្រី -- ក្មេងស្រីពីរនាក់។ លោកថាគេបោកក្មេងស្រីម្នាក់ហ្នឹងទៅដើមឈើ បែកក្បាល ហើយក្មេងធំបន្តិចហ្នឹងគេវៃក្រោយកញ្ចឹងក លោកអាចប្រាប់ឈ្មោះ អ្នកយាមដែលវៃសម្លាប់ក្មេងស្រីទាំងពីរហ្នឹងបានទេ?

**ឆ៖** អាចប្រាប់ ខ្ញុំស្គាល់បាទ។ បងសៀង, បងមឿន, សាំង, ឌុចតូច។ បាទ បួននាក់ហ្នឹង។

**ស៖** អ៊ីចឹងមានន័យថាពួកគាត់គ្នាច្រើន អ៊ីចឹងអ្នកណាជាអ្នកដែលចាប់ជើងក្មេងស្រីហ្នឹងហើយបោកក្បាលនឹងគល់ឈើហ្នឹង អ្នកណាជាអ្នកធ្វើអ៊ីចឹង លោកអាចប្រាប់ឈ្មោះបានទេ?

**ឆ៖** ប្រាប់បាន បងសៀង – ឈ្មោះ សៀង។

**ស៖** ឥឡូវនេះខ្ញុំសូមដកស្រង់ ចម្លើយរបស់លោកនៅក្នុងឯកសារ E3/714, ERN ជាភាសាខ្មែរ 00223068, ជាភាសាបារាំង 00702899, ជាភាសាអង់គ្លេស 00225511។ លោកឆ្លើយថា "មានពីរនាក់ឈ្មោះឌុច គឺ ឌុច តូច និងឌុច ធំ។ ឌុចធំ ជាអនុប្រធាន, ឌុចតូច ជាថ្នាក់ក្រោម។ ក្រៅពីការងារសម្លាប់អ្នកទោស ឌុចតូចមានតួនាទីបន្ថែមទៀត ជាអ្នកវាយអង្គុលីលេខ ធ្វើរបាយការណ៍សម្រាប់ផ្ញើទៅថ្នាក់លើ។ ឌុចតូច និងម្នាក់ទៀតឈ្មោះ សាំង មានលក្ខណៈកាចជាងគេក្នុងចំណោមទ័ពទាំងដប់ពីរនាក់នោះ"។ ចំពោះការអះអាងបែបនេះនោះ ថាតើហេតុអីបានជាលោកប៊ាននិយាយថា ឌុចតូច ហើយនិង សាំង ហ្នឹងកាចសាហាវជាងគេក្នុងចំណោមទាហានទាំងដប់ពីរនាក់នុ៎ង?

[១០:៤២:១៥]

**ឆ៖** បាទខ្ញុំថាគាត់កាចជាងគេ គាត់ឃើញអ្នកទោសអ្នកអីធ្វើការខុសគ្នាអាចតិចតួច គាត់ត្រូវដៃៗ ត្រូវជើងៗ គាត់រាងដូចថាមាត់កាចសាហាវជាងគេ គាត់ឃើញចំណីអីសល់ពីកន្លែងគាត់ហូបចុកសល់ឃើញអ្នកទោសមកបោសសំរាមឲ្យហ្នឹង ឃើញយកនេះ យកនោះ គាត់វៃដៃ វៃជើង វៃដៃ ឃើញយកដំឡូង វៃដៃភ្លូសអ៊ីចឹងទៅ បាទ អត់ឲ្យយក គាត់រាងកាចជាងគេ។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយលោកដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការវិលត្រឡប់មកក្រាំងតាចាន់របស់លោកវិញ ក្រោយឆ្នាំ៧៩ លោកបាននិយាយចំពោះមុខសហចៅក្រមស៊ើបអង្កេតថាលោកបានត្រឡប់មកវិញដើម្បីរៀបចំពិធី ឧទ្ទិសបុណ្យកុសល។ ក្នុងឋានៈជាអ្នកទោសដែលបានជីករណ្តៅសាកសព រណ្តៅកប់សាកសពច្រើននោះ តើលោកមានកត់សម្គាល់ឃើញថាក្រោយឆ្នាំ១៩៧៩ហ្នឹងមានការជីកកកាយរណ្តៅទាំងអស់ហ្នឹង ហើយមានការយកឆ្អឹងខ្មោចអ៊ីចឹងចេញ ឬក៏អត់មានធ្វើអីទេ គឺនៅដដែល?

**ឆ៖** អត់មានធ្វើអីទេហ្នឹង នៅដដែលបាទ អត់មានធ្វើអីថែមទៀតផង។

[១០:៤៣:៥១]

**ស៖** ដូច្នេះខ្ញុំគិតថា នេះគឺនៅពេលដំបូង ក៏ប៉ុន្តែកាលពីម្សិលមិញនេះយើងនិយាយអំពីតួរលេខលលាដ៍ក្បាលដែលរាប់ដោយព្រះសង្ឃ នៅពេលដែលគេជីកកកាយរណ្តៅផ្សេងៗនៅក្រាំងតាចាន់។ បើតាមលោកផ្ទាល់ដែលជាអ្នកមានវត្តមាននៅទីនោះ ដែលជាអ្នកបានជីករណ្តៅ ហើយនិងក្រោយមកបានទៅទៀងនុំង តើលោកមានឃើញថាតើរណ្តៅហ្នឹង គេមាន មានគេជីកកកាយទេ?

**ឆ៖** ជីកតែ ជីកកកាយតែវគ្គមុនទេ ដល់ក្រោយៗនៅតាមភូមិខាងលិចឈាងខាងត្បូងអត់មានជីកទេ អាហ្នឹងលុបចោលទល់សព្វថ្ងៃហ្នឹង បាទ។

**ស៖** ដើម្បីឲ្យបានពេញលេញនោះ ខ្ញុំជឿថាលោកបានឆ្លើយថាអ្នក ប្រជាជនបានសង់ផ្ទះនៅលើរណ្តៅមួយចំនួន។ តើអីចឹងមែនទេ?

**ឆ៖** បាទ ពីខាងត្បូងមកត្រពាំង គាត់សង់ផ្ទះនៅលើសពហ្នឹងហើយ។ សព្វថ្ងៃគេអត់ឲ្យជីកទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ជេស្នាឯល៖**

សូមអរគុណ លោកដើមបណ្តឹងរដ្ឋប្បវេណី តាំងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំសូមអរគុណចំពោះការអត់ធ្មត់ និងការផ្តល់សក្ខីកម្មរបស់លោកនៅចំពោះមុខតុលាការ។ សូមអរគុណលោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកតំណាងសហព្រះរាជអាជ្ញា។ អស់លោក លោកស្រីចៅក្រមមានសំណួរអ្វីសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ។

សូមអញ្ជើញ លោកចៅក្រម ក្លូឌា ហ្វេនស៍!

[១០:៤៦:០០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួន។ ខ្ញុំសុំចាប់ផ្តើមសួរជាមួយនឹងករណីដែលឃើញថា មានស្ត្រីម្នាក់គឺថាត្រូវបានគេបំពាតបំពានផ្លូវភេទ ហើយលោកសហព្រះរាជអាជ្ញាក៏បានលើកឡើងពីចំណុចនេះដែរ។

លោកបាននិយាយថា អ្នកដែលប្រព្រឹត្តអំពើរនេះ គឺមិនត្រូវបានទទួលការដាក់ទណ្ឌកម្មទេ។ លោកមាន លោកអាចដឹងបានទេថា ហេតុអីបានជាអ្នកប្រព្រឹត្តហ្នឹងមិនបានទទួលរងទណ្ឌកម្មនោះ?

**លោក សយ សែន៖**

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរ បាទនេះជាកងទ័ពរបស់គាត់គេយកទៅសម្លាប់ៗហើយគាត់ មុននឹងសម្លាប់គាត់ធ្វើអីស្រេចគាត់ ព្រោះជំនាន់ហ្នឹងសិទ្ធិនៅលើគាត់ទាំងអស់។

**ស៖** លោកសាក្សី លោកក៏បាននិយាយថា មានការណែនាំ ពាក់ព័ន្ធទៅនឹងបញ្ហាបែបហ្នឹង គឺបញ្ហារំលោភផ្លូវភេទអីចឹង។ តើលោកអាចបញ្ជាក់បានទេថា ការណែនាំ ឬក៏សេចក្ដីណែនាំហ្នឹងវាគេណែនាំរបៀបម៉េចដែរ?

**ឆ៖** ហ្នឹងខ្ញុំអត់បានដឹងដែរ។

**ស៖** លោកមានដឹងអំពីការណែនាំណាមួយទេ? លោកបាននិយាយថាគេមិនបានទទួលការដាក់ទណ្ឌកម្មទេ ទោះបីជាមានការណែនាំ មានសេចក្ដីណែនាំក៏ដោយ ក៏អ្នកប្រព្រឹត្តហ្នឹងមិនបានទទួលការដាក់ទណ្ឌកម្មទេ។ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ហ្នឹងវា តាមខ្ញុំមើល ខ្ញុំថាដូច មិនដឹងដាក់ទណ្ឌកម្មអី បើគាត់ជាអ្នកកងទ័ព ហើយគាត់ជាអ្នកនគរបាលនៅកន្លែងហ្នឹងហើយ គាត់យកទោសអ្នកណាទៀត បើតាមយោបល់ខ្ញុំដែលយល់ណា ដូចមិនដែលឃើញ បាទ។

[១០:៤៨:១២]

**ស៖** តើឧប្បត្តិហេតុដែលកើតឡើងរឿងចាប់រំលោភហ្នឹង មានតែលោកទេដែលបានដឹង ឬក៏មានការនិយាយគ្នាក្នុងចំណោមអ្នកដែលជាប់ឃុំឃាំង ឬក៏មានការនិយាយគ្នាក្នុងចំណោមបុគ្គលិកគុកហ្នឹងដែរ?

**ឆ៖** បាទ គេអត់ឲ្យដឹងទេហ្នឹង គេអត់ឲ្យដឹងទេ។

**ស៖** ចុះខ្លួនលោកវិញ ធ្វើម៉េចបានលោកដឹងថាមានអំពើរំលោភផ្លូវភេទហ្នឹង?

**ឆ៖** បាទ ខ្ញុំបានដឹងព្រោះគាត់ប្រាប់ខ្ញុំ បើគាត់អត់ប្រាប់ ខ្ញុំម៉េចនឹងដឹង បាទ។

**ស៖** សូមជម្រាបជូនអង្គជំនុំជម្រះផងមើលថា អ្នកណាជាអ្នកដែលបានប្រាប់លោកអំពីការរំលោភសេពសន្ថវៈហ្នឹង?

**ឆ៖** ឌុច តូច។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសុំចូលទៅប្រធានបទមួយផ្សេងទៀត។ ជាសំណួរដែលស្រួលទេ ពីម្សិលមិញលោកបានជម្រាបជូនអង្គជំនុំជម្រះថា នៅពេលដែលនិយាយទាក់ទងទៅនឹងអគារដែលពីដើមមកគឺថា មានអគារតែពីរទេ ហើយក្រោយមកក៏មានការសង់អគារពីរបន្ថែមទៀត។ លោកចាំទេថា តើអគារពីរថ្មីនោះ គេសង់នៅឆ្នាំណាដែរ?

**ឆ៖** ហ្នឹងខ្ញុំមិនអាចចាំឆ្នាំទេ ប៉ុន្តែដឹងថាគេបញ្ជូនអ្នកទោសមកច្រើន គេធ្វើគុកថែមពីរពីខាងកើតហ្នឹងមកទៀត។ ពីខាងកើតហ្នឹងជាប់គ្នាទាំងពីរ។

**ស៖** តើអគារថ្មីទាំងពីរនេះសង់តំណាលៗគ្នា ឬក៏វាសង់ គឺថាមួយហើយ បានមួយរយៈមកទៀតទើបសង់ថែមមួយទៀត ឬក៏សង់អគារទាំងពីរក្នុងពេលតំណាលគ្នា?

**ឆ៖** សង់មួយម្តង។ ពីខាងកើត -- ពីខាងលិចហើយតខាងកើតមួយទៀត។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅដល់កន្លែងដែលគេសួរចម្លើយអ្នកទោស។ នៅក្នុងអំឡុងពេល ៥ឆ្នាំដែលលោកជាប់ឃុំនៅទីនោះ តើកន្លែងសួរចម្លើយ គេសួរតែកន្លែងតែមួយហ្នឹងទេ ឬក៏គេមានសួរចម្លើយនៅកន្លែងផ្សេងពីកន្លែងនេះ?

**ឆ៖** តាមខ្ញុំដឹងឃើញកន្លែងតែមួយហ្នឹង មិនដឹងកន្លែងផ្សេងពីហ្នឹងផង មានកន្លែងតែមួយហ្នឹង។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ថា គឺគេសួរចម្លើយតែនៅកន្លែងតែមួយទេក្នុងរយៈពេល ៥ឆ្នាំហ្នឹង។ តើអ៊ីចឹងឬក៏អត់ទេ?

[១០:៥១:៤១]

**ឆ៖** បាទ តែមួយអត់មានសួរកន្លែងណា បែកកន្លែងផ្សេងទេមានតែកន្លែងតែមួយសួរ។

**ស៖** លោកបានរៀបរាប់ជូនអង្គជំនុំជម្រះអំពីចំនួនអគារដូចតទៅ៖ ហើយមានអគារ មានដាំដើមត្នោត ហើយក៏មានដំបូលធ្វើពីឫស្សីប្រក់ស្លឹក។ តើត្រឹមត្រូវទេ ខ្ញុំយល់ថាអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទដំបូលប្រក់ក្បឿងស្រកាលេញ វ៉ែដាដែងញ៉ក ពីឈើ ក្តារជញ្ជាំងក៏ឈើដែរ។ ច្បោះខាងគឺមានខាងៗពីខាងជញ្ជាំងហ្នឹងមានជាគោលរបង ជាឈើគ្រាក់ៗយកទៅដាំស្រុះអែបស្រុះរបងខាងៗជញ្ជាំងហ្នឹង ជម្រៅទៅក្រោមដីប្រាំតឹកទៀត ដាក់ជីកលុបអែបជញ្ជាំង ប្រាំតឹកទៀតបាទ។

**ស៖** ខ្ញុំដូចជាមានការភ័ន្តច្រឡំ។ តើដំបូល -- សូមសួរបញ្ជាក់ -- តើដំបូលគឺនិយាយពីអគារដែលគេសង់ចំនួន ១៥សង់ទីម៉ែត្រកម្ពស់ចេញពីដីហ្នឹង។ តើដំបូលវា ដំបូលប្រក់ក្បឿង ឬប្រក់ស្លឹក?

[១០:៥៣:០៩]

**ឆ៖** បាទ បរក់ក្បឿងទាំងអស់ ប្អូនអគារ ប្អូនគុកហ្នឹងប្រក់ក្បឿងទាំងប្អូន ប៉ុន្តែក្បឿងៗស្រកាលេញ ដាដែងញ៉ើក គេដាក់ដាដែងញ៉ើក។

**ស៖** ឥឡូវនេះ ខ្ញុំសួរអំពីអគារដែលមានបន្ទប់សួរចម្លើយនៅក្នុងអគារហ្នឹង។ គឺខ្ញុំចង់សួរពីអគារដែលគេប្រើប្រាស់មួយចំណែក កន្លែងមួយសម្រាប់សួរចម្លើយ។ តើគេប្រើអគារទាំងមូលហ្នឹងសម្រាប់សួរចម្លើយ ឬក៏គេយកតែផ្នែកណាមួយនៃអគារហ្នឹងយកមកធ្វើជាកន្លែងសួរចម្លើយ? ដូច្នេះ សូមជម្រាបជូនអង្គជំនុំជម្រះផងមើល ជម្រាបជូនតែត្រង់ផ្នែកនៃអគារ ឬក៏អគារទាំងមូលដែលត្រូវគេយកសួរចម្លើយ ឬក៏យ៉ាងណា?

**ឆ៖** បាទ គុក ខ្ញុំរស់នៅកន្លែងហ្នឹងកន្លែងគុក អ្នកទោសគេអត់ដែលសួរចម្លើយនៅកន្លែងហ្នឹង គេយកមកសួរនៅកន្លែងផ្សេង។ កន្លែងផ្សេងហ្នឹង ដំបូលប្រក់ស្លឹក ជញ្ជាំងប្រជីសឫស្សី បាំងជាមួយស្លឹកត្នោត ជញ្ជាំងជាប្រជីសឫស្សីហ្នឹង កន្លែងសួរចម្លើយ។ ប៉ុន្តែខាងក្រោយគេវ៉ៃជញ្ជាំងជិត ខាងមុខគេទុកវាលសម្រាប់សួរចម្លើយ ប៉ុន្តែទុកជញ្ជាំងតឿ ប៉ុន្តែខាងក្រោយពីបន្ទប់ខាងក្រោយហ្នឹង សុទ្ធតែសម្ភារៈសឹងនៅហ្នឹង គ្រាប់រំសេវ កាំភ្លើងនៅពេញហ្នឹងទាំងអស់ពីក្រោយ។

[១០:៥៤:៤៨]

**ស៖** លោក ជម្រាបជូនអង្គជំនុំជម្រះថា លោកឮសំឡេងចេញពីជញ្ជាំងហ្នឹង។ ប៉ុន្តែតាមរយៈជញ្ជាំងអ៊ីចឹង តើលោកអាចមើលឃើញទៅកន្លែងខាងក្នុងគេសួរចម្លើយហ្នឹងទេ?

**ឆ៖** ជញ្ជាំងនៅកន្លែងគុកអត់អាចសួរ -- អត់អាចមើលឃើញទេ ជិតឈឹង ទោះបីងាកទៅពីខាងត្បូងហ្នឹងព្រៃដំឡូងមីជិតទៀត។ គេអត់ឲ្យយើងមើលឃើញទេ។ ខាងៗ ទោះបីក្បែររបងខាងនោះក៏គេដាំច្បោះ ដាំដំឡូងមីទុកឲ្យវាដុះ ឲ្យព្រៃងងឹតសម្រាប់ឲ្យបាំងកន្លែងសួរចម្លើយខាងត្បូងហ្នឹងបាទ។

**ស៖** ដើម្បីឲ្យកាន់តែច្បាស់ ប្រសិនបើលោកឈរនៅខាងក្រៅអគារមួយហ្នឹង ឧទាហរណ៍ថាលោកឈរប្រហែលជា ១ម៉ែត្រ ចេញពីជញ្ជាំងហ្នឹង តើលោកអាចមើលឃើញតាមចន្លោះប្រហោងណាមួយទេ ជញ្ជាំង ឬក៏តាមចន្លោះប្រហោងណាមួយបានទេ?

**ឆ៖** មើលឃើញ។ ដូចថាមើលឃើញពីខាងមុខហ្នឹង ខាងមុខគេសួរហ្នឹង គេវាយជញ្ជាំងតឿ ហើយពីអគារ -- និយាយរួមផ្ទះមួយហ្នឹង គេវាយបន្ទប់មួយកំណាត់។ វាយមួយកំណាត់សម្រាប់ដាក់កាំភ្លើង ដាក់គ្រាប់។ ហើយមកគេចាក់សោទុកចោលហ្នឹង ហើយចេញមកធ្វើមួយកំណាត់ខាងមុខហ្នឹង វាយជញ្ជាំងតឿ ទៅជញ្ជាំងទៅក្រោម ប្រហែលជាអាច -- ខ្ញុំក៏មិនអាចចាំដែរ ខ្ពស់ប្រហែលជា១ម៉ែត្រ

ធ្លាក់។ ហើយខាងលើហ្នឹង អាចអង្គុយមើលឃើញក្បាលមនុស្សឡើងលើអីចេះ បាទ។ ហ្នឹងគេសួរចម្លើយពីខាងមុខ ប៉ុន្តែវាដាច់ស្រយាលពីកន្លែងគុកមកដីប្រហែលជា--

[១០:៥៦:២២]

**ស៖** ដូច្នេះពីខាងមុខបន្ទប់សួរចម្លើយ មានន័យថាមិនបានធ្វើជញ្ជាំងបិទពេញដូចជញ្ជាំងដទៃទេ អីចឹងមែនទេលោក?

**ឆ៖** បាទអាហ្នឹង គេដាក់ជញ្ជាំងតឿ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើលោកមានចាំនូវឧប្បត្តិហេតុ រឿងហេតុដែលគេបានសម្លាប់មនុស្ស -- លោកៗមានដែលឃើញព្រឹត្តិការណ៍ណាមួយដែលគេសម្លាប់មនុស្ស នៅចំពោះមុខអ្នកទោសដទៃទៀត សម្លាប់ដោយចំហរឲ្យអ្នកទោសដទៃទៀតឃើញទេ? ដែលឃើញព្រឹត្តិការណ៍បែបនេះទេ?

**ឆ៖** បាទឃើញ។ គាត់ឈ្មោះ សង – សង គាត់រត់ ថ្ងៃល្ងាចគេចេញធ្វើការដូចខ្ញុំហ្នឹង ហើយរត់ថ្ងៃល្ងាចពេលគេចូលទៅផ្ទះវិញ គេឲ្យលើកបាយៗហូប ដួសបាយចែកគ្នា។ ដល់ដួសបាយចែកគ្នា វាអត់ ក្រចូល វាខែៗទៅដកស្មៅ ស្រូវតែដកហើយស្រូវវាខ្ពស់ដែរ វារត់។ ដល់រត់ទៅ វា -- រត់គេបាញ់ គេបាញ់ៗកាំភ្លើងការ៉ូប៊ីន ហើយអ្នកនិរសារបាញ់មុនដំបូង ដល់ហើយបានជ្រួលច្របល់ បានរត់ទាហាន -- កងទ័ពរត់ពីកន្លែងទៅផរទាំងអស់ កាំភ្លើងមួយដើមៗម្នាក់ ទៅដល់បាញ់ អាកា ផ្ទូងៗ បាញ់ក្បាល ហើយនិងខ្លួនហ្នឹង ខ្ញុំក៏គេដេញអ្នកទោសហ្នឹងចូលគុកទាំងអស់ទៅ បាញ់ ហើយក៏បាញ់ស្លាប់នៅពេលនុងបាទ។

[១០:៥៨:០២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណ លោកសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទសូមអរគុណលោកប្រធាន បាទជម្រាបសួរ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទខ្ញុំមានសំណួរមួយចំនួន ដើម្បីបំភ្លឺចំណុចមួយចំនួន។ បាទជាដំបូងខ្ញុំសូមត្រឡប់មក

និយាយអំពីរចនាសម្ព័ន្ធបុគ្គលិកនៃមន្ទីរសន្តិសុខក្រាំងតាចាន់។ ហើយជាពិសេស គឺទាក់ទងទៅនឹងថ្នាក់ដឹកនាំ។ បាទលោកនិយាយថា មានមនុស្សបីនាក់ដែលជាថ្នាក់ដឹកនាំ។ បើខ្ញុំយល់ច្រលំទេ គឺថាមុនឆ្នាំ១៩៧៥ អ្នកដែលដឹកនាំមន្ទីរហ្នឹងឈ្មោះ ឆេន។ តើអ៊ីចឹងមែនទេ?

**លោក សយ សែន៖**

**ឆ៖** បាទឈ្មោះ ឆេន គាត់ជាអ្នកដឹកនាំនៅមន្ទីរគុកក្រាំងតាចាន់មុនគេបង្អស់ហ្នឹង។

**ស៖** ហើយខ្ញុំសួរថាតើ ឆេន ហ្នឹងក្រោយពេលដែលគាត់ចេញពីក្រាំងតាចាន់ហ្នឹងហើយ គាត់ក្លាយជាអ្វី? ហើយគាត់នៅឯណា?

[១០:៥៩:២២]

**ឆ៖** គាត់និយាយប្រាប់គេប្រាប់ឯង ហើយប្រាប់កងទ័ពថា គាត់ទៅនៅកាន់កាប់នៅគុក២០៤ នៅខាងលិចត្រពាំងអណ្ដើក។

**ស៖** តើលោកដឹងថាគុក២០៤ហ្នឹង ជាគុកអ្វី? ហើយអ្នកទោសនៅទីនោះហ្នឹងជាអ្នកទោសប្រភេទណាដែរ?

**ឆ៖** នៅកន្លែងនោះខ្ញុំអត់អាចដឹងទេ ព្រោះខ្ញុំអត់ដែលនៅជាប់ហ្នឹង ប៉ុន្តែធ្លាប់ដឹងឮពីអ្នកជាប់ៗហ្នឹង គាត់មានរស់នៅសព្វថ្ងៃនេះ ទៅនៅជាប់២០៤ ជាអ្នកពាក់ព័ន្ធ។ ពាក់ព័ន្ធក្នុងនាមថា ជាគាត់ជាមូលដ្ឋានពាក់ព័ន្ធជាបង ជាឪនៅខាងលន់នល់អ៊ីចឹង គេយកទៅដាក់២០៤។

**ស៖** តើលោកដឹងថា ក្រោយពីគុក២០៤នោះ ឆេន ហ្នឹងគាត់មានទំនួលខុសត្រូវផ្សេងទៀតទេ គាត់ទៅធ្វើការកន្លែងផ្សេងទៀតទេ បន្ទាប់ពីគុក២០៤?

**ឆ៖** បាទ តាគាត់ចេញ២០៤ហ្នឹងទៅ គាត់ឡើងទៅនៅកំពង់ចាម។ ទៅនៅកំពង់ចាមគាត់ឧស្សាហ៍មកលេងនៅក្រាំងតាចាន់ហ្នឹងដែរ។ មួយខែ ពីរខែ គាត់មានអាឡាន កាត់សង់កាត់របស់ចិនអាកង់៦ មួយគេហៅ អាតោប៊ា។ គាត់ឧស្សាហ៍មកឈប់នៅមុខកន្លែងក្រាំងតាចាន់។

**ស៖** តើសព្វថ្ងៃនេះ ឆេន គាត់នៅរស់ដែរឬទេ?

**ឆ៖** បាទ គាត់នៅសព្វថ្ងៃដែល ព្រោះខាងកាសែតគាត់យកខ្ញុំទៅជួបជាមួយគាត់ម្ដងនៅលើភ្នំដងរែកព្រំដែនរបស់ថៃ។ ផ្ទះគាត់នៅជាប់នឹងផ្ទះតា១៥ តាម៉ុក ហ្នឹងតែម្ដង។

**ស៖** លោកនិយាយពី ឆឹម ឬក៏ ឆែម?

**ឆ៖** ឆេនៗ។

**ស៖** តើ ឆេន ធ្លាប់បានរស់នៅអន្លង់វែងដែរឬទេ?

**ឆ៖** បាទ សព្វថ្ងៃគាត់នៅអន្លង់វែងផ្ទះកំណើតគាត់ដែលចេញពី--ទៅនៅខាងជំរំគាត់នៅជាប់នឹងផ្ទះតា១៥ គាត់ហើយផ្ទះតា១៥ ជាប់គ្នា។

[១១:០២:៣០]

**ស៖** តើលោកមានទំនាក់ទំនងជាមួយ ឆេន ហ្នឹងទេ? ហើយតើគាត់ហ្នឹងធ្លាប់ឲ្យយោបល់លោកទាក់ទងនឹងអ្វីដែលលោកត្រូវនិយាយពាក់ព័ន្ធនឹងតួនាទីរបស់គាត់ហើយទាក់ទងទៅនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ដែរឬទេ?

**ឆ៖** បាទ គាត់ដែលប្រាប់ខ្ញុំម្តងដែរ គាត់ថា "អ្អែង អញផ្តាំផ្ញើគេដែរ មិនឲ្យទៅណាមកណាទេ ខំថែខ្លួន ធ្វើម៉េចរក្សាកិត្តិយសឲ្យបាន កុំមាត់ដេកដាចទៅណាទៅណីឲ្យសោះអ្អែង អញផ្ញើគេហើយ"។ គាត់បានប្រាប់តែប៉ុណ្ណឹងទេ បាទ។

**ស៖** ខ្ញុំមិនប្រាកដថា យើងទទួលបានការបកប្រែត្រឹមត្រូវនោះទេ។ ឥឡូវសូមលោកឆ្លើយម្តងទៀត។ តើគាត់ធ្លាប់បានផ្តល់ដំបូន្មានដល់លោកថា លោកត្រូវនិយាយអ្វីនៅចំពោះមុខតុលាការយើងនេះ អ.វ.ត.ក យើងនេះថាត្រូវនិយាយយ៉ាងណាទាក់ទងនឹងទទួលរបស់គាត់ ហើយនិងមន្ទីរសន្តិសុខក្រាំងតាចាន់?

**ឆ៖** បាទ គាត់បានផ្តាំផ្ញើៗគេអ្នកនៅក្រោយៗ គាត់បានប្រាប់ខ្ញុំ គាត់មកឃើញខ្ញុំថា "អ្ហឺ! អញផ្ញើគេ អ្អែងទុកឲ្យនៅហ្នឹងអត់មានទៅណាមកណា អ្អែងនៅមាត់ឲ្យស្ងៀម"។ គាត់បានផ្តាំផ្ញើតែប៉ុណ្ណឹងឯងបាទ។

**ស៖** ខ្ញុំនៅតែមិនទាន់យល់ដដែល។ ថាតើគាត់នោះធ្លាប់ -- តាឆេន–ឆេន ហ្នឹងធ្លាប់បានប្រាប់លោកថាកុំឲ្យនិយាយអ្វីមួយទៅចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ អត់ទេអាហ្នឹង គាត់អត់ដែលប្រាប់ទេ។ គ្រាន់តែប្រាប់ខ្ញុំថា ថ្ងៃដែលខ្ញុំចុះទៅជាមួយអ្នកកាសែតអី ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាទៅដល់ហ្នឹងគាត់ថា ជាក់ស្តែងគាត់បែរត្រឡប់មកវិញគាត់ថា "បើមិនជឿសួរនេះ! ប្អូនសែន នេះនៅជាប់ជាមួយ គាត់ហ្នឹងជាអ្នកជាប់ហ្នឹងដូចគ្នាដែរ"។ ផ្ទុយទៅវិញ ខ្ញុំក៏មិនប៊ានឆ្លើយ គាត់ជាអ្នកប្រធានហើយ ដល់គាត់ឆ្លើយអ៊ីចឹង ថាអ៊ីចឹង ថា "ប្អូនសែនខ្ញុំចាត់ទុកថា ដូចកូនរបស់ខ្ញុំអ៊ីចឹង" គាត់និយាយអ៊ីចឹងបាទ។

[១១:០៥:៣២]

**ស៖** ពេលដែល ឆេន ហ្នឹងគាត់បានចេញទៅ តាអាន់ ឡើងជំនួស។ តើតាអាន់ ហ្នឹងនៅរស់ឬទេ ហើយគាត់បានរួច រស់រានមានជីវិតទេ កាលក្រោយឆ្នាំ១៩៧៩?

**ឆ៖** បាទ អត់បានដឹងដែរ។ ដឹងតែប្រពន្ធគាត់ ប្រពន្ធ និងកូនគាត់នៅបាទ ប៉ុន្តែចំណែកគាត់អត់ដែលឃើញទេ។ គេថាស្លាប់ៗ មិនបានឃើញដែរ។

**ស៖** តើប្រពន្ធគាត់ហ្នឹងជាអតីតអ្នកទោសដែលត្រូវបានឃុំខ្លួននៅក្រាំងតាចាន់ ដែរឬទេ?

**ឆ៖** បាទ ប្រពន្ធគាត់មានរឿងអីត្រូវអ្នកទោសឃុំខ្លួន។ ប្រពន្ធគាត់ជា -- គាត់ជាប្រធានមន្ទីរនៅកន្លែងហ្នឹង ហើយប្រពន្ធគាត់ជា ឬប្រធាននារីអីចឹងៗ គាត់ទៅលេងមួយអាទិត្យអី ពីរអាទិត្យគាត់ទៅជាប់ប្ដីគាត់នៅហ្នឹង។

**ស៖** ហើយឥឡូវនេះ ខ្ញុំចង់ដឹងថា អ្នកណាជាសមាជិកទី៣ នៃគណៈដឹកនាំនៅមន្ទីរហ្នឹង គឺថាដូចពេលមួយនោះ មានឈ្មោះ ប៉េង -- ឈ្មោះ ពេញ បាទ។ អម្បាញ់មិញនេះ លោកបាននិយាយថាឈ្មោះ ឌុច ហ្នឹងគាត់ធ្វើជាអ្នកជំនួយការ។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ សមាជិកទី៣ ដែលមានឈ្មោះអីគេ ឈ្មោះ ពេញ ឬក៏អី? ហើយតួនាទីរបស់ ឌុច ហ្នឹងស្អីដែរ គាត់ធ្វើអីដែរ?

**ឆ៖** ខ្ញុំដឹងថា គាត់នៅហ្នឹង ដឹងថាគាត់មុនដំបូងគាត់ប្រធានយុវជន– ប្រធានយុវជនស្រុក១០៥ ហើយដល់គាត់បានទៅនៅហ្នឹង គឺអត់ដឹងថាគាត់ជាអនុប្រធាន ឬសមាជិកអី អត់បានដឹងទេ។ គាត់នៅហ្នឹង គាត់មានតែប្រធានធំជាងគេ ហើយធំជាងគេ មិនមែន -- ធំជាងគេមានតែ ឌុច ហើយនិង អាន់ ពីរនាក់ហ្នឹងបាទ ព្រោះគាត់ដឹកនាំទាំងស្រុក។

[១១:០៨:១០]

**ស៖** គាត់ដឹកនាំនៅមន្ទីរសន្តិសុខ ឬក៏នៅស្រុក?

**ឆ៖** គាត់នៅតែកន្លែងមន្ទីរសន្តិសុខហ្នឹង ប៉ុន្តែបើ -- អត់ដែលឃើញគាត់ចេញមកវាលផង ឌុច ហ្នឹង គាត់នៅហ្នឹង។ ប៉ុន្តែពីដើមឡើយគាត់អត់ទាន់ចូលហ្នឹង គាត់ជាប្រធានយុវជនស្រុក១០៥ ហើយដល់បានខ្ញុំទៅនៅហ្នឹង ខ្ញុំប្រហែលជាមួយឆ្នាំជាងបានឃើញគាត់ចូលទៅនៅហ្នឹង។ ប៉ុន្តែចូលទៅនៅហ្នឹងក្នុងនាមគាត់ មិនដឹងជាប្រធាន ឬអនុប្រធានមិនដឹងទេ។ ប៉ុន្តែអនុប្រធានសមាជិកអីត្រូវមានការអីត្រូវពិភាក្សាជាមួយគាត់ ឃើញជំនុំជាមួយគាត់បាទ។

**ស៖** តើឌុច តូចនោះ ជាអ្នកទទួលបន្ទុកខាងសរសេររបាយការណ៍មែនទេ វាយអង្គុលីលេខ?

**ឆ៖** បាទ ព្រោះចុងក្រោយមក ឌុចតូចហ្នឹង គាត់ខាងវាយអង្គុលីលេខ ព្រោះគាត់ចេះជាងគេ។

គាត់ចេះអក្សរច្រើន ហើយខាងប្រធានៗហ្នឹង គាត់អត់សូវចេះទេ បើខ្ញុំ -- តាមខ្ញុំចំណាំមើលឃើញចេះច្រើនជាងគេតែ តាពេញ ទេ គាត់ចេះអក្សរច្រើន ហើយប្រធាននោះៗអស់សូវចេះទេបើតាមមើល។

**ស៖** ក្រៅពី ឌុចតូច តើមានបុគ្គលិកម្នាក់ទៀតឈ្មោះ ឌុច ដែរឬទេ ក្រៅពី ឌុចតូច?

**ឆ៖** អត់មានទេ មានតែ ឌុច ពីរនាក់នៅហ្នឹង –ឌុចធំ, ឌុចតូច– មានតែ ឌុច ពីរហ្នឹង។

**ស៖** តើ ឌុច ធំនៅរស់ដែរឬទេ?

**ឆ៖** ឌុចធំ គាត់ស្លាប់ហើយគាត់មានជំងឺផ្ទាល់ខ្លួនគាត់ ស្លាប់ប្រហែលជាពីរឆ្នាំជាងហើយ។

**ស៖** ចុះ តាពេញ គាត់ធ្វើការនៅក្រាំងតាចាន់រហូត ឬក៏គាត់ធ្លាប់បានចេញទៅធ្វើទៅកន្លែងផ្សេងទេ ហើយបើគាត់ចេញៗទៅណាដែរ?

**ឆ៖** ខ្ញុំឃើញតែនៅហ្នឹងរហូត អត់ដែលចេញទៅណាផង ឃើញនៅហ្នឹងរហូត។

**ស៖** តើកម្មាភិបាលមួយចំនួន បានចេញទៅកំពង់ចាមដែរឬទេក្រៅពី ឆេន នោះ?

**ឆ៖** បាទមានៗ ឌុចធំហ្នឹងបាទ ឌុចធំ គាត់ទៅនៅកំពង់ចាម។

**ស៖** តើលោកមានចាំឈ្មោះ កន ដែលជាប្រធានមន្ទីរអង្គរកា?

**ឆ៖** បាទចាំ។ ឃន – តាឃន ប្រធានអង្គរកាបាទ។

**ស៖** តើគាត់នោះធ្លាប់បានមកធ្វើការនៅមន្ទីរក្រាំងតាចាន់ដែរឬទេ?

[១១:១១:៥៩]

**ឆ៖** បាទ គាត់ទៅមកៗ កាលណាត្រូវការកម្ទេចមនុស្សច្រើនអ៊ីចឹងទៅ គាត់មកគ្នាគាត់មកពីអង្គរកា ពីរនាក់មានតាឃនមួយ មកតារស់មួយទៀត។ តារស់ ហើយតាឃន ហើយពីខាងស្នាក់ការនៅខាងលិចត្រពាំងព្រីង ខាងផ្ទះ តាកិលៗមកទៀតកាលណាត្រូវថ្ងៃកម្ទេចច្រើនគ្នាគាត់មកគ្រប់កន្លែង។

**ស៖** តើមន្ទីរសន្តិសុខផ្សេងទៀតនៅក្នុងចំណុះរបស់មន្ទីរក្រាំងតាចាន់ ឬក៏មន្ទីរក្រាំងតាចាន់ហ្នឹងគ្រប់គ្រងលើមន្ទីរសន្តិសុខផ្សេងទៀតដែរឬទេ?

**ឆ៖** បាទដឹងតែគ្រប់គ្រងលើអង្គរកា និងផ្ទះ តាកិល ខ្ញុំដឹងតែពីរកន្លែងហ្នឹងទេបាទ។

**ស៖** តើផ្ទះហ្នឹងនៅឯណា?

**ឆ៖** ខ្ញុំស្តាប់មិនបានទេ។ ផ្ទះខាងណា?

**ស៖** បាទ លោកទើបតែនិយាយថាលោកដឹងថាក្រាំងតាចាន់ហ្នឹងត្រួតត្រាអង្គរកា ហើយនិងផ្ទះតាកិល អានេះបើតាមខ្ញុំយល់។ តើអ៊ីចឹងខ្ញុំសួរលោកថាតើផ្ទះហ្នឹងនៅឯណា?

**ធ៖** បាទ ផ្ទះតាកិល នៅខាងលិចគុកក្រាំងតាចាន់ដីមួយគីឡូជាង នៅស្នាក់ការ គេហៅស្នាក់ការតាកិល នៅចេញពីអង្គរកាមក។ចូលស្នាក់ការតាកិល ចេញពីស្នាក់ការតាកិល បានមកចូលក្រាំងតាចាន់។

[១១:១៥:១៥]

**ស៖** បើអ៊ីចឹងបានន័យថា តាកិល មិនមែន ឃន អ្នកទទួលខុសត្រូវនៅអង្គរកាទេ គឺមានពីរ គឺថាមានតាកិល ហើយនិងអង្គរកា ដែលមាន ឃន ជាអ្នកដឹកនាំនៅទីនោះ។ អ៊ីចឹងមែនទេ?

**ធ៖** បាទ។

**ស៖** បាទ ឥឡូវនេះយើងសូមនិយាយអំពីយោធា ឬក៏អ្នកយាមនៅមន្ទីរក្រាំងតាចាន់ម្តង។ ខ្ញុំបានកត់ឈ្មោះមួយចំនួន អ៊ីចឹងសូមឲ្យលោកប្រាប់ខ្ញុំថាតើឈ្មោះហ្នឹងជាឈ្មោះយោធាមែនដែរឬទេ? ឈ្មោះ អ៊ុក អ៊ីចឹងឈ្មោះហ្នឹងលោកស្គាល់ឈ្មោះហ្នឹងទេ?

**ធ៖** បាទស្គាល់ មិនមែន អ៊ុក ទេ អ៊ួកបាទ។ អ៊ួក ហ្នឹងនៅស្នាក់ការជាមួយតាកិល ប៉ុន្តែចេញពីក្រាំងតាចាន់ទៅដូចគ្នា។

**ស៖** ហើយតើលោកដឹងថាគាត់ហ្នឹង នៅរស់រានមានជីវិតទេរាល់ថ្ងៃហ្នឹង? នៅរស់ ឬក៏យ៉ាងម៉េចដែរ?

**ធ៖** បាទអត់ដឹងទេ។ សព្វថ្ងៃខ្ញុំអត់បានដឹងគាត់ទេ ដឹងថាអ្នកនៅជិត។ហ្នឹងគេឃើញ បើអ្នកក្រៅហ្នឹងអត់ដែលឃើញទេ។

**ស៖** បាទ បន្ទាប់មកទៀត តើលោក។ឈ្មោះចិន លោកស្គាល់ឈ្មោះ ចិន ដែរទេ?

**ធ៖** បាទស្គាល់ ចិន ហ្នឹងជាអ្នកទោសដែរ។

**ស៖** ឈ្មោះ មឿន លោកស្គាល់ឈ្មោះទេ? គាត់ហ្នឹងជាយោធា ឬក៏យ៉ាងណា?

**ធ៖** បាទស្គាល់ មឿនហ្នឹងគាត់ជាយោធានៅកន្លែងហ្នឹង ប៉ុន្តែចុងបញ្ចប់មកគាត់ថា ជំនាន់ហ្នឹងឮគេថាទេ ខ្ញុំមិនដឹង ឮគាត់និយាយ គាត់ឧបជន បាទ។

[១១:១៦:៥៥]

**ស៖** គាត់នៅរស់ដែរឬទេ?

**ធ៖** បាទ គាត់ស្លាប់ហើយនៅតែប្រពន្ធទេ។ គាត់ស្លាប់តាំងពី ៧៩។

**ស៖** តើគាត់ហ្នឹងត្រូវបានគេសម្លាប់ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គាត់រត់ចេញពីហ្នឹងទៅគាត់សង្គ្រាមជាមួយវៀតណាមកាល៧៩ហ្នឹង គេទៅវ៉ៃគ្នាងាប់នៅក្បែរ ព្រៃភ្នំដំរីរមាល ពីសម័យ ៧៩ហ្នឹង គេបាញ់នៅម្តុំហ្នឹងបាទ។

**ស៖** បាទ ឥឡូវនេះខ្ញុំសូមឱ្យលោកប្រាប់ថាតើឈ្មោះ សាំង ហ្នឹងជាឈ្មោះទាហានឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គាត់ជាទាហានទេ សាំង ហ្នឹង។ គាត់មកមួយក្រុមគ្នាគាត់ហ្នឹង គឺទាហានទាំងអស់នៅកន្លែងហ្នឹង ប៉ុន្តែគាត់ជាចុងក្រោយគាត់ចូលជាបក្ខជនដែរ។ ប៉ុន្តែមកមុនដំបូងគាត់ជាទាហានទេបាទ។

**ស៖** បាទខ្ញុំ អំមិញនេះខ្ញុំមិនមែននិយាយ សាំង ទេ តាមពិតខ្ញុំនិយាយ សៀង។ ខ្ញុំមិនដឹងថាភាសាខ្មែរខុសគ្នាម៉េចទេ តែជាភាសាបារាំងនេះ ឈ្មោះគឺសរសេរ -- ឈ្មោះ សៀង បាទនុំងហើយឈមិនមែន សាំង ទេ។ អ៊ីចឹង ឥឡូវនេះ អំមិញនេះលោកនិយាយពីឈ្មោះ សាំង ឬក៏ឈ្មោះ សៀង ដែលថាគាត់ជាទាហានអំមិញនេ?

**ឆ៖** បាទ សាំង។

**ស៖** បាទ អំមិញហ្នឹងនិយាយថា -- ខ្ញុំអានជាបារាំង ខ្ញុំអាន សៀង ហើយឥឡូវគាត់ឆ្លើយឈ្មោះ សាំង ឬក៏សៀង? តើឈ្មោះ សាំង ដែលលោកទើបតែបាននិយាយអំមិញនេះគាត់នៅរស់ដែរឬទេ?

**ឆ៖** បាទសាំង គាត់នៅរស់ បើ សៀង គាត់ស្លាប់បាត់ហើយ។

**ស៖** បាទ ឥឡូវនេះ ខ្ញុំនិយាយពីសាំង ដែលគាត់នៅរស់នៅឡើយទេ។ បាទលោកបាននិយាយពីគាត់ច្រើនដងហើយ បើសិនជាខ្ញុំយល់មិនច្រឡំទេ លោកបាននិយាយថាមួយ និង ឌុចតូចនោះ ពីរនាក់ហ្នឹងគឺជាអ្នកដែលឃោរឃៅជាងគេ។ អ៊ីចឹងលោកចង់និយាយថាឈ្មោះ សាំងហ្នឹងហើយឬ និង ឌុចហ្នឹងហើយឬដែលជាអ្នកឃោរឃៅជាងគេនោះ កាចជាងគេនោះ?

**ឆ៖** បាទ សាំង និង ឌុច ហ្នឹងគាត់រាងកាចជាងគេ ហើយនិង សៀងៗ ក៏កាចដែរ។ ស្លូតអ្នកតិចណាស់ បាទ។

**ស៖** ម្សិលមិញ ហើយព្រឹកមិញដែរ គេបានចោទសំណួរលោក ហើយលោកនិយាយអំពីការសម្លាប់កុមារីពីរនាក់ ក្មេងស្រីពីរនាក់ ហើយលោកបាននិយាយថា កាលពីម្សិលមិញនេះ បើខ្ញុំមិនច្រឡំទេគឺថាឌុចតូចហ្នឹង គឺជាអ្នកដែលបោកក្បាលក្មេងស្រីដែលតូចជាងគេហ្នឹងទៅនឹងគល់ឈើ ហើយសាំងហ្នឹងគឺជាអ្នកដែលសម្លាប់បងស្រីរបស់ក្មេងស្រីតូចហ្នឹង។ ចាំថាបាននិយាយអ៊ីចឹងទេ?

**ឆ៖** បាទ ចាំ ប៉ុន្តែមិនមែន សាំង អ្នកបោកទេ សៀងៗ បោកៗនឹងគល់ត្នោត។ ប៉ុន្តែទៅបណ្ដាញរបស់គាត់ហ្នឹងមានសាំង – សៀង, សាំង, ឌុចតូច, ស៊ីម។ បួននាក់។

[១១:២២:០០]

**សៈ** អីចឹងអ្នកដែលបោកក្បាលកូនក្មេងហ្នឹង ឬក៏អ្នកដែលសម្លាប់បងៗគេនោះ ឈ្មោះ សាំង ឬក៏ឈ្មោះ សៀង?

**ឆ៖** សម្លាប់បងចុងក្រោយៗ គឺ សាំង។ ប្អូនមុនហ្នឹង សៀង បាទ។

**សៈ** តើលោកមានទំនាក់ទំនងជាមួយ សាំង ដែរឬទេ? ធ្លាប់មាន ធ្លាប់ជួបគាត់ទេ? ធ្លាប់ទាក់ទងគាត់ទេ?

**ឆ៖** បាទ ជួប សព្វថ្ងៃជួបគាត់ ប៉ុន្តែជិះធ្វើដំណើរអី ដើរហើរទៅតាមភូមិទៅជួបគាត់ គាត់គេចមុខខ្ញុំ អត់ជួបមុខខ្ញុំទេ គាត់ខ្លាច ដូចរាងដូចថាខ្លាចខ្ញុំអីចឹងទៅ បាទ។

**សៈ** តើសាំង ហ្នឹងខ្លាចអំពីអ្វីដែលលោកអាចរៀបរាប់ទៅសហចៅក្រមស៊ើបអង្កេត ហើយនិងតុលាការយើងនេះ ទាក់ទងទៅនឹងតួនាទីរបស់គាត់នៅមន្ទីរក្រាំងតាចាន់។ តើគាត់ហ្នឹងធ្លាប់បានផ្តល់ដំបូលមានឱ្យលោកថា កុំនិយាយអី ឬក៏និយាយអីទេនៅចំពោះមុខតុលាការ?

**ឆ៖** បាទ គាត់ដែលប្រាប់ដែរ ពីមុនៗគាត់ប្រាប់ខ្ញុំដែរ គាត់ថា៖ “អ្ហឺ! បើគេសួរអីអ្វីៗមួយ ឆ្លើយថាជនរងគ្រោះជាប់គុកដូចគ្នាទៅអាអើយ ជួយអញផងមក”។ ប៉ុន្តែឥឡូវ សព្វថ្ងៃគាត់មិនមែន ហៅ “អញ-អ្អែង”ទេ គាត់ហៅខ្ញុំបងវិញ។ ពីមុនគាត់ហៅខ្ញុំ “អ្អែង” ឥឡូវគាត់ហៅខ្ញុំ “បង” ថា “បងឯងជួយខ្ញុំផង ជួយប្រាប់គេថាខ្ញុំជាប់គុកដូចបងឯងដែរ រងគ្រោះដូចគ្នាទេ។ បងឯងជួយខ្ញុំផង ព្រោះខ្មែរដូចគ្នាទេ”។ គាត់បាននិយាយជាមួយខ្ញុំជា មួយលើកទៅពីរលើកហើយ សាំង ហ្នឹង។

[១១:២៤:១៨]

**សៈ** តើអ្នកយាមមួយចំនួនដែលនៅរស់នៅឡើយ ដែលរស់នៅក្នុងស្រុកត្រាំកក់ហ្នឹង នៅថ្ងៃណាមួយធ្លាប់បានសុំសូកលុយលោកដើម្បីឱ្យលោកកុំនិយាយស្តីអីទាំងអស់ បិទមាត់លោក មានធ្លាប់ទេ? គេមានធ្លាប់សូកលុយទេ?

**ឆ៖** បាទ មាន។ ប៉ុន្តែមិនមែនកងទ័ពនៅត្រាំកក់ហ្នឹង មិនមែនទេ គឺគាត់ជាប្រធាន គាត់នៅរស់សព្វថ្ងៃហ្នឹង ប៉ុន្តែរឿងរ៉ាវហ្នឹងខ្ញុំអត់បាននិយាយទេ។ វាគ្រាន់ថា គាត់គ្រាន់តែថាឱ្យខ្ញុំហ្នឹងជួយសម្រួលថា “ចាត់ទុកអ្អែងជាកូន”ហ្នឹង តាឆេន ជាប្រធានមន្ទីរមុនគេបង្អស់។ គាត់ថា អ្អែង -- ចាត់ទុកអ្អែង

ជាកូនហើយ អ្អែងការខ្វះខាតអី អ្អែងពឹងពាក់មកឪមានឲ្យចែកកូនឯងរកស៊ីគ្នាឯងខ្លះ។ អាហ្នឹងគាត់មាននិយាយណ៎ាពីមុនមក។ និយាយពីឥឡូវហ្នឹង ប៉ុន្តែទាក់ទងសូកជាលុយកាក់អីអត់មានទេ មានថាឲ្យដើមឲ្យទុនទៅរកស៊ី ប៉ុន្តែឲ្យនិយាយថា "អ្នកជាប់ទោស ទារុណកម្មដូចគ្នា" តែប៉ុណ្ណឹងបាទ។

**ស៖** លោកកំពុងតែនិយាយពី តាឆែន ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ សំណួរនេះ ខ្ញុំនិយាយពី តាឆែន ព្រោះ តាឆែន គាត់ថា -- សួរថាមានអ្នកណាដែលអាចសូកលុយសូកកាក់ មានតែ តាឆែន ទេគាត់ជា -- ទុកខ្ញុំជាកូនហ្នឹង គាត់ថាខ្ញុំខ្វះខាតពីបញ្ហាលុយកាក់អីគាត់ផ្តល់លុយកាក់ឲ្យយកមករកស៊ីអីតិចតួចបាន ទុកជាកូនហ្នឹងបាទ។

**ស៖** តើអ្នកយាមនៅក្រាំងតាចាន់ប៉ុន្មាននាក់ដែលនៅរស់សព្វថ្ងៃ ហើយដែលរស់នៅក្បែរផ្ទះលោកដែរសព្វថ្ងៃនេះនោះ? លោកអាចប្រាប់ឈ្មោះបានទេ អ្នកណាខ្លះដែលនៅរស់ដល់សព្វថ្ងៃ ហើយរស់នៅក្បែរផ្ទះលោក?

[១១:២៦:៤៣]

**ឆ៖** ប្រាប់បាន ប៉ុន្តែនៅឆ្ងាយពីផ្ទះខ្ញុំដែរ មិនជិតទេ ដីប្រហែលជាជាង១០គីឡូ សុទ្ធតែជាង១០គីឡូទាំងអស់ ជាង១០គីឡូ ៧គីឡូ ៨គីឡូ។ ប្រាប់បាន ប៉ុន្តែផ្ទះគាត់ឆ្ងាយៗពីផ្ទះខ្ញុំ។ មាន ស៊ាន់, សាំង, ស៊ីម, ឌុច បាទ នៅឆ្ងាយៗពីផ្ទះខ្ញុំដែរ បួននាក់ហ្នឹង។

**ស៖** អ៊ីចឹងគឺនៅសល់បីបួននាក់ដែរ ដែលនៅរស់ដល់សព្វថ្ងៃរស់នៅក្បែរផ្ទះលោក អ៊ីចឹងមែនទេ?

**ឆ៖** បាទ នៅបួននាក់ ប៉ុន្តែខាងនោះនៅឆ្ងាយៗអត់និយាយទេបាទ។

**ស៖** តើនៅក្នុងចំណោមអ្នកយាមនៅក្រាំងតាចាន់ហ្នឹង មានអ្នកយាមខ្លះហ្នឹងជាបងប្អូនបង្កើតឬបងប្អូនជីដូនមួយ មានទេ?

**ឆ៖** បាទ ផ្នែកកងទ័ពគឺ មានៗ។

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេតបានទៅជួបលោកជាលើកដំបូង អ្នកស៊ើបអង្កេតតុលាការយើងនេះ លោកមិនចង់និយាយជាមួយពួកគាត់ទេ។ ដូចម្សិលមិញហ្នឹង លោកបានជម្រាបជូនហើយថាលោកភ័យខ្លាច។ តើសព្វថ្ងៃនេះ តើលោកនៅតែភ័យខ្លាចដដែល ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ នៅតែភ័យ ហើយដល់មកឆ្លើយអ៊ីចឹងរឹតតែភ័យខ្លះទៀត ប៉ុន្តែក្នុងសំណួរឯកសារគឺឆ្លើយតាមឯកសារដែលខ្ញុំបាននិយាយតែការជាក់ស្តែង អត់មានឆ្លើយបំផ្លើស ឬឆ្លើយខ្វះ។ ប៉ុន្តែនៅតែ

ភ័យអ៊ីចឹង ទៅវិញក៏នៅតែភ័យ។ ភ័យថា ព្រោះគាត់រស់នៅច្រើន កាលណាខ្ញុំដើររកស៊ីយប់ព្រលប់អ៊ីចឹងទៅ វា -- ព្រោះខ្ញុំមុខរបរខ្ញុំនៅផ្ទះទេ អាជីពខ្ញុំគឺជួលរោងតុការ សម្អាង មីក្រូ ហើយម្ល៉ោះហើយ ខ្ញុំដើរយប់ព្រលប់ខ្លាចបាទ។

**ស៖** ខ្ញុំដូចជាអាន -- ខ្ញុំដូចជាធ្លាប់អានឯកសារមួយដែលលោកបានប្រាប់ថា លោកភ័យខ្លាចមែនទែនរហូតដល់មិនហ៊ានសម្រាន្តនៅផ្ទះខ្លួនឯង ទៅសម្រាន្តនៅស្រែចម្ការទៀតផង។ តើអ៊ីចឹងមែនទេ?

[១១:២៩:៥២]

**ឆ៖** បាទ ហ្នឹងពិតប្រាកដហើយ ពីឆ្នាំដំបូងគាត់ចុះទៅសម្លាសជាមួយខ្ញុំ មិនដឹងខាងណា ខ្ញុំអត់អាចចាំគាត់បានទេ ក៏មិនចាំខាងណាៗដែរ ទៅសម្លាស។ គឺខ្ញុំអត់ចង់ហ៊ាននិយាយទេ និយាយទៅវាការពិតដឹងពីខ្ញុំរស់នៅក្រាំងតាចាន់ហ្នឹង សេសសល់ពីគេមក។ ហើយបើអ៊ីចឹង អ្នកដែលកងទ័ពសល់ប៉ុន្មានក៏ដឹងរឿង ដឹងតែពីខ្ញុំដែរ។ ឥឡូវដឹងតែបែកការណ៍ពីខ្ញុំអស់ បើអ៊ីចឹងខ្ញុំខ្លាច នឹកឃើញបារម្ភខ្លាច។ ល្ងាចមិញ ខ្ញុំបានឆ្លើយពីម្សិលមិញមួយសន្ទុះមកហើយ បានល្ងាចមិញមានអារម្មណ៍មួយថាខ្ញុំជាប់គុកនៅក្រាំងតាចាន់ មានគាត់មកសម្លុតខ្ញុំទាំងយប់ យប់មិញ បាទ។ អារម្មណ៍របស់ខ្ញុំ បាទខ្ញុំអត់ចង់ឆ្លើយទេសព្វថ្ងៃ បាទ។

**ស៖** លោកអាចជម្រាបជូនតុលាការបានទេ ថាអ្នកណាគេជាអ្នកគំរាមកំហែងដល់លោក?

**ឆ៖** អត់មានអ្នកណាគំរាមខ្ញុំទេ ប៉ុន្តែខ្ញុំខ្លាចខ្លួនឯងថា សម័យនេះគឺខ្លាច ព្រោះខ្ញុំដើរយប់ព្រលប់ ហើយគាត់ក៏រស់នៅ ខ្ញុំក៏រស់នៅ ព្រោះសម័យនេះខ្ញុំត្រូវខ្លាចអ៊ីចឹង។

**ស៖** បាទឥឡូវនេះ ខ្ញុំសូមយកបញ្ជីអ្នកយាមនៅក្រាំងតាចាន់ម្តងទៀត។ ដែលសួរឈ្មោះ ស៊ាន់ ហ្នឹង គឺជាឈ្មោះអ្នកយាមមែនទេ? ស៊ាន់ ហ្នឹងជាអ្នកយាមមែនទេ?

[១១:៣១:៣៩]

**ឆ៖** បាទ ស៊ាន់ ហ្នឹង ជាកងទ័ព។ យាមផង កងទ័ពហ្នឹងៗយាម បាទ។

**ស៖** ហើយ ដាំ ហ្នឹង ឈ្មោះ ដាំ ហ្នឹង ជាយោធាកងទ័ព ឬក៏យ៉ាងណាដែរ?

**ឆ៖** ដាំ គាត់ជាកងទ័ពដែរនៅហ្នឹងមុនដំបូងបាទ។ កងទ័ពដូចគ្នា ប៉ុន្តែ ដាំ គាត់ស្លាប់ហើយ។

**ស៖** ដាំ ហ្នឹង តើពេលណាមួយនោះ គាត់បានធ្លាក់ខ្លួនជាអ្នកទោសវិញ គាត់មានធ្លាក់ខ្លួនក្លាយជាអ្នកទោសទេ?

**ឆ៖** បាទមាន។ គាត់នៅហ្នឹង គាត់មានរឿង គាត់មានរឿងខូចសីលធម៌។ ខូចសីលធម៌មិនមែនខូចសីលធម៌ជាមួយអ្នកទោសនៅកន្លែងហ្នឹងទេ។ គាត់ផ្ទះនៅពីខាងលិចគុកក្រាំងតាចាន់ហ្នឹង គាត់ខូចសីលធម៌ជាមួយគេ គេក៏ដកគាត់យកទៅដាក់នៅ២០៤ ជាមួយ តាឆេន។ ហើយទៅនៅជាមួយ តាឆេនហ្នឹង គាត់មានរឿងនៅកន្លែងហ្នឹង គេបញ្ជូនគាត់ពីកន្លែង តាឆេន មកក្រាំងតាចាន់វិញបាទ។

**ស៖** គាត់ស្លាប់នៅក្រាំងតាចាន់ ឬក៏គាត់រស់រានមានជីវិត?

**ឆ៖** បាទ គាត់ទើបតែស្លាប់ប្រហែលជារយៈកាលមិនទាន់បានពីរឆ្នាំទេ ត្រឹមមួយឆ្នាំជាង។

**ស៖** តើ ស៊ីម ហ្នឹងជាទ័ពមែនទេ?

**ឆ៖** បាទ ស៊ីម ជាកងទ័ព។

**ស៖** ហើយឈ្មោះ សឹង?

**ឆ៖** បាទ សឹង ដូចអត់ដែលឮឈ្មោះ។ មែន សឹង អត់ដែលមានសឹងទេ។

**ស៖** ប្រហែលជាខ្ញុំអានឈ្មោះមិនសូវច្បាស់ ព្រោះថាខ្ញុំអានជាភាសាបារាំង។ ឈ្មោះ សឿងបាទ។ ធ្លាប់ស្គាល់ឈ្មោះ សឿង ទេ?

[១១:៣៤:២៨]

**ឆ៖** បាទស្គាល់ សឿង។ ឥឡូវគាត់ទៅធ្វើអាចារ្យនៅព្រំដែន នៅឯសំឡូត បាទ។

**ស៖** អ៊ីចឹងបានន័យថា គាត់នៅរស់នៅឡើយទេ?

**ឆ៖** បាទគាត់នៅរស់ទេ បាទ បងសឿង ហ្នឹង បាទនិយាយពីប្រវត្តិគាត់មិនគួរណាបានទៅធ្វើអាចារ្យទេ គាត់សាហាវលេខ១ នៅក្រាំងតាចាន់។ កាចជាងគេបង្អស់ បាទនៅក្រាំងតាចាន់។

**ស៖** ហើយឈ្មោះ ទូច លោកស្គាល់ឈ្មោះ ទូច ទេ?

**ឆ៖** បាទ ស្គាល់។ គាត់ស្លាប់ហើយ។

**ស៖** អម្បាញ់មិញ លោកនិយាយអំពីឈ្មោះ កិល តើ កិល ហ្នឹងនៅរស់ទេ? ហើយតួនាទីរបស់គាត់ហ្នឹង គាត់មានតួនាទីអ្វីដែរ?

**ឆ៖** បាទគាត់ –តាកិល– ហ្នឹងគាត់ជាស្នាក់ការសម្រាប់បញ្ជូនមនុស្សមកដាក់នៅក្រាំងតាចាន់។ សព្វថ្ងៃនេះគាត់ស្លាប់ហើយ។

**ស៖** ខ្ញុំឃើញថា ឥឡូវ ខ្ញុំនៅមានសំណួរមួយចំនួនទៀត។ ឥឡូវដល់ពេលសម្រាកហើយ អ៊ីចឹងខ្ញុំសូមសួរសំណួរនៅពេលរសៀលនេះ។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម ជាទីគោរព។ ខ្ញុំគិតថាជាការល្អ គឺថាពេលចាប់ផ្ដើមនៅរសៀលនេះ អ៊ីចឹងសូមឲ្យបិទសំឡេងដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនេះ គាត់សម្ដែងមតិដោយកុំសូវភ័យពេក ព្រោះថាឃើញថាគាត់មានការព្រួយបារម្ភច្រើនណាស់។ អ៊ីចឹងសូមឲ្យបិទសំឡេង ហើយគាត់និយាយឲ្យច្បាស់លាស់ទាក់ទងទៅនឹងមន្ទីរសន្តិសុខហ្នឹង សូមធ្វើយ៉ាងណាកុំឲ្យសាធារណជនស្ដាប់សំឡេងគាត់ ពេលដែលគាត់ថ្លែងទុក្ខហ្នឹងឮ លោកប្រធាន។ នៅពេលគាត់និយាយរសៀលនេះលោកប្រធាន សូមបិទសំឡេង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរថាតើ នេះជាសំណើសុំឲ្យមានសវនាការជាសម្ងាត់ ឬក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺជាសំណួររបស់ខ្ញុំដែល។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមបញ្ជាក់សិន។តើនេះជាសំណើផ្លូវការឬក៏អត់ទេ? បើជាសំណើផ្លូវការសុំបង្ហាញមូលហេតុឲ្យបានច្បាស់លាស់បន្តិចមក ថាតើចង់សុំឲ្យមានសវនាការបែបម៉េច ហើយឲ្យមានមូលហេតុច្បាស់លាស់។

[១១:៣៧:៥៧]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ តាមការពិតសវនាការយើងអាចមានសវនាការជាសម្ងាត់ ឬក៏សវនាការជាអសាធារណៈ។ យើង -- ខ្ញុំចង់ស្នើសុំជាសវនាការអសាធារណៈ ដោយសាធារណជនអាចនៅទីនេះ ហើយគ្រាន់តែមិនឲ្យមានសំឡេងចេញទៅខាងក្រៅតែប៉ុណ្ណោះ។ មូលហេតុដោយសារថា អ្វីដែលលោក សយ សែន បានលើកអម្បាញ់មិញ អំពីការព្រួយបារម្ភអំពីសុវត្ថិភាពរបស់គាត់ ហើយម្យ៉ាងទៀតតាមការពិនិត្យមើលកន្លងមក គាត់ត្រូវបានសួរកាន់តែច្រើនឡើងៗ អំពីឈ្មោះរបស់អ្នកដែលជាកម្មាភិបាលនៅក្រាំងតាចាន់ ហើយដែលពួកគាត់នៅរស់រានមាន

ជីវិតនៅឡើយ ដែលកន្លែងនេះជាការយល់ឃើញរបស់ខ្ញុំ គឺយើងខ្ញុំ គឺយល់ថាគាត់អាចមានការព្រួយបារម្ភពាក់ព័ន្ធនឹងបញ្ហាសុវត្ថិភាពរបស់គាត់។ ដូច្នេះហើយបានយើងខ្ញុំស្នើសុំឱ្យលោកប្រធាន កាលណាមានសំណួរពាក់ព័ន្ធទៅនឹងឈ្មោះអ្នកដែលមានវត្តមាន នៅរស់រានមានជីវិតនៅឡើយ សូមធ្វើឱ្យធ្វើជាសវនាការដែលមានលក្ខណៈជាអសាធារណៈ ដែលអាចធ្វើឱ្យគាត់មានអារម្មណ៍ទុកចិត្តពាក់ព័ន្ធនឹងសុវត្ថិភាពរបស់គាត់ច្រើនជាងនៅក្នុងការឆ្លើយទៅនឹងសំណួរដែលបានសួរ។ ហើយចំពោះបញ្ហាផ្សេងៗទៀត យើងខ្ញុំនៅតែរក្សាថាទុកជា -- ផ្នែកផ្សេងៗទៀតអាចសួរក្នុងស្ថានភាពជាសវនាការសាធារណៈ ប៉ុន្តែពាក់ព័ន្ធទៅនឹងបញ្ហាឈ្មោះគឺសូម -- ហើយនិងសកម្មភាពជាក់ស្ដែងរបស់អ្នកទាំងនោះ សូមសួរជាអសាធារណៈ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ភាគីដទៃទៀត មានមតិយោបល់ដែរឬទេ លើសំណើសុំនេះ?

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា!

**លោក សួន វិសាល៖**

សូមគោរពលោកប្រធាន។ ខ្ញុំគិតថា អ្វីដែលលោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងគឺមិនសមហេតុផលទេ។ ដោយសារតែអ្វីដែលសាក្សីនេះបានបំភ្លឺ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីបានបំភ្លឺសាធារណជនអាចដឹងអស់ហើយ ដូច្នេះគ្មានអ្វី ហេតុផលណាមួយដែលត្រូវលាក់នូវអ្វីដែលគាត់ចង់និយាយនោះទេ។ ដូច្នេះសូមបដិសេធនូវអ្វីដែលស្នើសុំ។ បាទ សូមអរគុណ។

[១១:៤០:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមបន្ថែម គឺថាសំណើសុំនេះ គឺហាក់បីដូចជាមិនមានហេតុផលអី ហើយមិនស្ថិតក្នុងពេលមួយដែលសមស្របនោះទេ។ ដោយសារថា ការពាក់ព័ន្ធទៅនឹងឈ្មោះអ្នកដទៃ លោកលោកស្រីចៅក្រមក៏បានសួរសំណួរជាច្រើនពាក់ព័ន្ធទៅនឹងឈ្មោះរបស់អ្នក -- របស់ឆ្នាំគុក និងបុគ្គលិកដទៃដែរ។ លើកលែងតែមានកាលៈទេសៈពិសេសដែលបានស្នើសុំនោះទេ ទើបអាចនឹងមានការ -- ឱ្យស្នើសុំឱ្យមានសវនាការអសាធារណៈបែបនេះ។ ហើយសំណើសុំនេះ គឺស្នើសុំឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏សាក្សីផ្ទាល់តែម្ដង។ ខ្ញុំមិនឃើញថា មានការភ័យខ្លាចណាមួយជាប្រត្យក្សនោះទេនៅក្នុងពេលនេះ។ ដូច្នេះក៏ខ្ញុំសូមជំទាស់ចំពោះបញ្ហានេះដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទយល់ឃើញថា វាអាចមាការលំបាកសម្រាប់ការអនុវត្ត ផងដែរ ទាក់ទងទៅនឹងថាតើត្រូវកំណត់នៅពេលណាដែលថា ឈ្មោះមនុស្សម្នាក់ត្រូវបញ្ចេញ ឬក៏ត្រូវសួរ។ ហើយអ៊ីចឹងបានន័យថា អង្គជំនុំជម្រះត្រូវបិទ ការសវនាការជាសាធារណៈមួយរយៈ ហើយក្រោមមកបើកវិញ បើកហើយបិទ បិទហើយបើកៗ ត្រូវធ្វើទៅមកៗបែបនេះ ឬមួយក៏ត្រូវបិទ។ បានន័យថា ធ្វើសវនាការជាអសាធារណៈរហូតដល់ចប់។ អានេះជាបញ្ហាដែលខ្ញុំមើលឃើញពីការលំបាកក្នុងការអនុវត្ត។ ហើយដោយឡែកចំពោះបញ្ហាជាក់ស្ដែងទាក់ទងទៅនឹងសំណើសុំធ្វើសវនាការជាអសាធារណៈទៅលើផ្នែកខ្លះនេះ ខ្ញុំយល់ឃើញថា ហាក់ដូចជាពុំមានមូលដ្ឋានសមស្របដើម្បីធ្វើបែបនេះទេ។ ដោយសារសាក្សីបានឆ្លើយជាហូរហែរួចមកហើយ -- សូមទោស ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយជាហូរហែរួចមកហើយកន្លងមក។ ដូច្នេះ បើថាមានចំណុចណាដែលមានការព្រួយបារម្ភនោះអាហ្នឹងវាទាល់តែមានការភ័យខ្លាចជាលក្ខណៈជាក់ស្ដែងណាមួយដែលអាចកើតមានឡើងទើប អង្គជំនុំជម្រះគួរពិនិត្យទៅលើការសម្រេចឱ្យមានសវនាការជាអសាធារណៈនេះ។ បាទ សូមអរគុណ។

[១១:៤៣:០៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំយល់ចំពោះសំណួររបស់សហមេធាវីនាំមុខ។ មានវិធានជាក់លាក់នៅក្នុងចំណោមបញ្ហាជាច្រើនដែលត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ដូចជាក្នុងករណីនេះ ដែលគាត់ផ្តល់សក្ខីកម្មនៅពេលណានិយាយពាក់ព័ន្ធទៅនឹងឈ្មោះ ឆ្មាំគុក ឬក៏ឈ្មោះអ្នកទោស ឬពាក់ព័ន្ធទៅនឹងស្ថានភាពរបស់គាត់ ក្រុមគ្រួសាររបស់គាត់ស្ថិតនៅក្នុងភាពគ្រោះថ្នាក់ គឺត្រូវតែមានមូលដ្ឋានសំអាងឱ្យបានច្បាស់លាស់។ ប្រហែលជាអង្គជំនុំជម្រះត្រូវពិចារណានៅក្នុងពេលយើងសម្រាកបាយថ្ងៃត្រង់ ហើយគឺ -- ហើយក៏ក្នុងពេលនេះ គឺស្នើសុំឱ្យខាងសហមេធាវីនាំមុខគិតអំពីសំណើជាក់លាក់ណាមួយដាក់មកដល់អង្គជំនុំជម្រះ ដើម្បីឱ្យអង្គជំនុំជម្រះពិចារណា។ សូមអរគុណ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

លោកប្រធាន សំណើដែលយើងធ្វើនេះ ដោយសារការប្រព្រឹត្តទៅនៃសវនាការនេះ វាធ្វើឱ្យយើង

កើតចេញជាសំណើហ្នឹង។ ក៏ប៉ុន្តែបើ -- ព្រោះថាយើងស្នើនេះដែលថា តាមឃើញការជាក់ស្តែងនៃសវនាការហ្នឹង ហើយធ្វើស្នើហ្នឹង ដើម្បីឲ្យគាត់ហ្នឹងមានភាពកក់ក្តៅក្នុងចិត្ត ហើយយើងនឹងធ្វើការជាក់លាក់ -- បើមានសំណើជាក់លាក់យើងនឹងបន្តទៀត។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិចារណា គួរតែត្រូវបានធ្វើសំណើរួមគ្នាតែម្តង យើងបានរំឮកច្រើនលើកច្រើនសាហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ដោយថានេះមានលក្ខណៈវិសេសនៃសំណើនេះ ខ្ញុំសូមនិយាយបន្តិច។ បើសំណើរបស់ចៅក្រម ហ្វេនស៍ ខ្ញុំសុំពិចារណានឹងសំណើសិនពេលសម្រាកនេះ។ ហើយបើពេលក្រោយមកទៀត យើងនឹងធ្វើសំណើមួយដែលមានសំអាងហេតុច្បាស់លាស់ ហើយយើងនឹងបង្ហាញជូនតុលាការនៅម៉ោងមួយកន្លះលោកប្រធាន ម៉ោងដប់បីសាមសិបនាទី។ យើងពិចារណាពេលសម្រាកអាហារថ្ងៃត្រង់នេះ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ម៉ោងសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅសមរម្យដល់ សាក្សីហើយ -- ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងបុគ្គលិក ធី.ភី.អូ នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់នេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ ឲ្យបានមុនម៉ោងមួយនិងសាមសិបនាទីរសៀលនេះ។

ហើយបង្គាប់ឲ្យមន្ត្រីអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅរសៀលនេះវិញនៅវេលាម៉ោង ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤៧ នាទី ដល់ម៉ោង ១៣:៣៦ នាទី)*

[១៣:៣៦:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចសវនាការនីតិវិធីសវនាការ ហើយមុននឹងបន្តស្តាប់សក្ខីកម្មសាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងធ្វើការបង្ហាញនូវសំណើសុំរបស់ខ្លួនដែលមានបំណងធ្វើកាលពីព្រឹកមិញដើម្បីឲ្យបានច្បាស់លាស់ ដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការយកទៅពិចារណាសម្រេចលើបញ្ហានេះជាមុនមុននឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះតទៅទៀត។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីសាធារណជន និងដើមបណ្តឹងរដ្ឋប្បវេណីសាជាថ្មី។ ជាបឋមមុននឹងយើងខ្ញុំស្នើសុំលើកអំពីសំណើ ហើយនិងហេតុផលដើម្បីគាំទ្រសំណើរបស់យើងខ្ញុំនៅក្នុងការស្នើសុំឲ្យមានសវនាការជាអសាធារណៈនេះ។ យើងខ្ញុំស្នើសុំលោកប្រធានថាការលើកជាសំណើ ឬក៏ជាការលើកហេតុផល ឬក៏ជាការពិភាក្សាអំពីសំណើយើងខ្ញុំ ក៏សុំឲ្យលោកប្រធានសម្រេចថាផ្នែកនេះត្រូវធ្វើជាអសាធារណៈផងដែរ។ បន្ទាប់មកយើងខ្ញុំនឹងលើកអំពីសំណើយើងខ្ញុំ និងហេតុផលគាំទ្រផ្សេងៗទៀត។ ថាតើលោកប្រធាន និងលោក លោកស្រីចៅក្រម អនុញ្ញាតឲ្យយើងខ្ញុំលើកសំណើទាំងអស់នេះជាអសាធារណៈតែម្តង ឬក៏យ៉ាងម៉េច? ឬក៏ជាសាធារណៈ?

ខ្ញុំយល់ថាអ្វីដែលខ្ញុំនិយាយប្រហែលជាមិនទាន់បានច្បាស់លាស់។--

[១៣:៣៩:៥៨]

**ប្រធានអង្គជំនុំ៖**

ស្តាប់យល់ហើយ! ភាគីដទៃទៀតមានបញ្ហាអីទេ? ទី១ គឺសំណើដំបូងនេះ ស្នើសុំស្តាប់នូវការធ្វើសំណើសុំឲ្យធ្វើកិច្ចការជាសាធារណៈនេះ សុំពិភាក្សាដោយសវនាការអសាធារណៈ ជជែកលើ ពិភាក្សាលើសំណើសុំនេះ គឺធ្វើជាអសាធារណៈ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមានយោបល់មួយលោកប្រធានសម្រាប់រសៀលនេះ។ ខ្ញុំមានចំណាប់អារម្មណ៍ប្រសិនណាជាសំណើសុំនេះអាចមានមូលហេតុពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ ឬក៏ថាបញ្ហានេះអាចដឹងទើបតែពីរបីថ្ងៃនេះ ឬក៏យូរយាណាស់មកហើយ។ នៅក្នុងសំណើនេះថា ក្រែងលោមានការ

លបលួចធ្វើបាប ពួនស្ទាក់ធ្វើបាបដោយប្រការណាមួយ។ អ៊ីចឹងខ្ញុំសួរថា មូលហេតុនេះទើបតែដឹងថ្មីៗប៉ុន្មានថ្ងៃនេះ ឬក៏យូរយារមកហើយ?

[១៣:៤០:១៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤១:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ បានស្តាប់នូវសំណើសុំរបស់ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីនីតិវិធីនៃការបង្ហាញនូវសំណើសុំរបស់ខ្លួន ដែលមានបំណងបង្ហាញនេះ សុំធ្វើជាអសាធារណៈ។ អង្គជំនុំជម្រះយល់និងអនុញ្ញាតតាមការស្នើសុំ ដោយសារមូលហេតុលក្ខខណ្ឌ លក្ខណៈនៃការស្តាប់នូវសំណើសុំនេះ អាចមានការពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដែលគប្បីអង្គជំនុំជម្រះធ្វើជាសាធារណៈ។ ដូច្នេះ អង្គជំនុំជម្រះបង្គាប់ឲ្យទៅខាងបុគ្គលិកផ្នែកខាងសោតទស្សន៍ផ្តាច់នូវប្រព័ន្ធសំឡេងចេញទៅសាលសវនាការជាសាធារណៈ នៅខាងក្រៅ។ ហើយពេលណារួចរាល់ ប្រាប់ដំណឹងមកយើងវិញផង។

*(សវនាការអសាធារណៈផ្តើមពីម៉ោង ១៣:៤៣ នាទី ដល់ម៉ោង ១៤:២៧ នាទី)*

*(សវនាការសម្រាកពីម៉ោង ១៤:២៧ នាទី ដល់ម៉ោង ១៥:០៤ នាទី)*

[១៥:០៤:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាតទៅនេះ យើងធ្វើការជាសវនាការជាសាធារណៈ ហើយនិងប្រកាស -- ប្រគល់ -- សូមខាងផ្នែកសោតទស្សន៍បើកប្រព័ន្ធផ្សព្វផ្សាយសំឡេងទៅសាលសម្រាប់សាធារណជនវិញចុះ។ ហើយអង្គជំនុំជម្រះផ្តល់ភារកិច្ចជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីធ្វើការប្រកាសពីសម្រេចផ្ទាល់មាត់ពាក់ព័ន្ធជាមួយនឹងលើសំណើសុំរបស់ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះបានកត់សម្គាល់នៅសំណើរបស់សហមេធាវីនាំមុខ សូមឲ្យដាក់ចេញនូវវិធានការ ការពារគ្របដណ្តប់ទៅលើផ្នែកខ្លះនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា --

[១៥:០៥:៤៩]

*(មានបញ្ហាបច្ចេកទេស)*

[១៥:០៦:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីធ្វើការប្រកាសអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះចំពោះសំណើសុំធ្វើសវនាការជាអសាធារណៈរបស់ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះកត់សម្គាល់នូវសំណើសុំរបស់សហមេធាវីនាំមុខ សូមឲ្យចាត់វិធានការការពារគ្របដណ្តប់ទៅលើផ្នែកខ្លះនៃសក្ខីកម្មផ្តល់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ជាពិសេសផ្នែកពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណរបស់អតីតកម្មាភិបាលជាឆ្មាំគុកនៅក្រាំងតាចាន់ ហើយអង្គជំនុំជម្រះកត់សម្គាល់ឃើញទៀតថា វិធាន២៨ បានប្រមើលឃើញជាមុននៅរបាយការណ៍ពីផ្នែកអង្គភាពគាំពារសាក្សី និងអង្គភាពគាំពារជនរងគ្រោះស្តីអំពីការគំរាមកំហែងដល់អាយុជីវិត។ អង្គជំនុំជម្រះមិនបានទទួលព័ត៌មានចាំបាច់ដើម្បីឲ្យចេញនូវសេចក្តីសម្រេចនាពេលនេះបានទេ។ ហេតុដូច្នេះ សេចក្តីសម្រេចនេះត្រូវផ្អាកមួយអន្លើ ក៏ប៉ុន្តែការតាំងសំណួរទៅលើដើមបណ្តឹងរដ្ឋប្បវេណីនឹងបន្តទៅទៀត។ ប៉ុន្តែដើម្បីឆ្លើយតបទៅនឹងសំណើសុំឲ្យចាត់វិធានការការពារ ហើយនិងរហូតដល់ពេលសេចក្តីសម្រេចត្រូវបានចេញជាចុងក្រោយនោះ សំណើសុំទាំងឡាយ -- សំណួរទាំងពាក់ព័ន្ធទៅនឹងសំណើសុំនេះគឺមិនអនុញ្ញាតទេ។

[១៥:០៩:០០]

ប៉ុន្តែក្រោយពេលសេចក្តីសម្រេចបានចេញហើយ គឺមានន័យថា នឹងមានការសម្រេចនៅក្នុង

សេចក្ដីសម្រេចនេះ ហើយនិងសូមរំឭក និងធ្វើការកោះហៅសាក្សីនោះ គឺថានឹងអនុញ្ញាតឲ្យធ្វើបែបនេះបាន។ លោកដើមបណ្ដឹងរដ្ឋប្បវេណី តាមដែលលោកព្រួយបារម្ភនោះ រហូតដល់ពេលដែលអង្គជំនុំជម្រះនឹងជម្រាបលោកនៅពេលក្រោយ គឺថាលោកមិនចាំបាច់ឆ្លើយនូវសំណួរណាដែលពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណ កំណត់ឈ្មោះរបស់អ្នកយាមគុកនោះទេ។ ហើយបើសិនណាយល់ឃើញថាសំណួរណាវាខិតទៅជិតការចង្អុលបង្ហាញអត្តសញ្ញាណរបស់កម្មាភិបាលទាំងនោះ ក៏លោកអាចនឹងមិនឆ្លើយបានដែរ។ លោកយល់បានទេ លោកដើមបណ្ដឹងរដ្ឋប្បវេណី?

**លោក សយ សែន៖**

បាទ យល់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ សូមផ្ដល់វេទិការជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

បាទ សូមអញ្ជើញលោកចៅក្រម!

[១៥:១០:២៥]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ស៖** ខ្ញុំនឹងព្យាយាមសួរសំណួរមួយចំនួនបន្តទៀត ទោះបីជាខ្ញុំយល់ថាសំណួររបស់ខ្ញុំនឹងធ្វើឲ្យលោកមានការលំបាកក៏ដោយ។ ឥឡូវនេះខ្ញុំចង់ត្រឡប់មកសួរលោកអំពីលក្ខខណ្ឌនៃការឃុំឃាំងអ្នកទោសនៅក្រាំងតាចាន់។ ប្រសិនបើខ្ញុំស្ដាប់មិនច្រឡំនូវចម្លើយរបស់លោកទេ លោកថាមានអ្នកទោសធ្ងន់ និងអ្នកទោសស្រាល។ ចំពោះអ្នកទោសធ្ងន់ គឺគេមានដាក់ខ្នោះនៅកជើង ក៏ប៉ុន្តែអ្នកខ្លះនោះគេដាក់នៅកដៃទៅទៀត។ តើអ៊ីចឹងមែនទេលោកសាក្សី? គឺមានន័យថា អ៊ីចឹងទេអ្នកទោសធ្ងន់ហ្នឹងគេដាក់ខ្នោះនៅកដៃ ហើយនៅកជើង តើអ៊ីចឹងទេ?

**លោក សយ សែន៖**

**ឆ៖** បាទអ៊ីចឹងមែន កាលណាអ្នកទោសធ្ងន់ ក៏មិនដឹងថាធ្ងន់ហើយក៏ស្រាល បានគេនាំមកៗដល់មុនដំបូង អ៊ីចឹងគេដាក់ជើងទាំងពីរ។ ដាក់ជើងទាំងពីរហើយ ដាក់ដៃពីលើទៀត ដាក់មានរនុកដែកដាក់ដៃលើនេះមួយទៀតបាទ។

**សៈ** តើលោកអាចពន្យល់បានទេថា តើគេដាក់អ្នកទោសហ្នឹងយ៉ាងម៉េចដែរនៅក្នុងអគារហ្នឹង? គេដាក់ក្បាលអ្នកទោសនុ៎ង ឬក៏ជើងទល់គ្នាយ៉ាងម៉េច លោកអាចពន្យល់បានទេថា ជើងហើយនិងៗក្បាលហ្នឹងផ្ទៀបទៅនឹងជញ្ជាំងហ្នឹងយ៉ាងម៉េចដែរ?

**ឆៈ** បាទ បាន។ ទំហំគុកវា ៥ម៉ែត្រជាង គេធ្វើទាំងសងខាងអ៊ីចេះតែជាង១ម៉ែត្រទេ ជាង ១ម៉ែត្រទុកផ្លូវដើរកណ្ដាលដាក់ជើងសងខាង ក្បាលទល់ជញ្ជាំងសងខាង ទុកបន្លោះកណ្ដាលសម្រាប់គេសម្រាប់ចូលដើរមើលៗ គេត្រួពិនិត្យអ្នកជាប់គុក។ កងទ័ពដើរចូលពិនិត្យជាប់គុកអ៊ីចឹងគេមានរនុកខាងៗជុំវិញអូស មានត្រយូវវាផ្ដក់សងខាង បាទក្បាលទល់ជញ្ជាំងសងខាង បាទ។

[១៥:១២:៥៨]

**សៈ** ដូច្នេះ ជញ្ជាំងហ្នឹងជាជញ្ជាំងក្ដារ អ៊ីចឹងក្នុងជញ្ជាំងក្ដារហ្នឹងយើងមានឃើញរន្ធ ឬក៏មានប្រហោងអីទេ?

**ឆៈ** បាទ ជញ្ជាំងហ្នឹងគេវ៉ៃមិនឲ្យជិតប៉ុន្មានទេ គ្រាន់ដាក់គងៗគ្នា វ៉ៃហើយមានសំណាញ់លួសពី -- ផ្ទាប់ពីក្នុងមួយជាន់ទៀត នោះមួយជាន់ នេះមួយជាន់ កណ្ដាលអាដែងក្ដារ។ វាប្រហោងអាចមនុស្សដើរពីខាងមើលឃើញ តាមប្រហោងជញ្ជាំងមើលឃើញ។ អាចដើរស្គាល់ មើលឃើញស្គាល់មនុស្ស។

**សៈ** លោក កែវ ចន្ទតារ៉ា ហៅគ្រូ យ៉ាវ លោកធ្លាប់ឮឈ្មោះហ្នឹងទេ?

**ឆៈ** បាទស្គាល់ មិនត្រឹមឮទេ ស្គាល់។

**សៈ** លោកស្គាល់គាត់ហ្នឹងនៅកន្លែងណាដែរ?

**ឆៈ** គាត់ចូលទៅនៅហ្នឹងបានប្រហែលជាមិនដល់១០ថ្ងៃទេ គាត់រួចទៅវិញហើយ។ គាត់ឃុំតាភេមរាល់ថ្ងៃ សព្វថ្ងៃគាត់នៅភូមិអង្គតាភេម ឃុំអង្គតាសោម ត្រាំកក់ដូចគ្នាបាទ។

**សៈ** ម្សិលមិញ ហើយនិងព្រឹកនេះលោកនិយាយអំពីការធ្វើទារុណកម្ម ទៅលើអ្នកទោស។ លោកនិយាយអំពីការច្រកស្បោងប្លាស្ទិក និយាយអំពីការទាក់ធាក់ ហើយនិងការកៀប។ តើលោកធ្លាប់ឃើញ ឬក៏ធ្លាប់ឮគេនិយាយអំពីការធ្វើទារុណកម្មដោយប្រើអាស៊ីតដែលទេ?

**ឆៈ** បាទអាស៊ីតខ្ញុំអត់ដែលឃើញទេ ដែលឃើញតែចងស្លាបសេក ហើយចងមុខជាមួយនឹងកន្សែងៗកៅស៊ូ តែប៉ុណ្ណឹង ដល់អាស៊ីតខ្ញុំមិនដែលឃើញទេ អត់ឃើញៗតែកៅស៊ូ។

**សៈ** លោកក៏បាននិយាយអំពីការផលិតទឹកត្នោត ការធ្វើទឹកត្នោត ជាពិសេសលោកថាយកទៅ

ធ្វើទឹកត្នោតជូរ។ តើអ៊ីចឹងមែនទេ? ខ្ញុំយល់អ៊ីចឹងត្រូវទេ?

**ឆ៖** បាទ ខ្ញុំអ្នកធ្វើទឹកត្នោត បាទប៉ុន្តែត្នោតហ្នឹងខ្ញុំមុនដំបូងខ្ញុំអត់ចេះទេ ប៉ុន្តែគាត់ឲ្យខ្ញុំចេះធ្វើត្នោតហ្នឹង គាត់ឲ្យខ្ញុំ លែងឲ្យខ្ញុំនៅក្រៅ ដោយសារខ្ញុំគាត់សួរ គាត់បើកទ្វារគុកគាត់សួរថា "អ្ហែងចេះធ្វើត្នោតទេ? ខ្ញុំថាខ្ញុំចេះ" លើកដៃ ៗអ៊ីចឹងទៅគាត់អ៊ីចឹងស្អែកគាត់លែងឲ្យខ្ញុំធ្វើការទៅ គាត់សួរថា "អ្ហែងធ្វើត្នោត ទៅចងត្នោតធ្វើទៅដើមភូមិជើង ហើយភូមិលិច" គាត់ថាអ៊ីចឹង។

**ស៖** ទឹកត្នោតជូរហ្នឹង ខ្ញុំដូចជាមិនសូវយល់គេយកទៅធ្វើយ៉ាងម៉េច ហើយចុះសមាជិកហ្នឹង សមាជិកក្រាំងតាចាន់ហ្នឹងគាត់ផឹកទឹកត្នោតជូរហ្នឹងទេ?

[១៥:១៦:៤២]

**ឆ៖** បាទ ខ្ញុំពេលថ្ងៃល្ងាចហ្នឹងដាក់មកមួយបំពង់ ពីរបំពង់ឲ្យគាត់ហ្នឹង យកឲ្យគាត់យកឲ្យទៅប្រធាន។ មិនដឹងគាត់ហូបអ្នកណាខ្លះក៏ខ្ញុំអត់បានដឹងដែរ ប៉ុន្តែគាត់យកទៅកន្លែងគាត់ ពីរបំពង់ បីបំពង់។ ពេលព្រឹកឡើង ពីរបំពង់ បីបំពង់យកឲ្យគាត់រហូតបាទ។

**ស៖** ទឹកត្នោតនោះ ជាទឹកត្នោតអត់មានជាតិស្រវឹង ឬក៏មានជាតិស្រវឹង? លោកមិនបាច់ផ្តល់ឈ្មោះសមាជិកហ្នឹងទេ ក៏ប៉ុន្តែលោកធ្លាប់ឃើញសមាជិកស្រវឹងទេពេលដែលផឹកទឹកត្នោតហ្នឹងទៅ?

**ឆ៖** បាទ ទឹកត្នោតស្រវឹង ទឹកត្នោតជូរគាត់ហូបទៅស្រវឹងដែរ មានស្រវឹងអ៊ីចឹងគាត់មានសម្តីអ្នកធំៗទៅលើអ្នកដទៃៗដែរហ្នឹងឯង។

**ស៖** អ៊ីចឹងលោកឃើញច្បាស់ទេ ថាលោកឃើញថាសមាជិក ឬកម្មាភិបាលហ្នឹងគឺគាត់ស្រវឹង មិនបាច់ប្រាប់ឈ្មោះក៏បានដែរគ្រាន់តែបញ្ជាក់ថាឃើញ ឬមិនឃើញ?

**ឆ៖** បាទឃើញ។ ព្រោះខ្ញុំអ្នកធ្វើឲ្យគាត់ផ្ទាល់រឿងអីមិនឃើញ។

[១៥:១៨:១៣]

**ស៖** តើមានអ្នកទោសដែលត្រូវបានគេដាក់នៅក្នុងគុកងងឹត គឺជាគុកដែលគេជីកនៅក្នុងដី ដូចជារណ្តៅអ៊ីចឹង។ តើមានទេ? មានគុករបៀបហ្នឹងទេគុកងងឹត?

**ឆ៖** បាទមាន ៗនៅខាងដើមអម្ពិលខាងត្បូងកន្លែងសួរចម្លើយងាកមកលិចបន្តិចទៀត សម័យបច្ចុប្បន្ននៅខាងត្បូងស្តូបតម្កល់សពទុកសព្វថ្ងៃនេះបាទ។

**ស៖** ប្រហែលជាអាចមានបញ្ហាបកប្រែក៏មិនដឹង។ តើអ្នកទោសមួយចំនួនត្រូវបានគេដាក់នៅក្នុងរណ្តៅដែលគេជីករូងទៅក្នុងដី មានអ៊ីចឹងទេ?

**ឆ៖** បាទមានតែដាក់ក្នុងគុកៗក្នុងដី ក្នុងរូងក្នុងដីអត់មាន មានតែដាក់គុកក្នុងដីដែលគេជីកទៅក្រោមវា ខ្ញុំមិនអាចស្មានទេ បើស្មានដីវាមូល ជីកមូលអ៊ីចឹង វាមានតម្បាញល្អួសទៅក្រោមដីជម្រៅប្រហែលជាអាចបើមិន ៤ម៉ែត្រ ក៏៤ម៉ែត្រជាង ក៏អត់មានបីទេមានតែបួនជាង។ អ៊ីចឹងដំបូលគេធ្វើដំបូលដូចជារបៀបសម័យក្តុសឥឡូវ ធ្វើក្តុសព័ទ្ធជុំវិញអ៊ីចឹង មានមាត់ទ្វារចូល ពីផ្លូវមាត់ក្តុសទៅដល់គេដាក់ខ្សែរ៉តពីលើមួយ កាលណាវ៉ៃសួរចម្លើយអត់ឆ្លើយ គេយកទៅដាក់ហ្នឹង វ៉ៃហើយវ៉ៃទៀត អត់ឆ្លើយគេយកទៅដល់មានខ្សែ អាខ្សែព្ងួរយើងអាខ្សែព្ងួរសៗដូចសម័យមុនគេថាខ្សែព្ងួរកប៉ាល់នោះ យកមកដល់ដាក់ចងជាប់ចង្កេះហើយទម្លាក់ទៅក្រោម ទម្លាក់មកក្រោមហើយយោងអាខ្សែហ្នឹងឡើងមកលើវិញមួយសន្ទុះយោងវិញឡើងមកអ៊ីចឹងមក ទន់ខ្លួនឡេកឡាក់ៗហ្នឹងទុកទម្លាក់ទៅក្រោមមួយសន្ទុះទៀតលើកមកវិញនៅទន់ខ្លួនឡេកឡាក់ៗលែងដឹងអី អាហ្នឹងគេ -- គាត់ឲ្យខ្ញុំទៅយោងពីរនាក់ តាចិន យកមកទុកនៅកន្លែងគុកវិញបាទ។

[១៥:២០:២៩]

**ស៖** ឥឡូវនេះខ្ញុំមានសំណួរពាក់ព័ន្ធនឹងចំនួនអ្នកទោស ដែលមាននៅក្នុងអគារនីមួយៗ។ លោកនិយាយថាមានអគារមួយចំនួននៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់។ តើលោកអាចរៀបរាប់អំពីអគារនីមួយៗហ្នឹងបានទេ? ហើយអគារនីមួយហ្នឹងដាក់អ្នកទោសបានប៉ុន្មានដែរ?

**ឆ៖** បាទ អត់កំណត់។ បានន័យថាអត់កំណត់ វាមានតិចមានច្រើនៗ ហើយកាលណាច្រើនកាលណាចង្អៀតគ្នាអ៊ីចឹង កាលណាអត់ទាន់ធ្វើគុកហ្នឹងបានថែមគុកថ្មីពីរទៀត ណែន ឡើងណែនគរលើគ្នាផ្អៀងមួយប្រឡោះដែក រនុកដែកហ្នឹងវាមានគរបានរយៈកាលដាក់ដី ទំហំក្តារ មួយម៉ែត្រហ្នឹងដាក់បានបួននាក់ ដល់ពេលមនុស្សមកច្រើន គាត់ដាក់ក្តារប្រឡោះជើងហ្នឹង ស៊កជើងនឹងអាប្រឡោះជើងអាប្រឡោះត្រយូវខ្នោះហ្នឹងមួយម៉ែត្រៗហ្នឹងគឺអាចដាក់បានដល់ប្រាំពីរប្រាំបីនាក់ ក្នុងមួយប្រឡោះមួយម៉ែត្រ ម្ខាង ហ្នឹងម្ខាងប្រឡោះក្នុងមួយម៉ែត្រ។ ហ្នឹងវាអត់អាចកំណត់បានទេ ខ្ញុំម៉្យាងក៏ខ្ញុំអត់បានរាប់ខ្ញុំអត់មានសិទ្ធិអីដើររាប់ គ្រាន់តែលើកបាយលើកទឹកលើកចំណីទៅឲ្យហើយ អត់បានរាប់ទេបាទ។

**ស៖** បើតាមលោកផ្ទាល់នោះ បើសិនជាមិនអាចលោកប្រាប់ថាមិនអាចទៅ។ លោកអាចប្រហែលបានទេ? ប្រហាក់ប្រហែលថាចំនួនអ្នកទោសប្រហាក់ប្រហែលនៅក្រាំងតាចាន់ហ្នឹងប្រហែលប៉ុន្មានដែរ? លោកយល់សំណួរខ្ញុំទេ? គឺចំនួនអតិបរមាដែលអាចមាននៅរបស់អ្នកទោសនៅក្រាំងតាចាន់ក្នុងពេលតែមួយហ្នឹងអាចដាក់អ្នកទោសបានប៉ុន្មានដែរ បើគិតទៅ សរុបទៅ?

**ឆ៖** បើនិយាយថាដាក់ពេញណែនដូចខ្ញុំនិយាយអំមិញថា ក្នុងមួយម៉ែត្រប្រឡោះដែកហ្នឹង ក្នុងមួយម៉ែត្រហ្នឹង ប្រឡោះដែកមានទំពក់មួយៗ។ ក្នុងហ្នឹងរយៈកាលពីមុន កាលអត់ទាន់មនុស្សជាប់ដាក់បានមួយប្រឡោះតែពីរនាក់ បីនាក់ទេ ទូលាយបានអ្នកទោសហ្នឹងសម្រាន្តកើត ប៉ុន្តែដល់ពេលមនុស្សមកច្រើន ចាប់មកច្រើនមកវាដាក់មួយប្រឡោះហ្នឹងឡើងដល់ ៨នាក់ ឬក៏ ៩នាក់ ហើយនិង ៧នាក់ក្នុងមួយប្រឡោះ។ បើអ៊ីចឹងក្នុងមួយគុកសរុបពីរខ្សែ ពីរជួរហ្នឹងអាច ១០០ជាងក្នុងមួយគុក ១០០ជាងទៅ ២០០ តែប៉ុណ្ណឹងទេ បាទ។

[១៥:២៣:១៥]

**ស៖** ដូច្នេះលោកគិតថាក្នុងមួយគុកមួយហ្នឹងអាចមានមនុស្សរហូតទៅដល់ ២០០នាក់។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ដល់តែណែនបានអាចដាក់ចូលបាន១០០។ បើកាលណាវា ២០០នាក់ ដោយសារណែនបានបាន បើថាដាក់ជាធម្មតាដល់គុកហ្នឹងកើតថ្មីពីរមកទៀតអត់បានដល់ ២០០ ទេ។ ខ្ពង់ ១០០ ឬក៏ក្រោម ១០០បន្តិចបន្តួចហ្នឹងដល់បានកើតគុកបួនហ្នឹងណា។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទមួយផ្សេងទៀតពាក់ព័ន្ធហ្នឹងទស្សនកិច្ចរបស់មេដឹកនាំ ថ្នាក់ដឹកនាំ។ ខ្ញុំអត់និយាយពីសមាជិកក្រាំងតាចាន់ទេ ខ្ញុំចង់និយាយពីថ្នាក់ដឹកនាំដែលមកទស្សនកិច្ចនៅក្រាំងតាចាន់។ ខ្ញុំគិតថាលោកធ្លាប់ឆ្លើយរួចមកហើយ។ អ៊ីចឹងតើលោកអាចបញ្ជាក់បានទេថា តាជីម ធ្លាប់មកមន្ទីរសន្តិសុខទេ? ហើយ តាជីម ហ្នឹងគាត់មានមុខងារអ្វីដែរ?

**ឆ៖** បាទ មិនមែន តាជីម ទេ តាជឹមៗ គណៈស្រុក១០៥។ គាត់មួយខែពីរខែគាត់មកក្នុងរយៈកាលនៅក្នុងមួយខែយ៉ាងហោចក៏មួយដងដែរ តាជឹម បាទ។

**ស៖** តើគាត់មានទំនាក់ទំនងអ្វីជាមួយ តាម៉ុក ទេ?

**ឆ៖** បាទ ខាងហ្នឹងខ្ញុំអត់បានដឹងទេ ព្រោះខាងការងាររបស់គាត់ គឺខ្ញុំអ្នកទោសអត់បានទៅដឹងជាមួយគាត់ ប៉ុន្តែតែគាត់មក គាត់មិនលែងអីទាក់ទងគ្នាគាត់ មិនខានទេ គឺទាក់ទងគ្នាគាត់។

**ស៖** តើលោកដឹងទេ ថានៅពេលណាមួយនោះ តាជឹម ចេញពីស្រុកត្រាំកក់ទៅស្រុកផ្សេងទៀតមានធ្លាប់មានអ៊ីចឹង?

**ឆ៖** បាទ ដឹង។ ដឹងដោយសារតែកងទ័ពនៅហ្នឹងប្រាប់ថា តាជឹម ដូរជាគណៈស្រុកហើយ ឥឡូវទៅកាន់កាប់នៅកំពង់ចាម ចំការកៅស៊ូ ឥឡូវដូរមក បងភី ប៉ាំងពៀចម្តង និងប្រធាន -- កងទ័ព

អ្នកប្រាប់ខ្ញុំបាទ។

**ស៖** លោកក៏បាននិយាយអំពីតាម៉ុក ផងដែរ។ តើតាម៉ុកហ្នឹង គេមានហៅគាត់ថា តា១៥ ទេ?

[១៥:២៦:០៦]

**ឆ៖** បាទ កាលហ្នឹង ខ្ញុំអត់ស្គាល់គាត់ទេ ប៉ុន្តែកងទ័ពហ្នឹងអ្នកប្រាប់ – ថា "អ្អែងដែលស្គាល់តាហ្នឹងទេ?" ប៉ុន្តែគេបញ្ចូលអ្នកទោសអស់ហើយ គ្រាន់តែឡានមកដល់ អាហ្ស៊ីមកដល់ បញ្ចូលអស់ហើយ មានអាហ្ស៊ីមួយមានគ្នាពីរនាក់។ ពីរនាក់ហ្នឹង មានម្ខាងជិះពីខាងក្រោយគាត់ហ្នឹងពីរនាក់ គាត់ជិះពីខាងមុខជាមួយតៃកុង។ តៃកុងហ្នឹង ក្មេងឈរបើកឡាន អើតមើល ឈរអើតមើលអ៊ីចឹង មើលផ្លូវអត់មានអង្គុយមើលបានត្រឹមត្រូវទេ ក្មេងតូចខ្លាំងណាស់។ មកដល់ ខ្ញុំក៏អត់ដឹងដែរ គេបញ្ចូលអ្នកទោសទៅក្នុងអស់ហើយ ក៏ខ្ញុំមើលក្របីនៅនឹងខាងហ្នឹង បានកងទ័ពប្រាប់ខ្ញុំថា៖ "អ្អែងដែលស្គាល់? ថា៖ អត់ទេ។ ហ្នឹងហើយ តា១៥"។ ខ្ញុំស្គាល់គាត់ ដោយសារអាហ្នឹងដែរ។

**ស៖** លោកបានឃើញគាត់ហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** មិនចាំបានទេ យូរៗឃើញគាត់ម្តង ហើយចុងបញ្ចប់ ចុងក្រោយនេះ ឆ្នាំ៧៧ គាត់បើកឡានមកពីណាមក បីនាក់។ នីរសារពីក្រោយមួយ គាត់នៅពីមុខមួយ តៃកុងឡានមួយ ទាំងអស់បួន។ គាត់ចុះពីឡានមក ឃើញខ្ញុំនៅនឹងផ្លូវចូលកន្លែងគុកហ្នឹង គាត់មានទំពក់មួយ ប្រហែលជាអាចមិនដល់មួយម៉ែត្រទេ ទំពក់ហ្នឹង ប្រហែលជាអាចខ្ពង់ប្រាំមួយប្រាំពីរតឹក មួយម៉ែត្រធ្លាក់។ គាត់ទំពក់ហ្នឹង គោះឆ្អឹងខ្នងខ្ញុំ "អ្អែងនៅធ្វើអីហ្នឹង?" ស្រែកថាធ្វើអីហ្នឹង ខ្ញុំងាកមើលគាត់ ហើយងាកទៅជើង ដល់កងទ័ពថា "ដើរចេញឲ្យផុតទៅ" ខ្ញុំនៅផ្លូវ ដឹកក្របី ដឹកសេះទេកាលហ្នឹង នៅផ្លូវ។ ថ្ងៃ ខ្ពង់ប្រហែលជាមិនអាចចាំបានទេ ថ្ងៃម៉ោងអីក៏មិនចាំដែរ ថ្ងៃរសៀល បាទ។ អត់បានចាំម៉ោង ដឹងថាថ្ងៃរសៀល។

[១៥:២៧:៥៣]

**ស៖** លោកធ្លាប់ឮឈ្មោះ តាភី ទេ? គាត់ហ្នឹង គាត់មានជើងតែម្ខាងទេ? ធ្លាប់ឮទេ តាភី?

**ឆ៖** បាទ ខ្ញុំបាននិយាយពីមុនហ្នឹង ភី ហ្នឹងហើយ ហៅថា ភី បុំងពៀច។ ជើងគាត់ទាំងពីរប៉ុន្តែស្វិតម្ខាង។ ស្គាល់ច្បាស់ណាស់ មិនត្រឹមតែមិនបានឮទេ ស្គាល់ច្បាស់តែម្តង។

**ស៖** គាត់ធ្លាប់មកក្រាំងតាចាន់ទេ តាភី ទេហ្នឹង? ហើយគាត់មានមុខងារអ្វីដែរ?

**ឆ៖** គាត់ជា -- មុនដំបូង ខ្ញុំអត់ដឹងមុខងារគាត់ជាស្អីទេ គាត់នៅមន្ទីរព្រៃតាដុក។ មន្ទីរព្រៃតាដុកហ្នឹង គាត់ចេញពីមន្ទីរព្រៃតាដុក គាត់នៅ ចុះឡើងៗហ្នឹង ដល់មកចុងក្រោយ ដឹងគាត់ ដល់តាជឹម

ឡើងទៅជាគណៈស្រុកកំពង់ចាមចម្ការកៅស៊ូ គាត់មកបានធ្វើគណៈស្រុក១០៥ហ្នឹងវិញ –តាភី បុាំងពៀច– ប៉ុន្តែកន្លែងក្រាំងតាចាន់ ចន្លោះថ្ងៃតិចណាស់ យ៉ាងហោចក្នុងមួយអាទិត្យ គាត់មកបីដង និងបួនដង អត់ខានទេ បាទ ភី បុាំងពៀច។

[១៥:២៩:០៥]

**ស៖** អ៊ីចឹងមានន័យថា គាត់ពិតជាធ្លាប់មកក្រាំងតាចាន់។ មែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកធ្លាប់ឮឈ្មោះ យាយបូ ទេ?

**ឆ៖** បាទ មិនត្រឹមឮទេ ស្គាល់ទៀត។ ស្គាល់ យាយបូ ស្រុកកំណើតគាត់ ក៏ខ្ញុំស្គាល់ដែរបាទ។

**ស៖** តើគាត់មានទំនាក់ទំនងអ្វីជាមួយ តាម៉ុក ទេ? ហើយគាត់ -- យាយបូ ហ្នឹងធ្លាប់មកក្រាំងតាចាន់ទេ?

**ឆ៖** អត់ដែលឃើញគាត់មកទេ។ ស្គាល់ដោយសារកាលខ្ញុំនៅតូចៗ នៅផ្ទះគាត់។ ដើរធ្វើ -- កាលហ្នឹងគាត់ថាធ្វើរណសិរ្សរួបរួមជាតិកម្ពុជាឆ្នាំ៧២។ ស្គាល់ យាយបូ ដោយសារឆ្នាំ៧២ហ្នឹងបាទ។

**ស៖** ដូច្នេះ គឺមានន័យថាបន្ទាប់មកទៀត លោកអត់ធ្លាប់ឃើញ យាយបូ ហ្នឹងនៅក្រាំងតាចាន់ទេ។ អ៊ីចឹងទេ?

**ឆ៖** ដូចអត់ដែលឃើញគាត់មកដែរ យាយបូ ហ្នឹង ហើយក៏ប្រហែលពេលណាខ្ញុំក៏មិនឃើញក៏មិនដឹងដែរ ប៉ុន្តែរឿងថា ខ្ញុំមិនដឹង ដូចប្រហែល -- មិនដែលឃើញគាត់ដែរ។

**ស៖** តាទិត្យ លោកធ្លាប់ឮទេឈ្មោះ តាទិត្យ?

**ឆ៖** បាទដែលឮ។

**ស៖** លោកធ្លាប់ឃើញ តាទិត្យ នៅក្រាំងតាចាន់ទេ?

**ឆ៖** បាទអត់ដែលឃើញទេ អត់ដែលឃើញមកផង។

[១៥:៣១:១០]

**ស៖** លោកអាចឆ្លើយម្តងទៀតបានទេ? អម្បាញ់មិញនេះចម្លើយរបស់លោកមិនត្រូវបានបកប្រែទេ។

**ឆ៖** បាទ តាទិត្យ ដែលឮ ប៉ុន្តែគាត់អត់ដែលមក អត់ដែលឃើញទេ ខ្ញុំអត់ដែលឃើញទេ ដែលឮឈ្មោះ បាទ។

**សៈ** តើលោកធ្លាប់ឃើញថ្នាក់ដឹកនាំស្រុក ឬក៏ថ្នាក់លើខាងតំបន់ ឬក៏ខាងភូមិភាគ ឬក៏មេដឹកនាំណាផ្សេងទៀត មកក្រាំងតាចាន់ ទេ?

**ឆះ** បាទអត់ៗដែលឃើញទេ ឃើញតែតាភូមិភាគមួយ–តា១៥មួយ–ឃើញតែម្តងហ្នឹងបាទ ឃើញម្តងឬក៏ពីរដង បាទតែប៉ុណ្ណឹង ឃើញតែម្នាក់ហ្នឹង។

**សៈ** ចុះឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលត្រូវបានគេស្គាល់ថាជាប្រធានមន្ទីរ ស-២១ នេះ លោកធ្លាប់ស្គាល់ទេ កាំង ហ្កេកអ៊ាវ ហៅ ឌុច?

**ឆះ** បាទ អត់ទេ។

**សៈ** ហើយគាត់ធ្លាប់មកក្រាំងតាចាន់ ទេ?

**ឆះ** បាទអត់ដែលឃើញផង។ ទើបតែឮឈ្មោះឥឡូវ ពីមុនអត់ដែលឃើញផងគាត់។

[១៥:៣២:៤៧]

**សៈ** ខ្ញុំនឹងបញ្ចប់សំណួររបស់ខ្ញុំ ដោយព្យាយាមយល់អំពីការលំបាករបស់លោក ដែលលោកត្រូវជម្នះ បន្ទាប់ពីគេឃុំឃាំងលោកនៅក្រាំងតាចាន់។ លោកអាចនិយាយអំពីបញ្ហារូបកាយ ផ្លូវកាយ ឬក៏បញ្ហាផ្លូវចិត្តដែលលោកទទួលរង ឧទាហរណ៍ដូចជាមានការបាក់ស្បាត ឬក៏មានការប៉ះទង្គិចផ្លូវចិត្តបែបណា នៅពេលដែលលោកជាប់ឃុំនៅក្រាំងតាចាន់នោះ? សូមលោកជម្រាបជូនតុលាការ។

**ឆះ** បាទ ជីវប្រវត្តិរូបរបស់ខ្ញុំ ដូចខ្ញុំបានប្រាប់តុលាការថា ខ្ញុំអត់ចង់និយាយទេជីវប្រវត្តិសាស្ត្រពីជំនាន់គុកនៅក្រាំងតាចាន់ហ្នឹង។ កាលណានិយាយ ឲ្យរំភើបថ្មីអ៊ីចឹងទៅគឺថា ជីវិតរបស់ខ្ញុំវាដូចថារសាយអណ្តែតអណ្តូងទៅ ថាដូចលែងដឹងលិច លែងដឹងកើត បានខ្ញុំអត់ចង់និយាយ វាកំសត់និងវេទនាហួសនិស្ស័យ ប៉ុន្តែមកសម័យបច្ចុប្បន្ន សរសើរខ្លួនឯងថា គួរណាបានរស់ទល់សម័យរាល់ថ្ងៃដែរ បាទ។ បាទខ្ញុំអត់ចង់និយាយប្រាប់ទាំងអស់ ក្រែងតែកូនចៅខ្ញុំ ក៏ខ្ញុំអត់ចង់ប្រាប់ដែររាល់ថ្ងៃ អត់ចង់ប្រាប់ប្រវត្តិសាស្ត្រឪពុកជួរចត់ដល់ប៉ុណ្ណឹង។ នឹកឃើញថាមិនចង់ឲ្យកូនវេទនាដោយសារតាមឪពុកដែររាល់ថ្ងៃនេះ។

[១៥:៣៤:១១]

**សៈ** ខ្ញុំដឹងថាហើយថានេះជាការឈឺចាប់ចំពោះលោក ក៏ប៉ុន្តែលោកអាចជម្រាបបានទេ ឧទាហរណ៍ថាការធ្វើ ការខំចងចាំឡើងវិញហ្នឹង ធ្វើឲ្យលោកសម្រាន្តមិនលក់ ធ្វើឲ្យលោកពិបាកទប់អារម្មណ៍ ឬមួយក៏នៅពេលដែលខំនឹកអ៊ីចឹងទៅ ធ្វើឲ្យលោកអស់សង្ឃឹមខ្លាំង លោកមានការលំបាកក្នុងការប្រមូលអារម្មណ៍ដើម្បីធ្វើការ។ លោកអាចរៀបរាប់បន្តិចបានទេ? លោកធ្លាប់ជួបបញ្ហាទាំងអស់ហ្នឹងទេនៅ

ពេលដែលលោកនឹកឃើញអំពីអតីតកាលដ៏ឈឺចាប់របស់លោកនោះ?

**ឆ៖** បាទ កាលណា ខ្ញុំអត់រំឭកឡើងពីបញ្ហាការជួចត់ពីសម័យមុន គឺបំភ្លេចចោលឲ្យអស់ គឺខ្ញុំសប្បាយ។ តែបើមករំឭកនូវរឿងការងារអតីតកន្លងមក ពីម្សិលមិញរហូតដល់ថ្ងៃហ្នឹង ហើយល្ងាចមិញនេះគឺខ្ញុំអត់បានស្នាក់បានពេញភ្នែក។ នឹកឃើញថា ខ្ញុំស្រមៃឃើញថាខ្ញុំនៅក្រាំងតាចាន់ ដូចឈ្មោះគាត់ប្រធានមន្ទីរគាត់ស្រែកហៅខ្ញុំ ឲ្យទៅដាក់ទឹកឆ្នោតជូឲ្យគាត់អ៊ីចឹងល្ងាចមិញ។ គាត់ស្រែកថា "អ្អែងតោះទៅភ្ជួមិជើងទៅដាក់ទឹកឆ្នោតឲ្យអញ!" គាត់ស្រែកដាក់ខ្ញុំអ៊ីចឹង។ ខ្ញុំនឹកឃើញស្រមៃ ខ្ញុំអត់ចង់នឹកឃើញអីទាំងអស់រាល់ថ្ងៃ។ អត់ចង់ឃើញ អត់ចង់បានដឹងឮអីទាំងអស់។ ពីសម័យជួចត់រ៉ាយរ៉ាប់នៅតុលាការទាំងអស់នេះ គឺខ្ញុំវែងណាស់ ហើយខ្ញុំក៏វាការជួចត់ភ្លេចបាត់ក៏ខ្លះ នៅខ្លះ ចាំខ្លះ អត់ខ្លះដែរ វាយូរឆ្នាំពេក ៤១ឆ្នាំហើយ។ វាអាចភ្លេចបានខ្លះហើយ។ តាំងពី៧៤ ដល់ឥឡូវនេះ ៤១ឆ្នាំគត់។ កាលណា អង្គុយគិតយូរៗបាននឹកឃើញមួយវគ្គទៀតៗ អ៊ីចឹងទៅបាទ។

**ស៖** តើលោកធ្លាប់យល់សប្តិអាក្រក់ ហើយភ្ញាក់កណ្តាលយប់ថា គេមករកលោក មកនាំលោកទៅក្រាំងតាចាន់អ៊ីចឹង។ ធ្លាប់យល់សប្តិអាក្រក់អ៊ីចឹងទេ?

[១៥:៣៦:៣៥]

**ឆ៖** មាន មានពិតប្រាកដ។ មានលុះត្រាតែ អស់លោកៗខាងកាសែតគាត់ទៅជួប។ ទៅដល់ក្រាំងតាចាន់ មានឈ្មោះខ្ញុំនៅហ្នឹង។ សយ សែន ជាអ្នកអតីតជាប់គុកក្រាំងតាចាន់ឆ្នាំ១៩៧៤ អ៊ីចឹងគេសួរផ្ទះនៅណាៗ គេសួរដេញហេតុ អ្នកនៅហ្នឹងចេះតែប្រាប់មករកផ្ទះឃើញ។ កាលណាគាត់ទៅសម្ភាសអ៊ីចឹងយប់ឡើងបារម្ភនឹកឃើញនៅក្រាំងតាចាន់រហូត។ បើគាត់អត់សម្ភាសការងារបាត់អ្វីៗឬមួយក្រុមការងារផ្សេងៗអត់សម្ភាស គឺខ្ញុំអត់បាននឹកឃើញ។ ខ្ញុំបានពីឆ្នាំទៅមួយ ខាងអង្គការ ធី.ភី.អូ គាត់យកមកបណ្តុះបណ្តាលលេងជាក្រុមជួយខ្លួនឯង ខ្ញុំបំភ្លេចចោលរឿងហ្នឹងបានយូរអង្វែង យូរឆ្នាំដែរហើយដែលអត់សូវនឹកនាបញ្ហាហ្នឹង។ ហើយយប់មួយនោះ ផ្នែកអង្គការណាទៅសម្ភាស ខ្ញុំក៏អត់បានស្គាល់គាត់ដែរ។ ខ្ញុំជាប់អ្នករកស៊ី។ សម្ភាសខ្ញុំកំពុងឡើងរោង ឡើងតុការគេ គាត់យកផ្លែមីក្រូ ដើរសម្ភាសខ្ញុំនៅយ៉ាងម៉េចមួយ យ៉ាងម៉េចពីរ ហើយខ្ញុំចេះតែធ្វើ ចេះតម្លើងរោង។ យប់ឡើងខ្ញុំស្រែកឡើងរបើកផ្ទះពេញផ្ទះ ប្រពន្ធខ្ញុំឡើងគុកអង្អែលឲ្យដឹង ស្រែកធ្វើអី? ថាខ្ញុំគេហៅទៅក្រាំងតាចាន់។ បានថាខ្ញុំអត់ចង់ឮអី អត់ចង់ដឹងសម័យបច្ចុប្បន្ន ខ្ញុំមិនចង់ឃើញអ្វីទាំងអស់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណីដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ។

សូមអរគុណ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដែលដំបូងនេះគឺក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន

[១៥:៣៨:៣៩]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងរយៈពេល ២៥នាទីទៀតនេះ ខ្ញុំសួរទៅលើបញ្ហាមួយចំនួនទាក់ទងទៅនឹងប្រវត្តិរូបរបស់លោក ប្រវត្តិផ្ទាល់ខ្លួនរបស់លោក។ បញ្ហាទី១ គឺអំពីអាយុរបស់លោក។ តើត្រឹមត្រូវទេ ដែលថាលោកកើតនៅខែមករា ឆ្នាំ១៩៥៨ តើត្រឹមត្រូវទេ?

**ប្រធានអង្គជំនុំ៖**

នែ៎ៗ បញ្ហាបកប្រែភាសា លោកនិយាយឮតែម្នាក់ឯង។ ផ្អាកបន្តិចសិនណ៎ា។

ផ្អាកសិនលោក កូប៉េ។ អង្គុយចុះសិនទៅ បើមានបញ្ហាបកប្រែភាសា។

សូមអញ្ជើញលោក សយ សែន ឆ្លើយ!

**លោក សយ សែន៖**

**ឆ៖** បាទ ខ្ញុំមិនអាចចាំឆ្នាំកំណើតរបស់ខ្ញុំទេ។ ចាំបានតែអាយុ ៗហ្នឹង កាលឆ្នាំខ្ញុំនៅជាប់ហ្នឹង បើមិន -- អាច១៥-១៦ ប៉ុន្តែសម័យបច្ចុប្បន្ននេះ ខ្ញុំ៥៧។ ព្រោះម៉ែខ្ញុំថា "អ្នែងអាយុ៥៧" បាទ ប៉ុណ្ណឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ហ្នឹងក៏ខ្ញុំដកទៅឃើញថាអ៊ីចឹងដែរនៅពេលដែលលោកថាត្រូវ

បានចាប់ខ្លួននៅក្នុងឆ្នាំ៧៤ គឺលោកអាយុប្រហែលជា -- កាលនោះប្រហែលជា១៤ឆ្នាំ។ ពីម្សិលមិញ លោកបានផ្តល់សក្ខីកម្មថា នៅពេលនោះមានអាយុ១០ឆ្នាំ ហើយជាមួយ -- ហើយនៅពេលលោកទៅដល់ក្រាំងតាចាន់នៅឆ្នាំ១៩៧៤ លោកមានអាយុប្រហែលជា១៦ឆ្នាំ។ តើត្រឹមត្រូវទេ?

[១៥:៤១:១៦]

**ឆ៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំទៅនៅក្រាំងតាចាន់បើមិន១៥, ១៦បាទ ប៉ុណ្ណឹងបាទ។

**ស៖** ឥឡូវនេះ ខ្ញុំសូមសំណួរលោកពីរបីសំណួរអំពីមនុស្សមួយចំនួនដែលលោកបានឆ្លើយពីខាងដើម។ ពីខាងដើមលោកឆ្លើយថា មានយាយ -- លោកឆ្លើយថា មានឈ្មោះយាយញ៉ុ។ តើលោកមានចាំថាលោកឆ្លើយថាអ៊ីចឹងទេ?

**ឆ៖** បាទ ចាំ – យាយញ៉ុ។

**ស៖** ហើយព្រឹកមិញនេះ នៅពេលលោកឆ្លើយទៅកាន់តំណាងសហព្រះរាជអាជ្ញាលោកបាននិយាយថា អួន សេង គឺជាប្តីរបស់ យាយចាន់ នេះបាទ។ ថាតើលោកចាំថាឆ្លើយថាអ៊ីចឹងទេ? តើលោកនៅប្រកាន់យកចម្លើយនេះទេ?

**ឆ៖** បាទ សូមម្តងទៀត ខ្ញុំស្តាប់អត់ទាន់ទេ។

**ស៖** ព្រឹកមិញនេះ នៅពេលលោកឆ្លើយទៅកាន់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកបានឆ្លើយថា ប្តីរបស់ យាយញ៉ុ គឺឈ្មោះ ហ៊ុន សេង។ តើលោកនៅប្រកាន់យកចម្លើយនេះឬទេ?

**ឆ៖** បាទ ឈ្មោះគាត់ពិត គឺខ្ញុំអត់បានដឹងទេ។ ឈ្មោះ សេង មិនបានដឹងទេ ឈ្មោះ សេង គឺមានប្តីគាត់នេះឈ្មោះ តា -- អាហ្នឹងឈ្មោះគាត់ខាងក្រោយទេ បើឈ្មោះហៅនៅកន្លែងគុកនុំងមិនមែនហៅឈ្មោះ សេង ហ្នឹងទេ ប្តីយាយញ៉ុ។ ខ្ញុំអាចភ្លេចប្តីគាត់បាទ។

[១៥:៤៣:៤១]

**ស៖** តើថា -- តើអាចនិយាយបានថា យាយញ៉ុ ខ្លួនឯងនេះគឺជាឈ្មោះ ហ៊ុន សេង ហ្នឹងបានទេ?

**ឆ៖** មិនទេ។ ហ៊ុន សេង ហ្នឹងកូនគាត់។ យាយញ៉ុ ផ្សេង។

**ស៖** តើមានអ្នកណាម្នាក់ទៀត ដែលមានឈ្មោះជាយាយញ៉ុ ហើយហៅ ឬក៏យាយញ៉ុ ក៏ជាឈ្មោះ គឹម សេង ហ្នឹងដែរទេ? មានអ្នកផ្សេងពីហ្នឹងទេ?

**ឆ៖** អត់មានទេ។ មានតែយាយញ៉ុ មួយ។ សេង ហ្នឹងផ្សេងទៀត ហ្នឹងកូនគាត់។

**ស៖** តើ យាយញ៉ុ បានរៀបការជាមួយបុរសម្នាក់ឈ្មោះ មាស សុគុន ទេ?

**ឆ៖** បាទ ប្ដីគាត់ឈ្មោះ តាគុន។ ខ្ញុំច្រឡំកូនប្រសារបស់គាត់ឈ្មោះ សេង – ប្ដីអ៊ីវ៉ាត់ បាទ។ ប៉ុន្តែក្នុង ឥឡូវនេះខ្ញុំអត់បានដឹងពីនាមត្រកូលរបស់គាត់ ដឹងថា តាគុន បាទ ហ្នឹងប្ដីប្រពន្ធគាត់ពិតប្រាកដ ហើយ បាទ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកច្បាស់ទេថាប្ដីរបស់ យាយញ៉ូ មិនមែនឈ្មោះ មាស គុន ទេហ្អី?

**ឆ៖** តាគុន ពិតប្រាកដ អត់មានក្លែងក្លាយ ក៏អត់បន្លំទៀត បាទ។

**ស៖** តើលោកស្គាលកូនៗរបស់ឈ្មោះ មាស គុន ហៅ ហ៊ុន សេង ហ្នឹងទេ ហើយនិង យាយញ៉ូ ហ្នឹងទេ ស្គាល់កូនៗរបស់ពួកគាត់ហ្នឹងទេ?

**ឆ៖** ស្គាល់តែអ្នកនៅជាប់នោះហ្នឹងទេ បើអ្នកនៅតាមមូលដ្ឋាននេះខ្ញុំអត់ស្គាល់ទេ ស្គាល់តែអ្នក នៅគុកក្រាំងតាចាន់ស្គាល់ បាទ។

[១៥:៤៥:០២]

**ស៖** តើលោកអាចរៀបរាប់ឈ្មោះអ្នកដែលលោកបានស្គាល់ ដែលគេឃុំខ្លួនហ្នឹងបានទេ ជូនអង្គ ជំនុំជម្រះហ្នឹងបានទេ?

**ឆ៖** បាន ប៉ុន្តែក្មេងមីមួយចុងក្រោយតូចជាងគេ ខ្ញុំមិនអាចចាំឈ្មោះ មិនដឹងឈ្មោះៗអី ព្រោះ នៅហ្នឹងគេហៅឈ្មោះ មីល្អិត ហើយមកដល់សម័យបច្ចុប្បន្នមិនដឹងឈ្មោះអីទេ មីហ្នឹងតូចជាងគេកូន យាយញ៉ូ។ ពីមុនមក អ៊ីវ៉ាត់ៗ, អាខា, អាខុម ហើយមីល្អិតបាទ។ ហើយកូនប្រសាមួយទៀត កូនប្រសា ប្ដីអ៊ីវ៉ាត់ហ្នឹងមួយទៀតបាទ។

**ស៖** បាទ នៅពេលដែលលោកនិយាយឈ្មោះ អាខា អ៊ីចឹង តើលោកសំដៅទៅឈ្មោះមាស សុខាហ្នឹងអី?

**ឆ៖** បាទហ្នឹងហើយបាទ។

**ស៖** តើប្អូនស្រីរបស់ មាស សុខា ត្រូវបានឃុំខ្លួននៅទីនោះដែរឬទេ? គឺគាត់ឈ្មោះ មាស សាវ៉ាត់។

**ឆ៖** បាទ ហ្នឹងមិនមែនជាប្អូនទេ ជាបងបាទ មិនមែនជាប្អូនទេ ជាបងៗអាខាហ្នឹងទៀត បាទ។ មាស សាវ៉ាត ហ្នឹងបង អាខា។

**ស៖** បាទ សូមអរគុណ។ ប្រហែលជាបងអ៊ីចឹងហើយ។ ខ្ញុំសូមសួរបន្ថែមបន្តិចអំពីបងស្រី

ឈ្មោះ មាស សារ៉ាត នេះ។ ខ្ញុំនឹងត្រឡប់មកសួរអំពីព្រឹត្តការណ៍របស់គាត់នៅថ្ងៃស្អែក។ តើមួយណាឈ្មោះរតនា ឈ្មោះរ៉ាត់ ឬមួយណាដែលលោកបាននិយាយពាក់ព័ន្ធទៅនឹងព្រឹត្តការណ៍ចាប់រំលោភ ដោយការប្រើគ្រាប់ សេវេនធីណៃ គឺតើៗលោកសំដៅឈ្មោះមួយហ្នឹង?

**ឆ៖** បាទ មានពីរ។ អីរ៉ាត់ ហ្នឹង គាត់គ្រាន់តែចាប់ជាលេងឡោះនាយអាយអីតិចតួចទេ។ បើជាអ្នកកងចល័តពីរនាក់ហ្នឹង អាហ្នឹងបាន គាត់ចាប់រំលោភហើយ បានគាត់យកគ្រាប់ក្បាលម៉ាស៊ីនទៅញាត់ស្ត្រីហ្នឹងទៀតបាទ។ ហ្នឹងវាមានពីរផ្សេងគ្នាបាទ។

[១៥:៤៩:១៧]

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមបង្ហាញចម្លើយរបស់លោកមួយដែលឆ្លើយជូនមជ្ឈ-មណ្ឌលឯកសារកម្ពុជា គឺ E3/4846, ERN អង់គ្លេស 00527774, ហើយខ្មែរ 00527724 នៅត្រង់ពាក់កណ្ដាលទំព័រនេះ លោកបាននិយាយអំពីការរំលោភស្ត្រីពីរនាក់ដោយប្រើក្បាលគ្រាប់សេវេនធីណៃហើយនៅចុងក្រោយនៃទំព័រនេះលោកបាននិយាយដូចតទៅនេះ៖ “ខ្ញុំដឹងថានៅភូមិឧត្ដមសុរិយា ភូមិឃុំឧត្ដមសុរិយា ឌុច បានរំលោភអីរ៉ាត់ ហើយក្នុងពេលហ្នឹងគឺ ឌុចតូច ក៏នៅទីនោះដែរ គាត់មានកូនមួយរស់នៅសព្វថ្ងៃរស់នៅភ្នំពេញ និងធ្វើការនៅទីក្រុងភ្នំពេញ--

**ប្រធានអង្គជំនុំ៖**

ម៉េចមានការអី? សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ខ្ញុំគិតថានៅពេលដែលលោកសួរសំណួរៗហ្នឹងមិនត្រូវពាក់ព័ន្ធឈ្មោះសមាជិកបុគ្គលិកនៅក្រាំងតាចាន់ទេ នេះគឺលើកលែងតែខ្ញុំច្រឡំ ក៏ប៉ុន្តែលោកកំពុងតែនិយាយអំពីឈ្មោះហើយដូច្នេះយើងបានពន្យល់ច្បាស់ហើយ បើសិនជាលោកនៅតែធ្វើអីចឹង គឺយើងពិបាកនឹងបន្តទៀតណាស់លោក កូប៉េ។

[១៥:៥២:២៣]

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំព្យាយាមប្រើហៅថា អ៊ិច(X) អីចឹង។ ដូច្នេះចម្លើយរបស់លោកបានឆ្លើយថា “គឺគាត់មានកូនម្នាក់សព្វថ្ងៃរស់នៅនិងធ្វើការនៅទីក្រុងភ្នំពេញ គាត់ជាប់គុកនោះជាមួយខ្ញុំ, រ៉ាត់ និងយាយញ៉ នៅរស់រៀនមានជីវិតនៅឡើយ” ហើយសំណួរ យាយញ៉ គឺជាម្ដាយរបស់ រ៉ាត់។ ដូច្នេះសំណួររបស់ខ្ញុំគឺ

តើ រ៉ាត់ ដែលលោកកំពុងនិយាយនេះ គឺជាកូនស្រីរបស់យាយញ៉ូ ដែលជាឈ្មោះតែមួយឈ្មោះ មាស សារ៉ាត់ ហ្នឹងឬមិនមែនទេ?

**ឆ៖** ឈ្មោះតែមួយពិតប្រាកដគឺពីមុនគេហៅថា ម៉ែអាបេ ប៉ុន្តែឥឡូវគេហៅដល់ចុងឈ្មោះនាម ត្រកូលមកមាន អ៊ីរ៉ាត់ ប៉ុន្តែពីមុនគេហៅថា ម៉ែអាបេៗ នេះមាននៅធ្វើការនៅភ្នំពេញសព្វថ្ងៃនេះបាទ អាហ្នឹងកូន អ៊ីរ៉ាត់ បង្កើត។

**ស៖** សូមសួរបញ្ជាក់ដូច្នេះ មាស សារ៉ាត់ ឬក៏ រតនា នេះគឺជាបងស្រីរបស់មាស សុខា។ សំណួររបស់ខ្ញុំ តើ មាស សារ៉ាត់ ឬរតនា ឬរ៉ាត់ នៅរស់រៀនមានជីវិតឬទេសព្វថ្ងៃនេះ?

**ឆ៖** បាទបើ អ៊ីរ៉ាត់ ហ្នឹងនៅបាទ។

**ស៖** តើលោកដឹងថាគាត់រស់នៅឯណាដែរសព្វថ្ងៃហ្នឹង?

**ឆ៖** បាទបានដឹងពី ពីរបីឆ្នាំគាត់ទៅផ្ទះខ្ញុំ ខាងអាខាហ្នឹងវាទៅផ្ទះខ្ញុំ ប្រាប់ថាបងវានៅឯសហរដ្ឋ ឯណោះបាទ អ៊ីរ៉ាត់ហ្នឹងគាត់នៅសហរដ្ឋ។

[១៥:៥៣:៣០]

**ស៖** ដូច្នេះ មាស សារ៉ាត់ ឬក៏ រ៉ាត់ នៅរស់រៀនមានជីវិតនៅឡើយ ហើយសព្វថ្ងៃរស់នៅឯ សហរដ្ឋអាមេរិក។ តើខ្ញុំស្តាប់លោកហ្នឹងត្រឹមត្រូវទេ?

**ឆ៖** បាទ។

**ស៖** ហើយថាតើ មាស សារ៉ាត់ មានរៀបការជាមួយបុរសម្នាក់ឈ្មោះ មុំ ប៊ុន ហ្នឹងឬក៏អត់ទេ?

**ឆ៖** បាទ អាហ្នឹងមិនមែន មុំ ប៊ុន ទេ មុំ ហឿន បាទ ឪអាបេ ម៉ែអាបេ ឪអាបេអាហ្នឹងបាទ។

**ស៖** តើលោកមានដឹងរឿងអ្វីបន្ថែមទៀតទេ អំពីឈ្មោះ មុំ ហឿន នេះ?

**ឆ៖** បាទអត់ដឹងផង បើគាត់ទៅជាប់បានប្រហែលជា -- ពីរនាក់ឪហើយនិងកូន កូនប្រសានិង ឪក្មេកទៅជាប់មិនបានប្រហែល ដូចមិនបានមួយខែផង គេវៃស្លួរចម្លើយស្តាប់ទាំងពីរៗ ខ្ញុំអ្នកយកសព គាត់ទៅទុកនៅពីរបងនៅខាងត្បូង ខ្ញុំដាំដូងពីរដើមនៅពីលើហ្នឹងបាទ។ ពូហឿន ហើយនិង តាគុន ពីរនាក់ ហ្នឹង។

**ស៖** តើលោកមានដឹងអ្វីបន្ថែមទៀតអំពីឈ្មោះ មុំ ហឿន នេះទេ? ឧទាហរណ៍ដូចជាថា ហេតុអ្វី បានជាគាត់ត្រូវបានគេចាប់ខ្លួន ហើយចាប់ខ្លួននៅពេលណា?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេហ្នឹង ដឹងតែគេបញ្ជូនទៅដាក់គុកហ្នឹង ខ្ញុំអត់បានសួរគេ ព្រោះខ្ញុំវ័យក្មេង

ណាស់ ខ្ញុំតាំងនាមខ្ញុំជាអ្នកទោស ខ្ញុំអត់មានសិទ្ធិអីសួរទេ បានតែជាប់គុកជាប់គ្នាហ្នឹងចេះតែសួរថា នៅភូមិណា ស្រុកណា ឃុំណា តែប៉ុណ្ណឹងទេបាទ។

**ស៖** លោកចាំទេថា មុំ បឿន ត្រូវគេចាប់ខ្លួននៅពេលណាដែរ?

**ឆ៖** បាទ អត់ដឹងទេហ្នឹង យប់ឡើងព្រលឹមឡើងបានខ្ញុំឃើញ ព្រោះដាក់គុកខុសគ្នា។ គាត់ចូលទៅដល់ដំបូងគាត់គុកពីខាងលិចឯណោះ ខ្ញុំនៅគុកកើត។ ដល់ពីរបីថ្ងៃឡើង គេវាយសួរចម្លើយហើយបានយកទៅដាក់នៅគុកកើត បានឃើញ បាទ។

[១៥:៥៦:១៦]

**ស៖** ចុះ មាស គុន – មាស សុគុន នេះ លោកដឹងស្អីខ្លះអំពី មាស សុគុន នេះ?

**ឆ៖** អត់ដឹងដែរ ដឹងតែទៅតែពីរនាក់ឪហើយនិងកូន ខ្ញុំអត់បានដឹងរឿងមូលហេតុអីយ៉ាងម៉េចមួយយ៉ាងម៉េចពីរ ប៉ុន្តែអត់ដឹងទេ ខ្ញុំនឹកឃើញ មិនដែលស្រាវជ្រាវសួរព្រោះខ្ញុំជាវ័យក្មេងខ្ចី ហើយម្យ៉ាងខ្ញុំជាអ្នកទោសដូចគ្នា។ ខ្ញុំអត់មានសិទ្ធិអីសួរគាត់ទេ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះត្រួសៗបានទេថា តើ មាស សុគុន នេះត្រូវបានចាប់ខ្លួននៅពេលណា?

**ឆ៖** អត់ដឹងដែរ ហ្នឹងអត់ដឹងទេ ខ្ញុំអត់បានដឹង ពេលណា ថ្ងៃណា ខែណា ក៏ខ្ញុំអត់បានដឹងដែរ គ្រាន់តែឃើញនៅគុកហ្នឹង ខ្ញុំមិនអាចចាំខែ ក៏មិនអាចថ្ងៃទៀត ចាំឆ្នាំទៀត។

**ស៖** តើលោកនៅចាំបានទេថា តើមាស គុន ហ្នឹងត្រូវគេឃុំខ្លួនអស់រយៈពេលប៉ុនណាដែរ?

**ឆ៖** អាចដែលខ្ញុំស្មានខ្ទង់ប្រហែលមួយខែ ឬក៏មួយខែជាង ឬក៏មិនដល់មួយខែក៏មិនដឹងដែរ ព្រោះខ្ញុំមិនអាចរាប់បានទេ ព្រោះខ្ញុំបានជម្រាបពីមុនមកអ៊ីចឹងបាទ។

**ស៖** តើប្រាកដទេដែលថាគាត់ជាប់ប្រហែលជាមួយខែហ្នឹង?

**ឆ៖** មិនជាប្រាកដក៏ដូចជាប្រាកដដែរព្រោះខ្ញុំអត់បានរាប់ថ្ងៃ ហើយក៏មិនបានដឹងខែ ព្រោះខ្ញុំវាមិនបានគិតក្នុងនាមខែ ហើយក៏មិនសមខ្លួនថា ក្លាយខ្លួនថាបានមកតុលាការអី បង្កើតខ្មែរក្រហមអីដល់ថ្នាក់ហ្នឹង ខ្ញុំមិនបានស្មានដល់ថ្នាក់ប៉ុណ្ណឹងទេបាទ។

**ស៖** តើលោកដឹងថានៅពេលណា យាយញ៉ បានចូលទៅក្នុងគុក?

**ឆ៖** បានដឹងថាគេ ប្ដីគាត់សម្លាប់ ប្ដីគាត់ស្លាប់ហើយ ៗហ្នឹងប្ដីគាត់គេអត់យកទៅសម្លាប់ទេ។ គេវាយសួរចម្លើយ ដល់វាយសួរចម្លើយទុកយូរទៅបង្អត់បាយ បង្អត់ទឹកទៅ គាត់ក៏ស្លាប់ដោយសារគេ

ធ្វើទារុណកម្ម។ ដល់ប្ដីគាត់ស្លាប់ហើយ បានចំនួនប្រហែលជាអាចកន្លះខែក៏មិនដឹង ១០ថ្ងៃក៏មិនដឹង បានឃើញមួយគ្រួសារគេនាំទៅទៀត បាទតែប៉ុណ្ណឹងទេ។

**ស៖** តើលោកអាចព្យាយាមគិតមើល ថាលោកត្រូវបានគេចាប់ខ្លួននៅឆ្នាំ១៩៧៤។ តើរយៈពេលប្រហែលជាប៉ុន្មាន ទើប មាស គុន, ហ៊ុន គឹមសេង បានចូលទៅដល់ពន្ធនាគារនោះ?

**ឆ៖** គាត់មកយូរហើយ ខ្ញុំមកយូរហើយបានគាត់មកក្រោយទេ។ ខ្ញុំចូលមុនអ៊ីចឹង មុនបែកជ័យជំនះ ហើយគាត់មកបែកហើយបាទ។

**ស៖** ខ្ញុំសូមសួរលោកបន្ថែមទៀត។ តើឆ្នាំណា ក្រោយពីរំដោះ ថ្ងៃរំដោះមួយឆ្នាំ ឬក៏ពីរឆ្នាំ លោកអាចគិតមើលបន្តិចមើល អាចជម្រាបជូនតុលាការបានទេ?

**ឆ៖** បាទ អាហ្នឹងខ្ញុំអត់បានដឹងផង។ អត់បានដឹងផង។ ខាងណាដែលខ្ញុំដឹង បានខ្ញុំជម្រាប។ បើខាងណា ខ្ញុំមិនអាចដឹង គឺខ្ញុំមិនអាចជម្រាបទេ ព្រោះខ្ញុំតាំងនាមជាអ្នកទោស ហើយខ្ញុំអីណាទៅបានគិតថា អ្ហេ! ខ្ញុំជាប់បានប៉ុន្មានខែ គេនាំអ្នកទោសមកទៀត គឺខ្ញុំអត់បានដឹងកន្លែងហ្នឹងបាទ។

**ស៖** ចុះ មាស សារ៉ាត់ ហើយនិងប្ដីរបស់គាត់ មុំ បឿម ថាបានចូលទៅក្នុងគុកហ្នឹងពីពេលណាដែរ?

[១៦:០០:៥៧]

**ឆ៖** អ៊ីវ៉ាត់ ហ្នឹង គាត់មកក្រោយជាមួយគ្រួសារ ជាមួយយាយញ៉ូ។ បឿន ហើយនិងតាគុនហ្នឹងគាត់ទៅមុន មុនគេវាយសួរចម្លើយស្លាប់ទៅហើយ ស្លាប់ហើយហ្នឹងបាន ខ្ញុំមិនចាំថ្ងៃទេ ប្រហែលជាមួយសន្ទុះ ខ្ទង់ប្រហែលជាអាច១០ថ្ងៃ ក៏មួយខែក៏មិនដឹង កន្លះខែក៏មិនដឹង ខ្ញុំអត់ចាំ។ បានគេនាំគ្រួសារហ្នឹងទៅក្រោយ បានសួរគាត់ គាត់ប្រាប់ថា "យាយញ៉ូ"។ យាយញ៉ូ ប្ដីគាត់គេយកមកមុនបាត់ហើយ។ តាគុន ហើយ បងបឿន ហ្នឹង បានខ្ញុំអាចស្គាល់គាត់។ កុំអីអត់ស្គាល់ដែរ គាត់ប្រាប់អ៊ីចឹងទេ។

**ស៖** តើលោកអាចជម្រាបជូនតុលាការអំពីមូលហេតុ ថាហេតុអ្វីបានជាមនុស្សបួននាក់នេះត្រូវបានចាប់ខ្លួន មាស គុន, ហ៊ុន គឹមសេង, មាស សារ៉ាត់ និងប្ដីរបស់ មាស សារ៉ាត់ ឈ្មោះ មុំ បឿន។ តើលោកមានដឹងទេ តើមូលហេតុអីបានជាគេយកទៅដាក់គុកទៅក្រាំងតាចាន់?

**ឆ៖** អត់ដឹងដែរ ខ្ញុំ។

**ស៖** នៅពេលដែលអ្នកទាំងនេះ ចូលទៅដល់គុក មនុស្សទាំងបួននាក់នេះ តើមានពេលណាមួយលោកធ្លាប់បាននិយាយទៅកាន់ពួកគាត់អំពីសួរអំពីមូលហេតុនៃការចាប់ខ្លួនទេ?

**ឆ៖** បាទ ប្អូននាក់ហ្នឹង ហើយខ្ញុំនៅជាមួយគ្នា។ បាយក៏ជាមួយគ្នា ធ្វើការក៏ជាមួយគ្នា ប៉ុន្តែអត់បានសួរទេ ព្រោះខ្ញុំវាក្មេងខ្ចីជាងគេ។ ខ្ចីជាងគេ ហើយម្យ៉ាង ខ្ញុំអត់បានគិតពីបញ្ហា ដូចខ្ញុំបានជម្រាបតុលាការថា ខ្ញុំអត់បានគិតពីបញ្ហារកថ្ងៃ រកខែ អ្នកទោសចូលទេ។ ព្រោះខ្ញុំអ្នកទោស ខ្ញុំបន់ឲ្យតែរស់រានមានជីវិតខ្លួនឯង តែប៉ុណ្ណឹង។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកបានឆ្លើយថា លោកអាចដើរនៅក្នុងបរិវេណគុកហ្នឹងបានតាមចិត្ត ជួនកាលអាចឃើញគេវាយដំសួរចម្លើយ លោកបាននិយាយទៅកាន់អ្នកទោសផ្សេងទៀត លោកធ្វើកិច្ចការដទៃទៀតៗ។ សំណួររបស់ខ្ញុំជាក់លាក់នោះ គ្រាន់តែសួរថាហេតុអ្វីបានជាមនុស្សប្អូននាក់នេះត្រូវបានគេចាប់ខ្លួន? ហើយលោកឆ្លើយថាមិនបានដឹងអំពីមូលហេតុជាក់លាក់នោះទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

[១៦:០៣:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ឥឡូវនេះដល់ពេលសម្រាកនៅរសៀលនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយអង្គជំនុំជម្រះអរគុណចំពោះលោក សយ សែន ដំណើរសវនាការស្ដាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅថ្ងៃនេះមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះសាលាដំបូងកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្ម នៅថ្ងៃសុក្រ ទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ ទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយលោកអាចវិលត្រឡប់ទៅកាន់កន្លែងដែលលោកស្នាក់នៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក សយ សែន វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែក ឲ្យមុនម៉ោងប្រាំបួនព្រឹក។

ហើយអង្គជំនុំជម្រះក៏អញ្ជើញលោកជាបុគ្គលិកអង្គការ ធី.ភី.អូ មកបន្តអង្គុយអមដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដើម្បីជាជំនួយពង្រឹងស្មារតីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនៅថ្ងៃស្អែកទៀតផងដែរ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*